រាជរដ្ឋាភិបាលកម្ពុជា

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# សេចក្តីណែនាំបច្ចេកទេស

# ស្តីពី

# ការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ខណ្ឌ

ខែមីនា ឆ្នាំ២០១៧

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង ផែនការ

ក្រសួងមហាផ្ទៃ

លេខ : ០៩១ ផក.

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការដាក់ឲ្យប្រើប្រាស់សេចក្តីណែនាំបច្ចេកទេស
## ស្តីពីការរៀបចំ និងការកសាងផែនការអភិវឌ្ឍន៍ខណ្ឌ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងផែនការ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងអនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- យោងអនុក្រឹត្យលេខ ២១៩ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- យោងអនុក្រឹត្យលេខ ១៥២ អនក្រ.បក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា១២ នៃអនុក្រឹត្យស្តីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- យោងតាមស្មារតីកិច្ចប្រជុំលើកទី១៣របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កាលពីថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៧។

## សម្រេច

**ប្រការ ១.-**

ដាក់ឲ្យប្រើប្រាស់ **"សេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំ និងការកសាងផែនការអភិវឌ្ឍន៍ខណ្ឌ"**។

**ប្រការ ២.-**

ក្រុមប្រឹក្សាខណ្ឌ គណៈអភិបាលខណ្ឌ និងក្រុមការងារកសាងផែនការខណ្ឌត្រូវរៀបចំ និងកសាងផែនការអភិវឌ្ឍន៍របស់ខ្លួន ស្របតាមសេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ខណ្ឌឲ្យមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងការចូលរួមពីប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា ដោយមានការយកចិត្តទុកដាក់លើបញ្ហាបរិយាប័ន្ន សមធម៌សង្គម និងការប្រែប្រួលអាកាសធាតុ។

**ប្រការ ៣.-**

ក្រសួងផែនការ ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការផ្តល់ការអភិវឌ្ឍសមត្ថភាព និងការគាំទ្រដល់រដ្ឋបាលខណ្ឌ ដើម្បីឲ្យរដ្ឋបាលខណ្ឌមានសមត្ថភាពគ្រប់គ្រាន់ក្នុងការប្រើប្រាស់សេចក្តីណែនាំបច្ចេកទេសនេះសម្រាប់ការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍របស់ខ្លួនប្រកបដោយប្រសិទ្ធភាព។

**ប្រការ ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥.-**

ក្រសួងផែនការ ក្រសួងមហាផ្ទៃ លេខាធិការដ្ឋាន គ.ជ.អ.ប ក្រុមប្រឹក្សា និងគណៈអភិបាលខណ្ឌត្រូវអនុវត្តប្រកាសអន្តរក្រសួងនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី...០២... ខែ...មីនា... ឆ្នាំ២០១៧...

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងផែនការ**

**ឆាយ ថន**

**កន្លែងទទួល**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- រាជកិច្ច
- ដូចប្រការ ៥
- ឯកសារ-កាលប្បវត្តិ

# មាតិកា

## ផ្នែកទី១
## ទិដ្ឋភាពទូទៅនៃការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ខណ្ឌ


១. សេចក្តីផ្តើម ១
២. គោលការណ៍ ២
៣. យន្តការ និងភារកិច្ច ២


## ផ្នែកទី២
## ទម្រង់សៀវភៅផែនការអភិវឌ្ឍន៍ខណ្ឌ


១. ក្របមុខ ៥
២. មាតិកាសៀវភៅផែនការអភិវឌ្ឍន៍ខណ្ឌ ៦
៣. សេចក្តីពន្យល់អំពីបណ្តាសមាសធាតុនៃសៀវភៅផែនការអភិវឌ្ឍន៍ខណ្ឌ ៧


## ផ្នែកទី៣
## វិធីសាស្ត្ររៀបចំ
## និងកសាងផែនការអភិវឌ្ឍន៍ខណ្ឌ


ជំហានទី១ ៖ ការរៀបចំ និងផ្សព្វផ្សាយស្តីពីការរៀបចំផែនការអភិវឌ្ឍន៍ខណ្ឌ ១៨
ជំហានទី២ ៖ ការរៀបចំ និងចងក្រងសេចក្តីព្រាងផែនការអភិវឌ្ឍន៍ខណ្ឌ ២៥
ជំហានទី៣ ៖ ការពិនិត្យ អនុម័ត និងផ្សព្វផ្សាយផែនការអភិវឌ្ឍន៍ខណ្ឌ ៣៨


## ផ្នែកទី៤
## ឧបសម្ព័ន្ធសម្រាប់ជាជំនួយស្មារតី
## នៅពេលរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ខណ្ឌ


ឧបសម្ព័ន្ធទី១ ៖ ទម្រង់គំរូគោលការណ៍ណែនាំផ្នែកគោលនយោបាយ ៤១
ឧបសម្ព័ន្ធទី២ ៖ វិធីសាស្ត្រវិភាគស្ថានភាព ៤៤
ឧបសម្ព័ន្ធទី៣ ៖ វិធីសាស្ត្រចាត់អាទិភាព ៥២
ឧបសម្ព័ន្ធទី៤ ៖ ចំណុចគន្លឹះសម្រាប់ក្រុមប្រឹក្សាពិនិត្យ និងអនុម័តផែនការអភិវឌ្ឍន៍ខណ្ឌ ៥៣
ឧបសម្ព័ន្ធទី៥ ៖ ជំនួយស្មារតីសម្រាប់ការរៀបចំសរសេរស្ថានភាពទូទៅ ៥៤

# ផ្នែកទី១

# ទិដ្ឋភាពទូទៅនៃ

# ការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ខណ្ឌ

## និជ្ជភាពទូទៅ
## នៃការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ខណ្ឌ

### ១. សេចក្ដីផ្ដើម

ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ បានតម្រូវឲ្យក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗរៀបចំកសាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធនានា។ ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ គឺជាមធ្យោបាយយ៉ាងសំខាន់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវប្រើប្រាស់សម្រាប់កំណត់អំពីបញ្ហា និងតម្រូវការជាអាទិភាពយ៉ាងពិតប្រាកដរបស់មូលដ្ឋាន និងយុទ្ធសាស្ត្រនានា ដើម្បីដោះស្រាយនូវបញ្ហាប្រឈមទាំងនោះ សំដៅឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋយ៉ាងមានប្រសិទ្ធភាព។

គោលនយោបាយស្ដីពីប្រព័ន្ធផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ បានផ្ដល់ជាទស្សនទាន និងចង្អុលបង្ហាញដល់ការរៀបចំ និងកែសម្រួលសេចក្ដីណែនាំបច្ចេកទេសស្ដីពីការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ឲ្យស្របតាមចរិតលក្ខណៈផ្សេងៗគ្នារបស់រដ្ឋបាលនីមួយៗនៅថ្នាក់ក្រោមជាតិ។ តាមន័យនេះ ផែនការរាជធានី គឺជាផែនការដែលមានបញ្ចូលគ្នានូវផែនការរបស់រាជធានីផ្ទាល់ និងផែនការរបស់រដ្ឋបាលនានាចំណុះរាជធានី (ខណ្ឌ និងសង្កាត់ក្នុងរាជធានី) ឲ្យទៅជាផែនការរួមមួយ ដោយធានាបាននូវស្វ័យភាព ការផ្សារភ្ជាប់ និងស៊ីសង្វាក់គ្នាក្នុងការអភិវឌ្ឍ (ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងការផ្ដល់សេវាកម្ម) ក្នុងរាជធានី និងក្នុងរដ្ឋបាលចំណុះទាំងនោះ។ ផែនការរបស់រដ្ឋបាលចំណុះរាជធានី រួមមាន ផែនការខណ្ឌ និងផែនការសង្កាត់។ ផែនការខណ្ឌ គឺជាផែនការដែលមានការសម្របសម្រួល ការបំពេញបន្ថែម និងការគាំទ្រដល់ផែនការសង្កាត់។ ផែនការសង្កាត់ក្នុងខណ្ឌ ជាផែនការដែលរៀបចំឡើងដោយមានការពិភាក្សា និងពិគ្រោះយោបល់ផ្ទាល់ជាមួយប្រជាពលរដ្ឋនៅក្នុងសង្កាត់នីមួយៗ។ ផែនការខណ្ឌ និងផែនការសង្កាត់ជាសមាសភាគនៃផែនការរាជធានី។ ការពិគ្រោះយោបល់ និងការចូលរួមរបស់ប្រជាពលរដ្ឋ វិស័យឯកជន សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានាក្នុងដំណើរការរៀបចំផែនការរាជធានី ផែនការខណ្ឌ និងផែនការសង្កាត់ចំណុះរាជធានី គឺជាគោលការណ៍សំខាន់ និងចាំបាច់។

ក្រុមប្រឹក្សាខណ្ឌនីមួយៗ ត្រូវរៀបចំកសាងផែនការអភិវឌ្ឍន៍ខណ្ឌរបស់ខ្លួន ដែលឆ្លុះបញ្ចាំងអំពី ១).ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំសម្រាប់អាណត្តិរបស់ក្រុមប្រឹក្សា និង២).កម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរយៈពេលប្រាំឆ្នាំ។ ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំសម្រាប់អាណត្តិរបស់ក្រុមប្រឹក្សា ជាផែនការដែលមានចរិតជាទស្សនៈអភិវឌ្ឍន៍រួមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយរួមបញ្ចូលនូវគោលដៅអភិវឌ្ឍន៍របស់ក្រសួង ស្ថាប័ន ឬអង្គភាព ឬការិយាល័យនានារបស់រាជរដ្ឋាភិបាល សង្គមស៊ីវិល និងវិស័យឯកជនដែលបានផ្ដល់សេវា សម្ភារៈ ឬហេដ្ឋារចនាសម្ព័ន្ធដោយផ្ទាល់នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខណ្ឌនោះ។ កម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរយៈពេលប្រាំឆ្នាំ ជារបៀបវារៈ ឬកម្មវិធីជាក់ស្ដែង ដែលរដ្ឋបាលខណ្ឌនីមួយៗចង់សម្រេចបានក្នុងអាណត្តិខ្លួន សម្រាប់បង្ហាញពីគណនេយ្យភាពរបស់ខ្លួនចំពោះប្រជាពលរដ្ឋ និងចំពោះរាជរដ្ឋាភិបាល។ កម្មវិធីអភិវឌ្ឍន៍មូលដ្ឋានមានសមាសភាគ ១).ក្របខ័ណ្ឌវិនិយោគ ២).ក្របខ័ណ្ឌផ្ដល់សេវាកម្ម និង៣).ការដាក់ចេញលិខិតបទដ្ឋានគតិយុត្តនានា។

## ២. គោលការណ៍

ការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ខណ្ឌ ត្រូវផ្អែកលើគោលការណ៍សំខាន់ដូចខាងក្រោម ៖

១. ការចែករំលែកព័ត៌មាន

២. តម្លាភាព

៣. សង្គតិភាព និងសុខដុមនីយកម្ម

៤. ការចូលរួមពិគ្រោះយោបល់ជាទូទៅ

៥. ការឆ្លើយតបនឹងតម្រូវការ

៦. គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ

៧. ប្រសិទ្ធភាព និងសុក្រឹតភាពសេដ្ឋកិច្ច និងសង្គម

៨. ការធានាចីរភាពធនធានធម្មជាតិ និងបរិស្ថាន

៩. ការធានាសមធម៌។

## ៣. យន្តការ និងភារកិច្ច

យន្តការ ដែលទទួលខុសត្រូវក្នុងការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ខណ្ឌ គឺ ៖

**៣.១. ក្រុមប្រឹក្សាខណ្ឌ** មានភារកិច្ច ៖

- ណែនាំផ្នែកគោលនយោបាយសម្រាប់កសាងផែនការអភិវឌ្ឍន៍ខណ្ឌ
- ពិនិត្យ និងអនុម័តប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍ខណ្ឌ
- ចូលរួមក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ខណ្ឌ
- តាមដាន និងវាយតម្លៃក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ខណ្ឌ
- ពិនិត្យ និងអនុម័តផែនការអភិវឌ្ឍន៍ខណ្ឌ
- តាមដានត្រួត ពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ខណ្ឌ
- ពិនិត្យ និងអនុម័តសំណើវិសោធនកម្មផែនការអភិវឌ្ឍន៍ខណ្ឌ ក្នុងករណីចាំបាច់។

**៣.២. គណៈអភិបាលខណ្ឌ** មានភារកិច្ច ៖

- ដឹកនាំ និងសម្របសម្រួលការកសាងផែនការអភិវឌ្ឍន៍ ស្របតាមការណែនាំរបស់ក្រុមប្រឹក្សាខណ្ឌ
- ដឹកនាំសិក្ខាសាលា វេទិកាពិគ្រោះយោបល់នានា ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ខណ្ឌ
- ពិនិត្យ និងផ្តល់យោបល់ទៅលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ មុនដាក់ជូនក្រុមប្រឹក្សាខណ្ឌពិនិត្យ និងអនុម័ត
- ដាក់ជូនក្រុមប្រឹក្សាខណ្ឌ ពិនិត្យ និងអនុម័តលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ខណ្ឌ
- ដាក់សំណើវិសោធនកម្មផែនការអភិវឌ្ឍន៍ខណ្ឌជូនក្រុមប្រឹក្សាខណ្ឌពិនិត្យ និងអនុម័ត
- ដឹកនាំ និងសម្របសម្រួលការធ្វើវិសោធនកម្មផែនការអភិវឌ្ឍន៍ខណ្ឌ
- តាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ខណ្ឌ តាមការណែនាំរបស់ក្រុមប្រឹក្សា។

**៣.៣. ក្រុមការងារកសាងផែនការខណ្ឌ** មានភារកិច្ច ៖

- រៀបចំសេចក្តីព្រាងប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍ខណ្ឌ
- រៀបចំសេចក្តីព្រាងគោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សាខណ្ឌ
- សម្របសម្រួលដំណើរការកសាងផែនការអភិវឌ្ឍន៍ខណ្ឌ

- រៀបចំសិក្ខាសាលា វេទិកាពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធនានាក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ខណ្ឌ
- រៀបចំចងក្រង និងកែសម្រួលសេចក្តីព្រាងផែនការអភិវឌ្ឍន៍ខណ្ឌ
- រៀបចំសេចក្តីព្រាងសេចក្តីសម្រេចស្តីពីការដាក់ឲ្យប្រើប្រាស់ផែនការអភិវឌ្ឍន៍ខណ្ឌ
- រៀបចំសេចក្តីព្រាងវិសោធនកម្មផែនការអភិវឌ្ឍន៍ខណ្ឌ។

**៣.៤. គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសខណ្ឌ** មានភារកិច្ច ៖

- ចូលរួមក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ខណ្ឌ
- សម្របសម្រួលការចូលរួមរបស់គ្រប់អ្នកពាក់ព័ន្ធក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍ខណ្ឌ
- ពិនិត្យ និងជូនយោបល់ទៅក្រុមប្រឹក្សា មុនធ្វើការអនុម័តលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍។

យន្តការទាំងបួនខាងលើ គឺជាយន្តការស្នូលក្នុងការចូលរួម និងទទួលខុសត្រូវផ្ទាល់លើការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ខណ្ឌ។ ជាមួយគ្នានេះ ដើម្បីធានាឲ្យផែនការអភិវឌ្ឍន៍ខណ្ឌមានគុណភាព នោះចាំបាច់ត្រូវមានយន្តការគាំទ្រ ដែលមាន ៖

**៣.៥. គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខណ្ឌ** មានភារកិច្ច ៖

- ចូលរួមក្នុងការកសាងចក្ខុវិស័យ និងយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខណ្ឌ និងដើម្បីឲ្យសម្រេចបាននូវសមភាពយេនឌ័រ និងការផ្តល់សេវាផ្សេងៗដែលពាក់ព័ន្ធនឹងសមភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារ
- ប្រមូល និងវិភាគព័ត៌មាន ទិន្នន័យដែលទាក់ទងនឹងយេនឌ័រ និងតម្រូវការស្ត្រី យុវវ័យ និងកុមារ ដើម្បីដាក់បញ្ចូលព័ត៌មានទាំងនេះទៅក្នុងផែនការអភិវឌ្ឍន៍របស់ក្រុមប្រឹក្សាខណ្ឌ
- ចូលរួមផ្តល់ព័ត៌មាន និងការពារខ្លឹមសារការងារក្នុងដែនសមត្ថកិច្ចខ្លួនក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ខណ្ឌ
- សហការបំពេញការងារនានាតាមសំណូមពរពីក្រុមការងារកសាងផែនការខណ្ឌ ដើម្បីកសាងផែនការអភិវឌ្ឍន៍ខណ្ឌ។

**៣.៦. មន្ទីរផែនការរាជធានី** មានភារកិច្ច ៖

- គាំទ្របច្ចេកទេសក្នុងការកសាងផែនការអភិវឌ្ឍន៍ខណ្ឌដល់ក្រុមការងារកសាងផែនការខណ្ឌ ដូចជា ការងារស្រង់ទិន្នន័យពីមូលដ្ឋានភូមិ សង្កាត់ ការងារចងក្រងកម្រងព័ត៌មានស្ថានភាពខណ្ឌប្រចាំឆ្នាំ ឯកសារពិន្ទុវិស័យ និងគាំទ្រការងាររៀបចំ និងសម្របសម្រួលក្នុងកិច្ចប្រជុំឬវេទិកានានាក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ខណ្ឌ
- សហការជាមួយមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី និងទីចាត់ការផែនការ និងវិនិយោគរាជធានី ក្នុងការបណ្តុះបណ្តាលអំពីបច្ចេកទេសស្តីពីការកសាងផែនការអភិវឌ្ឍន៍ខណ្ឌ ការប្រើប្រាស់ទិន្នន័យ និងបច្ចេកទេសតាមដាន និងវាយតម្លៃលទ្ធផលអនុវត្តផែនការអភិវឌ្ឍន៍ខណ្ឌ
- សហការផ្តល់ការគាំទ្របច្ចេកទេសតាមដាននិងវាយតម្លៃលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍ខណ្ឌដល់សមាជិកក្រុមប្រឹក្សាខណ្ឌនិងបុគ្គលិកសំខាន់ៗរបស់ខណ្ឌតាមសំណើពីអ្នកពាក់ព័ន្ធ។

**៣.៧. នីចាត់ការផែនការ និងវិនិយោគរាជធានី** មានភារកិច្ច ៖

- សហការជាមួយមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី មន្ទីរផែនការរាជធានី និង ឬអង្គភាពជំនាញក្នុងការបណ្តុះបណ្តាលសមាជិកក្រុមប្រឹក្សាខណ្ឌ ក្រុមការងារកសាងផែនការខណ្ឌ និងអ្នកពាក់ព័ន្ធអំពីនីតិវិធីកសាងផែនការអភិវឌ្ឍន៍ខណ្ឌ
- ជំរុញ និងគាំទ្រការប្រមូល និងរក្សាសៀវភៅផែនការអភិវឌ្ឍន៍ខណ្ឌទុកជាឯកសារ
- ជួយក្រុមប្រឹក្សាខណ្ឌក្នុងការរៀបចំ និងអនុវត្តផែនការអភិវឌ្ឍន៍ខណ្ឌ និងការតាមដាន និងវាយតម្លៃអំពីលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍ខណ្ឌ។

**៣.៨. ការិយាល័យផែនការ និងអភិវឌ្ឍន៍របស់រដ្ឋបាលខណ្ឌ** មានភារកិច្ច ៖

- ជួយក្រុមការងារកសាងផែនការខណ្ឌ ក្នុងការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ខណ្ឌ
- ចូលរួមក្នុងការវិភាគស្ថានភាពខណ្ឌ
- ចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់នានាស្តីពីការកសាងផែនការអភិវឌ្ឍន៍ខណ្ឌ
- គាំទ្រដល់សង្កាត់ក្នុងការកសាង និងការអនុវត្តផែនការអភិវឌ្ឍន៍របស់សង្កាត់។

**៣.៩. ការិយាល័យផែនការខណ្ឌ** មានភារកិច្ច ៖

- ជួយសម្របសម្រួល និងជំរុញអាជ្ញាធរភូមិ សង្កាត់ ក្នុងការស្រង់ទិន្នន័យមូលដ្ឋានភូមិ សង្កាត់
- ជួយក្រុមការងារកសាងផែនការខណ្ឌក្នុងការវិភាគព័ត៌មានស្ថានភាព និងពិន្ទុវិស័យ ភូមិ សង្កាត់ ខណ្ឌ
- សហការជាមួយក្រុមការងារកសាងផែនការខណ្ឌក្នុងការរៀបចំបណ្តាឧបករណ៍សម្រាប់ការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍នៅខណ្ឌ។

**៣.១០. ការិយាល័យជំនាញ និងអង្គភាពនានានៅថ្នាក់ខណ្ឌ** មានភារកិច្ច ៖

- ចូលរួម និងផ្តល់ព័ត៌មានជាធាតុចូលដល់ការកសាងផែនការអភិវឌ្ឍន៍ខណ្ឌ
- ចូលរួមក្នុងការវិភាគស្ថានភាពខណ្ឌ
- ចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់នានាស្តីពីការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ខណ្ឌ។

**៣.១១. ចៅសង្កាត់** មានភារកិច្ច ៖

- ចូលរួម និងផ្តល់ព័ត៌មានជាធាតុចូលពាក់ព័ន្ធនឹងការកសាងផែនការអភិវឌ្ឍន៍ខណ្ឌ
- ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់នានាស្តីពីការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ខណ្ឌ។

**៣.១២. អង្គការសង្គមស៊ីវិល ក្រុមយុវជន និងវិស័យឯកជន** មានភារកិច្ច ៖

- ចូលរួម និងផ្តល់នូវព័ត៌មាននានាដែលពាក់ព័ន្ធនឹងការកសាងផែនការអភិវឌ្ឍន៍ខណ្ឌ
- ចូលរួមក្នុងការវិភាគស្ថានភាពខណ្ឌ និង
- ចូលរួមកិច្ចប្រជុំ និងវេទិកានានាដែលពាក់ព័ន្ធនឹងការកសាងផែនការអភិវឌ្ឍន៍ខណ្ឌ។

**៣.១៣. ប្រជាពលរដ្ឋ** មានភារកិច្ច ៖

- លើកឡើងនូវបញ្ហា និងតម្រូវការអាទិភាពតាមរយៈការចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់នានាសម្រាប់ជាធាតុចូលឲ្យការកសាងផែនការអភិវឌ្ឍន៍ខណ្ឌ
- ចូលរួមក្នុងការតាមដាន និងវាយតម្លៃលើការអនុវត្តផែនការអភិវឌ្ឍន៍ខណ្ឌ។

# ផ្នែកទី២

# ទម្រង់សៀវភៅផែនការអភិវឌ្ឍន៍ខណ្ឌ

**១ .គ្របមុខ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ

# ( ២០.... - ២០.... )

# ខណ្ឌ................រាជធានីភ្នំពេញ

បានទទួលការអនុម័តពីក្រុមប្រឹក្សាខណ្ឌ

ក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញលើកទី... អាណត្តិទី... ថ្ងៃទី ខែ ឆ្នាំ២០...

## ២. មាតិកាសៀវភៅផែនការអភិវឌ្ឍន៍ខណ្ឌ

សេចក្តីសម្រេចស្តីពីការដាក់ឲ្យប្រើប្រាស់ផែនការអភិវឌ្ឍន៍ខណ្ឌរយៈពេលប្រាំឆ្នាំ
អារម្ភកថា
សេចក្តីផ្តើម
ផែនទីខណ្ឌ
**ជំពូកទី១ : ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច**
១.១. ស្ថានភាពព័ត៌មានទូទៅរបស់ខណ្ឌ
១.១.១. ស្ថានភាពភូមិសាស្រ្ត
១.១.២. សេចក្តីសង្ខេបព័ត៌មាន និងទិន្នន័យសេដ្ឋកិច្ច សង្គមកិច្ច
១.២. ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម
១.២.១. ស្ថានភាពសេដ្ឋកិច្ច
១.២.២. ស្ថានភាពសង្គមកិច្ច
១.២.៣. ស្ថានភាពនៃការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងការប្រែប្រួលអាកាសធាតុ
១.២.៤. ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ
**ជំពូកទី២ : ក្របខ័ណ្ឌអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំសម្រាប់អាណត្តិក្រុមប្រឹក្សាខណ្ឌ**
២.១. ចក្ខុវិស័យអភិវឌ្ឍន៍
២.២. គោលបំណងអភិវឌ្ឍន៍
២.៣. គោលដៅអភិវឌ្ឍន៍
២.៤. យុទ្ធសាស្រ្តអភិវឌ្ឍន៍
២.៤.១.យុទ្ធសាស្រ្តអភិវឌ្ឍន៍សេដ្ឋកិច្ច
២.៤.២.យុទ្ធសាស្រ្តអភិវឌ្ឍន៍សង្គមកិច្ច
២.៤.៣.យុទ្ធសាស្រ្តអភិវឌ្ឍន៍ការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ
២.៤.៤.យុទ្ធសាស្រ្តអភិវឌ្ឍន៍ការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ
២.៥. តារាងក្របខ័ណ្ឌអភិវឌ្ឍន៍ខណ្ឌ
**ជំពូកទី៣ : កម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរយៈពេលប្រាំឆ្នាំ**
៣.១. ក្របខ័ណ្ឌវិនិយោគ
៣.២. ក្របខ័ណ្ឌផ្តល់សេវាកម្ម
៣.៣. ការដាក់ចេញលិខិតបទដ្ឋានគតិយុត្តនានា
៣.៤. ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម
**ជំពូកទី៤ : ការតាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍**
៤.១. យន្តការតាមដាន និងវាយតម្លៃ
៤.២. វិធីសាស្រ្តតាមដាន និងវាយតម្លៃ
៤.៣. សូចនាករតាមដាន និងវាយតម្លៃ
**ឧបសម្ព័ន្ធ**

## ៣. សេចក្តីពន្យល់
## អំពីបណ្តាសមាសធាតុក្នុងសៀវភៅផែនការអភិវឌ្ឍន៍ខណ្ឌ

### សេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់ផែនការអភិវឌ្ឍន៍ខណ្ឌ

បន្ទាប់ពីទំព័រក្របសៀវភៅ គឺសេចក្តីសម្រេច។ សេចក្តីសម្រេច គឺជាលិខិតបទដ្ឋានគតិយុត្តរបស់ក្រុមប្រឹក្សាខណ្ឌ ក្នុងការដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវផែនការអភិវឌ្ឍន៍ខណ្ឌ។ ខ្លឹមសារសំខាន់ក្នុងសេចក្តីសម្រេច រួមមាន ការចូលជាធរមាននូវផែនការអភិវឌ្ឍន៍ខណ្ឌ ការណែនាំដល់គណៈអភិបាលខណ្ឌឲ្យធ្វើការផ្សព្វផ្សាយ ការអនុវត្ត និងការតាមដាន វាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ខណ្ឌ។ សេចក្តីសម្រេចនេះចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាខណ្ឌ។

### អារម្ភកថា

អារម្ភកថា គឺជាអត្ថបទបង្ហាញពីសារៈប្រយោជន៍នៃផែនការអភិវឌ្ឍន៍ ការថ្លែងអំណរគុណចំពោះអ្នកដែលបានចូលរួមរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ និងសេចក្តីសង្ឃឹមថានឹងទទួលបានការគាំទ្រពីអ្នកពាក់ព័ន្ធ (អារម្ភកថាមិនគួរសរសេរវែងពេក គឺត្រឹមមួយទំព័រគឺជាការប្រសើរ)។ អារម្ភកថានេះ ត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សខណ្ឌ។

### សេចក្តីផ្តើម

សេចក្តីផ្តើម ត្រូវសរសេរពីវឌ្ឍនភាពនៅក្នុងខណ្ឌ និងមូលហេតុដែលនាំឲ្យមានការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ ព្រមទាំងគោលបំណង និងសង្ខេបពីដំណើរការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ (សេចក្តីផ្តើមមិនគួរសរសេរវែងពេកទេ)។

### ផែនទីខណ្ឌ

ជាផែនទីខណ្ឌ ដែលបង្ហាញពីលក្ខណៈភូមិសាស្ត្រ ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច ធនធានធម្មជាតិ និងទីតាំងរដ្ឋបាលក្នុងខណ្ឌ។ ផែនទីនេះរៀបចំលើក្រដាសទំហំA3 និងប្រើនិមិត្តសញ្ញាតាងឱ្យវត្ថុកំពុងមានក្នុងខណ្ឌ ដូចជានិមិត្តសញ្ញានៃប្រព័ន្ធផ្លូវថ្នល់ ស្ពាន លូរំដោះទឹក ប្រព័ន្ធប្រឡាយទឹក ទីតាំងរដ្ឋបាល ទីតាំងសាលារៀន ទីតាំងផ្តល់សេវាសុខភាពសាធារណៈ ទីតាំងសាសនា វាលស្រែ ធនធានធម្មជាតិ ។ល។

### ជំពូកទី១ : ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច

#### ១.១. ស្ថានភាពព័ត៌មានទូទៅរបស់ខណ្ឌ

**១.១.១. ស្ថានភាពភូមិសាស្ត្រ ៖** បរិយាយអំពីស្ថានភាពទូទៅរបស់ខណ្ឌ ដែលរួមមាន ដូចជា ព្រំប្រទល់ ទីតាំង ស្ថានភាពដី ចំនួនសង្កាត់ និងចំនួនភូមិ ប្រព័ន្ធគមនាគមន៍។ល។

**១.១.២. សេចក្តីសង្ខេបព័ត៌មាន និងទិន្នន័យសេដ្ឋកិច្ច សង្គមកិច្ច**

សេចក្តីសង្ខេបទិន្នន័យចម្បងរបស់ខណ្ឌ ត្រូវបានបង្ហាញក្នុងតារាងខាងក្រោម ៖

# តារាងសង្ខេបទិន្នន័យចម្បងរបស់ខណ្ឌ

| ល.រ | បរិយាយ | ឆ្នាំ... |
|---|---|---|
| **ព័ត៌មានទូទៅ** | | |
| ១ | ផ្ទៃដីខណ្ឌ (គ.ម² ) | |
| ២ | ចំនួនសង្កាត់ | |
| ៣ | ចំនួនភូមិ | |
| ៤ | ចំនួនគ្រួសារ | |
| ៥ | % មេគ្រួសារជាស្ត្រី | |
| ៦ | ចំនួនប្រជាជនសរុប | |
| ៧ | ចំនួនស្រី | |
| ៨ | ចំនួនប្រុស | |
| ៩ | % អ្នកមានអាយុពី០-១៧ឆ្នាំ | |
| ១០ | % អ្នកមានអាយុពី១៨-៦០ឆ្នាំ | |
| ១១ | % អ្នកមានអាយុពី៦១ឆ្នាំឡើង | |
| ១២ | កំណើនប្រជាជនប្រចាំឆ្នាំ (%) | |
| ១៣ | អត្រាភាពក្រីក្រ (%) | |
| ១៤ | % អ្នកមានមុខរបរចម្បងផ្នែកកសិកម្ម | |
| ១៥ | % អ្នកមានមុខរបរចម្បងផ្នែកសិប្បកម្ម | |
| ១៦ | % អ្នកមានមុខរបរចម្បងផ្នែកសេវាកម្ម | |
| ១៧ | % មនុស្សទៅរកការងារធ្វើនៅក្នុងប្រទេស | |
| ១៨ | % មនុស្សទៅរកការងារធ្វើនៅក្រៅប្រទេស | |
| ១៩ | % ខ្នងផ្ទះមានអគ្គិសនីប្រើប្រាស់ | |
| **អប់រំ** | | |
| ២០ | % កុមារអាយុ៣-៥ឆ្នាំបានចូលរៀន | |
| ២១ | % កុមារអាយុ៦ឆ្នាំបានចូលរៀន | |
| ២២ | % កុមារអាយុ៦-១១ឆ្នាំបានចូលរៀន | |
| ២៣ | % កុមារអាយុ១២-១៤ឆ្នាំនៅរៀន | |
| ២៤ | % អ្នកចេះអក្សរអាយុ១៥-១៧ឆ្នាំ | |
| ២៥ | % អ្នកចេះអក្សរអាយុ១៨-៤៥ឆ្នាំ | |
| **សុខាភិបាល** | | |
| ២៦ | ចំនួនមណ្ឌលសុខភាព | |
| ២៧ | % ស្ត្រីសម្រាលកូនដោយឆ្មបពេទ្យ | |
| ២៨ | អត្រាស្លាប់របស់មាតាក្រោយពេលសម្រាល(០-១ខែ) ក្នុង១ពាន់កំណើត | |
| ២៩ | អត្រាស្លាប់របស់កុមារក្រោយពេលកើត(០-១ខែ)ក្នុង១ពាន់កំណើត | |
| ៣០ | % កុមារអាយុពី៩-១២ខែបានចាក់ថ្នាំបង្ការគ្រប់ចំនួន | |
| ៣១ | ចំនួនគ្រួសារមានសមាជិកកើតជំងឺអេដស៍ | |
| **ភាពងាយរងគ្រោះ** | | |
| ៣២ | ចំនួនជនពិការ | |

| ល.រ | បរិយាយ | ឆ្នាំ... |
|---|---|---|
| ៣៣ | % ជនពិការអាយុ១៨ឆ្នាំឡើងមិនអាចរកចំណូលបាន | |
| ៣៤ | ចំនួនកុមារកំព្រាឪពុកម្តាយស្លាប់ដោយជំងឺអេដស៍ | |
| ៣៥ | ចំនួនចាស់ជរាគ្មានទីពឹង(អាយុ៦១ឆ្នាំឡើង) | |
| **ធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ** | | |
| ៣៦ | ចំនួនគ្រួសាររងគ្រោះដោយខ្យល់ព្យុះ/កន្ត្រាក់ | |
| ៣៧ | ចំនួនគ្រួសាររងគ្រោះដោយទឹកជំនន់ | |
| ៣៨ | ចំនួនគ្រួសាររងគ្រោះដោយរាំងស្ងួត | |
| ៣៩ | % គ្រួសារមានសេវាប្រមូលសំរាមតាមផ្ទះ | |
| ៤០ | % គ្រួសារមានទឹកស្អាតប្រើប្រាស់ | |
| ក្នុង នោះ: | % គ្រួសារមានទឹកម៉ាស៊ីនប្រើប្រាស់ | |
| | % គ្រួសារមានទឹកអណ្តូងស្នប់ឬអណ្តូងចម្រុះ | |
| | % គ្រួសារប្រើទឹកអណ្តូងជីកមានការការពារ | |
| | % គ្រួសារប្រើទឹកភ្លៀងមានការការពារ | |
| ៤១ | % គ្រួសារមានបង្គន់អនាម័យប្រើប្រាស់ | |
| **រដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ** | | |
| ៦២ | % កុមារបានចុះសំបុត្រកំណើត(០-៣០ថ្ងៃ) | |
| ៤៣ | ចំនួនគ្រួសារមានអំពើហិង្សាក្នុងគ្រួសារ | |
| ៤៤ | ចំនួនអ្នកស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍ | |
| ៤៥ | ចំនួនអ្នកស្លាប់ដោយអំពើហិង្សានានា | |
| ៤៦ | ចំនួនគ្រួសារមានសមាជិកប្រើប្រាស់គ្រឿងញៀន | |

### ១.២. ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម

ក្នុងចំណុចនេះ ត្រូវរៀបរាប់អំពីអ្វីខ្លះ ដែលខណ្ឌមានសក្តានុពលសម្រាប់បម្រើឱ្យសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ និងអ្វីខ្លះដែលជាឧបសគ្គ ឬជាបញ្ហាប្រឈមដល់ការអភិវឌ្ឍ និងការឆ្លើយតបទៅនឹងសេចក្តីត្រូវការទាំងនោះ។

ក្រុមការងាររកសាងផែនការខណ្ឌ ត្រូវសរសេរតាមលំដាប់លំដោយ ដោយផ្តើមពីស្ថានភាពសេដ្ឋកិច្ចទៅស្ថានភាពសង្គមកិច្ច ស្ថានភាពប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ រហូតដល់ស្ថានភាពគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ (ឧបសម្ព័ន្ធទី៥) ដោយផ្អែកលើលទ្ធផលនៃការវិភាគស្ថានភាពបច្ចុប្បន្នរបស់ខណ្ឌ ការវិភាគពិន្ទុវិស័យ និងឯកសារស្ថានភាពខណ្ឌ។

## ជំពូកទី២ ៖ ក្របខ័ណ្ឌអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំសម្រាប់អាណត្តិក្រុមប្រឹក្សាខណ្ឌ

### ២.១. ចក្ខុវិស័យអភិវឌ្ឍន៍

ចក្ខុវិស័យអភិវឌ្ឍន៍ គឺជាទស្សនៈ ដែលក្រុមប្រឹក្សាចង់បានការប្រែប្រួលជីវភាពរស់នៅរបស់ប្រជាពលរដ្ឋខ្លួនឲ្យបានស្របតាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាល។

## ២.២. គោលបំណងអភិវឌ្ឍន៍

គោលបំណងអភិវឌ្ឍន៍ គឺជាការបរិយាយពីលទ្ធផលរួមដែលក្រុមប្រឹក្សាចង់បានតាមរយៈការអនុវត្តផែនការអភិវឌ្ឍន៍នេះ ដែលត្រូវរួមចំណែកក្នុងការសម្រេចបាននូវចក្ខុវិស័យអភិវឌ្ឍន៍។

## ២.៣. គោលដៅអភិវឌ្ឍន៍

គោលដៅអភិវឌ្ឍន៍ គឺជាការបរិយាយអំពីលទ្ធផលនានាដែលក្រុមប្រឹក្សាចង់បានតាមវិស័យនីមួយៗ តាមរយៈការអនុវត្តផែនការអភិវឌ្ឍន៍ ដែលរួមចំណែកក្នុងការសម្រេចបាននូវគោលបំណងអភិវឌ្ឍន៍របស់ខ្លួន។

## ២.៤. យុទ្ធសាស្ត្រអភិវឌ្ឍន៍

យុទ្ធសាស្ត្រអភិវឌ្ឍន៍ គឺជាការកំណត់វិធីសាស្ត្រ ឬសកម្មភាពដែលត្រូវអនុវត្ត ដើម្បីសម្រេចបានគោលដៅអភិវឌ្ឍន៍នីមួយៗដែលបានកំណត់ខាងលើ។ យុទ្ធសាស្ត្រអភិវឌ្ឍន៍ខណ្ឌ ត្រូវកំណត់តាមផ្នែកនីមួយៗ ដូចខាងក្រោម ៖

### ២.៤.១. យុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ច

ចំណុចនេះ ត្រូវបរិយាយពីយុទ្ធសាស្ត្រនានាសម្រាប់អភិវឌ្ឍន៍របស់បណ្តាវិស័យក្នុងផ្នែកសេដ្ឋកិច្ច ដើម្បីចូលរួមចំណែកក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍របស់ខណ្ឌ។

### ២.៤.២. យុទ្ធសាស្ត្រអភិវឌ្ឍន៍សង្គមកិច្ច

ចំណុចនេះ ត្រូវបរិយាយពីយុទ្ធសាស្ត្រនានាសម្រាប់អភិវឌ្ឍន៍របស់បណ្តាវិស័យក្នុងផ្នែកសង្គមកិច្ច ដើម្បីចូលរួមចំណែកក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍របស់ខណ្ឌ។

### ២.៤.៣. យុទ្ធសាស្ត្រគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ

ចំណុចនេះ ត្រូវបរិយាយពីយុទ្ធសាស្ត្រនានាសម្រាប់អភិវឌ្ឍន៍របស់បណ្តាវិស័យក្នុងផ្នែកគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ដើម្បីចូលរួមចំណែកក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍របស់ខណ្ឌ។

### ២.៤.៤. យុទ្ធសាស្ត្រគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

ចំណុចនេះ ត្រូវបរិយាយពីយុទ្ធសាស្ត្រនានាសម្រាប់អភិវឌ្ឍន៍របស់បណ្តាវិស័យក្នុងផ្នែកគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ដើម្បីចូលរួមចំណែកក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍របស់ខណ្ឌ។

## ២.៥. តារាងក្របខ័ណ្ឌអភិវឌ្ឍន៍ខណ្ឌ

តារាងក្របខ័ណ្ឌអភិវឌ្ឍន៍ខណ្ឌ

| **ចក្ខុវិស័យ ÷** | | | | | |
|---|---|---|---|---|---|
| គោលបំណង និងគោលដៅ | សូចនាករ | | | | យុទ្ធសាស្ត្រអភិវឌ្ឍន៍ |
| | ការបរិយាយ | ឯកតា | ដើមគ្រា | ២០... | |
| **១. ផ្នែកសេដ្ឋកិច្ច** | | | | | |
| **១.១. គោលបំណង ៖** | | | | | |
| ១.១.១. គោលដៅ៖ | | | | | |
| ១.១.២. គោលដៅ៖ | | | | | |
| **១.២. គោលបំណង ៖** | | | | | |
| ១.២.១. គោលដៅ៖ | | | | | |
| ១.២.២. គោលដៅ៖ | | | | | |
| **២. ផ្នែកសង្គមកិច្ច** | | | | | |
| **២.១. គោលបំណង ៖** | | | | | |
| ២.១.១. គោលដៅ៖ | | | | | |
| ២.១.២. គោលដៅ៖ | | | | | |
| **៣. ផ្នែកគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ** | | | | | |
| **៣.១. គោលបំណង៖** | | | | | |
| ៣.១.១. គោលដៅ៖ | | | | | |
| ៣.១.២. គោលដៅ៖ | | | | | |
| **៤. ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ** | | | | | |
| **៤.១. គោលបំណង ៖** | | | | | |
| ៤.១.១. គោលដៅ៖ | | | | | |
| ៤.១.២. គោលដៅ៖ | | | | | |

## ជំពូកទី៣ ៖ កម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរយៈពេលប្រាំឆ្នាំ

កម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរយៈពេលប្រាំឆ្នាំគឺជា របៀបវារៈ ឬកម្មវិធីជាក់ស្តែងដែលក្រុមប្រឹក្សាខណ្ឌចង់សម្រេចបានក្នុងអាណត្តិខ្លួន សម្រាប់បង្ហាញពីគណនេយ្យភាពរបស់ខ្លួនចំពោះប្រជាពលរដ្ឋ និងចំពោះរាជរដ្ឋាភិបាល។ ក្នុងការរៀបចំកម្មវិធីអភិវឌ្ឍន៍មូលដ្ឋាននេះ រដ្ឋបាលខណ្ឌត្រូវផ្អែកតាមមុខងារ ធនធាន សិទ្ធិអំណាចរបស់ខ្លួន និងខ្លឹមសារនៃផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំសម្រាប់អាណត្តិរបស់ខ្លួន។

កម្មវិធីអភិវឌ្ឍន៍មូលដ្ឋាន ជាឯកសារសម្រាប់ពិចារណានៅពេលរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល និងថវិកា និងសម្រាប់ការតាមដាន និងវាយតម្លៃអំពីការបំពេញការងាររបស់រដ្ឋបាលខណ្ឌ និងរបស់ការិយាល័យ អង្គភាពជំនាញនានាក្នុងខណ្ឌ។

កម្មវិធីអភិវឌ្ឍន៍មូលដ្ឋានមានសមាសភាគចំនួនបីគឺ ១).ក្របខ័ណ្ឌវិនិយោគ ២).ក្របខ័ណ្ឌផ្តល់សេវាកម្ម និង៣).ការដាក់ចេញលិខិតបទដ្ឋានគតិយុត្តនានា។

## ៣.១. ក្របខ័ណ្ឌវិនិយោគ

ក្របខ័ណ្ឌវិនិយោគ ដាក់បញ្ចូលនូវ ៖

- ក្របខ័ណ្ឌវិនិយោគរបស់រដ្ឋបាលខណ្ឌ
- ក្របខ័ណ្ឌវិនិយោគរបស់ការិយាល័យ អង្គភាពជំនាញនានា។

### ក). ក្របខ័ណ្ឌវិនិយោគរយៈពេលប្រាំឆ្នាំរបស់រដ្ឋបាលខណ្ឌ

ដើម្បីឆ្លើយតបទៅនឹងក្របខ័ណ្ឌអភិវឌ្ឍន៍ខណ្ឌ ក្នុងរយៈពេលប្រាំឆ្នាំនៃអាណត្តិរបស់ក្រុមប្រឹក្សាខណ្ឌ (ឆ្នាំ..... ដល់ឆ្នាំ.....) រដ្ឋបាលខណ្ឌដាក់ចេញនូវក្របខ័ណ្ឌវិនិយោគ ដូចខាងក្រោម ៖

**តារាងក្របខ័ណ្ឌវិនិយោគរយៈពេលប្រាំឆ្នាំរបស់រដ្ឋបាលខណ្ឌ**

| ល.រ | កម្មវិធីអភិវឌ្ឍន៍ | ឆ្លើយតបគោលដៅ | បរិយាយ | ឯកតា | លទ្ធផលប៉ាន់ស្មាន | | | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ២០.. | ២០.. | ២០.. | ២០.. | ២០.. | សរុប | |
| ក. ផ្នែកសេដ្ឋកិច្ច | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| ខ. ផ្នែកសង្គមកិច្ច | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| គ. ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| ឃ. ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |

**កំណត់សម្គាល់ ៖** កូឡោន "បរិយាយ" ផ្តោតលើឈ្មោះលទ្ធផលនានានៃកម្មវិធីអភិវឌ្ឍន៍នីមួយៗ។

### ខ). ក្របខ័ណ្ឌវិនិយោគរយៈពេលប្រាំឆ្នាំរបស់ការិយាល័យ អង្គភាពជំនាញនានា

ជាមួយគ្នានេះ ដើម្បីឆ្លើយតបទៅនឹងក្របខ័ណ្ឌអភិវឌ្ឍន៍ខណ្ឌ ក្នុងរយៈពេលប្រាំឆ្នាំនៃអាណត្តិរបស់ក្រុមប្រឹក្សា (ឆ្នាំ..... ដល់ឆ្នាំ....) ការិយាល័យ អង្គភាពជំនាញនានាដាក់ចេញនូវក្របខ័ណ្ឌវិនិយោគតាមវិស័យរបស់ខ្លួនដូចខាងក្រោម ៖

**តារាងក្របខ័ណ្ឌវិនិយោគរយៈពេលប្រាំឆ្នាំរបស់ការិយាល័យ អង្គភាពជំនាញ**

| ល.រ | កម្មវិធីអភិវឌ្ឍន៍ | ឆ្លើយតបគោលដៅ | បរិយាយ | ឯកតា | លទ្ធផលប៉ាន់ស្មាន | | | | | | ផ្នែក |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ២០.. | ២០.. | ២០.. | ២០.. | ២០.. | សរុប | |
| ១. ការិយាល័យ................. | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| ២. ការិយាល័យ................. | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| ៣. ការិយាល័យ................. | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| ៤. ការិយាល័យ................. | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |

**សម្គាល់ ៖** កូឡោន "ផ្នែក" ត្រូវបញ្ជាក់ថា កម្មវិធីអភិវឌ្ឍន៍នីមួយៗនោះស្ថិតក្នុងក្របខ័ណ្ឌនៃផ្នែកណាក្នុងចំណោមផ្នែកទាំង៤ ដូចខាងក្រោម ៖

- I. សំដៅលើ "ផ្នែកសេដ្ឋកិច្ច"
- II. សំដៅលើ "ផ្នែកសង្គមកិច្ច"
- III. សំដៅលើ "ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ"
- IV. សំដៅលើ "ផ្នែករដ្ឋបាល សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ"។

## ៣.២. ក្របខ័ណ្ឌផ្តល់សេវារដ្ឋបាល

ក្នុងរយៈពេលប្រាំឆ្នាំនៃអាណត្តិរបស់ក្រុមប្រឹក្សា រដ្ឋបាលខណ្ឌ និងការិយាល័យ អង្គភាពជំនាញនានានឹងផ្តល់សេវាជូនប្រជាពលរដ្ឋ ដោយរួមបញ្ចូលទាំងសេវានានាដែលរដ្ឋបាលខណ្ឌ និងការិយាល័យ អង្គភាពជំនាញនានាបាននិងកំពុងផ្តល់ជូនប្រជាពលរដ្ឋ និងមុខងារថ្មីៗបន្ថែមទៀតដែលរដ្ឋបាលខណ្ឌ ឬការិយាល័យ អង្គភាពជំនាញបានទទួល ឬនឹងបានទទួលពីក្រសួង ស្ថាប័ននានា។

### ក). ក្របខ័ណ្ឌផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលខណ្ឌ

**តារាងក្របខ័ណ្ឌផ្តល់សេវារដ្ឋបាលរយៈពេលប្រាំឆ្នាំរបស់រដ្ឋបាលខណ្ឌ**

| ល.រ | ប្រភេទសេវារដ្ឋបាល | ឯកតា | លទ្ធផលប៉ាន់ស្មាន | | | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| | | | ២០.. | ២០.. | ២០.. | ២០.. | ២០.. | សរុប | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |

ខ). ក្របខ័ណ្ឌផ្តល់សេវារបស់ការិយាល័យ អង្គភាពជំនាញនានាក្នុងខណ្ឌ

**តារាងក្របខ័ណ្ឌផ្តល់សេវារដ្ឋបាលរយៈពេលប្រាំឆ្នាំរបស់ការិយាល័យ អង្គភាពជំនាញ**

| ល.រ | ប្រភេទសេវារដ្ឋបាល | ឯកតា | លទ្ធផលប៉ាន់ស្មាន | | | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| | | | ២០.. | ២០.. | ២០.. | ២០.. | ២០.. | សរុប | |
| ១. ការិយាល័យ.................. | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| ២. ការិយាល័យ.................. | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| ៣. ការិយាល័យ.................. | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |

## ៣.៣. ការដាក់ចេញលិខិតបទដ្ឋានគតិយុត្តនានា

លិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋបាលខណ្ឌ ផ្តោតលើលិខិតបទដ្ឋានដែលមានឋានុក្រមខ្ពស់ដែលមានលក្ខណៈជាបទបញ្ជា ដូចជា ដីកា សេចក្តីសម្រេច សេចក្តីណែនាំ ជាដើម។

ដើម្បីឆ្លើយតបនឹងតម្រូវការ និងឱកាសអភិវឌ្ឍន៍ក្នុងមូលដ្ឋានក្នុងរយៈពេលប្រាំឆ្នាំនៃអាណត្តិរបស់ក្រុមប្រឹក្សាខណ្ឌ រដ្ឋបាលខណ្ឌគ្រោងនឹងដាក់ចេញលិខិតបទដ្ឋានគតិយុត្តនានាដូចខាងក្រោម ៖

**តារាងលិខិតបទដ្ឋានគតិយុត្ត**
**ដែលត្រូវរៀបចំ និងដាក់ឲ្យអនុវត្តសម្រាប់រយៈពេលប្រាំឆ្នាំរបស់រដ្ឋបាលខណ្ឌ**

| ល.រ | ប្រភេទលិខិត | ឯកតា | លទ្ធផលប៉ាន់ស្មាន | | | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| | | | ២០.. | ២០.. | ២០.. | ២០.. | ២០.. | សរុប | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |

## ៣.៤. ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម

ផ្អែកតាមទំហំនៃសូចនាករអភិវឌ្ឍន៍ដែលបានសរសេរខាងលើ ត្រូវធ្វើការគណនាប៉ាន់ស្មានអំពីតម្រូវការថវិកាចំណាយ។ ថវិកាចំណាយមានពីរផ្នែក គឺផ្នែកចំណាយចរន្ត និងផ្នែកចំណាយមូលធន។ ទោះបីជាថវិកាចំណាយនេះមិនទាន់មានលក្ខណៈត្រឹមត្រូវឥតខ្ចោះក៏ដោយ ក៏ថវិកាចំណាយនេះបង្ហាញឱ្យឃើញពីភាពម្ចាស់ការក្នុងកម្រិតណាមួយរបស់ខណ្ឌ នៅពេលបំប្លែងសូចនាករអភិវឌ្ឍន៍៥ឆ្នាំទៅជាទំហំនៃកម្មវិធីអភិវឌ្ឍន៍មូលដ្ឋាន។ សេចក្តីណែនាំលម្អិតសម្រាប់រៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យមនឹងធ្វើការណែនាំជាក្រោយ ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ជំពូកទី៤ ÷ ក្របខ័ណ្ឌតាមដាន និងវាយតម្លៃនៃការអនុវត្តផែនការអភិវឌ្ឍន៍ខណ្ឌ**

ការតាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ខណ្ឌ និងសមិទ្ធផលនៃការងារ នានាជាកិច្ចការចាំបាច់ និងមានសារៈសំខាន់ពុំអាចរំលងបានសម្រាប់ការងារគ្រប់គ្រងរបស់ក្រុមប្រឹក្សាខណ្ឌ។ ការតាមដាន គឺត្រូវធ្វើឡើងដើម្បីជំរុញឱ្យការងារអនុវត្តបានប្រព្រឹត្តទៅដល់គោលបំណងអភិវឌ្ឍន៍ដែលបានកំណត់ ហើយក៏ដើម្បីមានការសម្រេចចិត្ត (ផ្តល់ការលើកទឹកចិត្ត ឬកែតម្រូវជាចាំបាច់) ត្រង់ប្រការណាមួយដែលមិនសមស្រប។ ដូច្នេះ ក្នុងការសរសេរអំពីការតាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ខណ្ឌ ត្រូវរៀបរាប់អំពី ៖

៤.១. **យន្តការតាមដាន និងវាយតម្លៃ ៖** ត្រូវកំណត់ និងបរិយាយអំពីអង្គភាព ឬអ្នកទទួលបន្ទុកក្នុងការតាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍នេះ និងអង្គភាព ឬអ្នកទទួលបន្ទុកក្នុងការផ្តល់ព័ត៌មានពាក់ព័ន្ធតាមផ្នែក ឬវិស័យ ឬតាមគោលបំណង ឬតាមគោលដៅនីមួយៗឲ្យបានច្បាស់លាស់។

៤.២. **វិធីសាស្រ្តតាមដាន និងវាយតម្លៃ ៖** ត្រូវកំណត់ និងបរិយាយអំពីវិធីសាស្រ្តនានា ដែលត្រូវប្រើប្រាស់សម្រាប់ការតាមដាន និងវាយតម្លៃការសម្រេចបាននូវគោលដៅ គោលបំណង និងចក្ខុវិស័យអភិវឌ្ឍន៍ដែលបានកំណត់។

៤.៣. **សូចនាករតាមដាន និងវាយតម្លៃ ៖** គឺជាសូចនាករដែលមានក្នុងតារាងក្របខ័ណ្ឌអភិវឌ្ឍន៍ និងតារាងនានានៃកម្មវិធីអភិវឌ្ឍន៍មូលដ្ឋាន។ ដូច្នេះ ក្រុមការងារកសាងផែនការត្រូវស្រង់ចេញពីតារាងពាក់ព័ន្ធទាំងនោះ មកដាក់ក្នុងតារាងក្របខ័ណ្ឌតាមដាន និងវាយតម្លៃសម្រាប់ប្រើប្រាស់ជាខ្នាតសម្រាប់វាស់វែងអំពីវឌ្ឍនភាពនានា។

ក្រុមការងារកសាងផែនការខណ្ឌ ត្រូវរៀបចំតារាងក្របខ័ណ្ឌតាមដាន និងវាយតម្លៃតាមទម្រង់ដូចខាងក្រោម ៖

**តារាងក្របខ័ណ្ឌ**
**តាមដាន និងវាយតម្លៃការអនុវត្តក្របខ័ណ្ឌផែនការអភិវឌ្ឍន៍**

| គោលបំណង និងគោលដៅ | សូចនាករ | | | | អ្នកទទួលបន្ទុក | ប្រភពព័ត៌មាន | វិធីសាស្រ្ត |
|---|---|---|---|---|---|---|---|
| | ការបរិយាយ | ឯកតា | គ្រោង | ជាក់ស្តែង | | | |
| **១. ផ្នែកសេដ្ឋកិច្ច** | | | | | | | |
| **១.១. គោលបំណង ៖** | | | | | | | |
| ១.១.១. គោលដៅ ៖ | | | | | | | |
| ១.១.២. គោលដៅ ៖ | | | | | | | |
| **១.២. គោលបំណង ៖** | | | | | | | |
| ១.២.១. គោលដៅ ៖ | | | | | | | |
| ១.២.២. គោលដៅ ៖ | | | | | | | |
| **២. ផ្នែកសង្គមកិច្ច** | | | | | | | |
| **២.១. គោលបំណង ៖** | | | | | | | |

| គោលបំណង និងគោលដៅ | សូចនាករ | | | | អ្នកទទួលបន្ទុក | ប្រភពព័ត៌មាន | វិធីសាស្ត្រ |
|---|---|---|---|---|---|---|---|
| | ការបរិយាយ | ឯកតា | គ្រោង | ជាក់ស្តែង | | | |
| ២.១.១. គោលដៅ ៖ | | | | | | | |
| ២.១.២. គោលដៅ ៖ | | | | | | | |
| **៣. ផ្នែកគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងការបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុ** | | | | | | | |
| **៣.១. គោលបំណង ៖** | | | | | | | |
| ៣.១.១. គោលដៅ ៖ | | | | | | | |
| ៣.១.២. គោលដៅ ៖ | | | | | | | |
| **៤. ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ** | | | | | | | |
| **៤.១. គោលបំណង ៖** | | | | | | | |
| ៤.១.១. គោលដៅ ៖ | | | | | | | |
| ៤.១.២. គោលដៅ ៖ | | | | | | | |

## តារាងក្របខ័ណ្ឌតាមដាន និងវាយតម្លៃការអនុវត្តក្របខ័ណ្ឌវិនិយោគរយៈពេលប្រាំឆ្នាំ

| ល.រ | កម្មវិធីអភិវឌ្ឍន៍ | ឆ្លើយតបគោលដៅ | បរិយាយ | ឯកតា | គ្រោង | ជាក់ស្តែង | ប្រែប្រួល | អ្នកទទួលបន្ទុក | ប្រភពព័ត៌មាន | វិធីសាស្ត្រ |
|---|---|---|---|---|---|---|---|---|---|---|
| **១. សម្រាប់រដ្ឋបាលខណ្ឌ** | | | | | | | | | | |
| ក. ផ្នែកសេដ្ឋកិច្ច | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ខ. ផ្នែកសង្គមកិច្ច | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| គ. ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុ | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ឃ. ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| **២. សម្រាប់ការិយាល័យ អង្គភាពជំនាញ** | | | | | | | | | | |
| ក. ការិយាល័យ........ | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ខ. ការិយាល័យ..... | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| គ. ការិយាល័យ... | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |

តារាងក្របខ័ណ្ឌតាមដាន
និងវាយតម្លៃការអនុវត្តក្របខ័ណ្ឌផ្តល់សេវារដ្ឋបាល

| ល.រ | ប្រភេទសេវារដ្ឋបាល | ឯកតា | គ្រោង | ជាក់ស្តែង | ប្រែប្រួល | អ្នកទទួលបន្ទុក | ប្រភពព័ត៌មាន | វិធីសាស្រ្ត |
|---|---|---|---|---|---|---|---|---|
| **១. សម្រាប់រដ្ឋបាលខណ្ឌ** | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| **២. សម្រាប់ការិយាល័យ អង្គភាពជំនាញ** | | | | | | | | |
| ក. ការិយាល័យ........... | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| ខ. ការិយាល័យ............ | | | | | | | | |
| | | | | | | | | |
| | | | | | | | | |

តារាងក្របខ័ណ្ឌតាមដាន
និងវាយតម្លៃការអនុវត្តដាក់ចេញលិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋបាលខណ្ឌ

| ល.រ | ប្រភេទលិខិតបទដ្ឋានគតិយុត្ត | ឯកតា | គ្រោង | ជាក់ស្តែង | ប្រែប្រួល | អ្នកទទួលបន្ទុក | ប្រភពព័ត៌មាន | វិធីសាស្រ្ត |
|---|---|---|---|---|---|---|---|---|
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |

**ឧបសម្ព័ន្ធ**

# ផ្នែកទី៣
# វិធីសាស្ត្ររៀបចំ និង
# កសាងផែនការអភិវឌ្ឍន៍ខណ្ឌ

**ដំណើរប្រព្រឹត្តទៅនៃការរៀបចំ និងកសាង**
**ផែនការអភិវឌ្ឍន៍ខណ្ឌ ត្រូវអនុវត្តតាមបីជំហាន**

- ជំហានទី១ ៖ ការរៀបចំ និងផ្សព្វផ្សាយស្ដីពីការរៀបចំផែនការអភិវឌ្ឍន៍ខណ្ឌ
- ជំហានទី២ ៖ ការរៀបចំ និងចងក្រងសេចក្ដីព្រាងផែនការអភិវឌ្ឍន៍ខណ្ឌ
- ជំហានទី៣ ៖ ការពិនត្យ អនុម័ត និងផ្សព្វផ្សាយផែនការអភិវឌ្ឍន៍ខណ្ឌ

# ជំហានទី១
# ការរៀបចំ និងផ្សព្វផ្សាយស្តីពីការរៀបចំផែនការអភិវឌ្ឍន៍ខណ្ឌ

**គោលបំណង**

គោលបំណងនៃជំហាននេះ គឺដើម្បីរៀបចំឯកសារ និងព័ត៌មាននានាពាក់ព័ន្ធនឹងការកសាងផែនការអភិវឌ្ឍន៍ខណ្ឌ និងផ្សព្វផ្សាយអំពីការចាប់ផ្តើម និងដំណើរការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ខណ្ឌដល់អ្នកពាក់ព័ន្ធនានាឲ្យបានយល់ដឹង និងបានចូលរួមក្នុងដំណើរការនៃការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ខណ្ឌ។

**លទ្ធផលរំពឹងទុក**

លទ្ធផលរំពឹងទុក ដែលនឹងទទួលបានពីជំហានទី១ គឺ ៖

- បានរៀបចំឯកសារ និងព័ត៌មានពាក់ព័ន្ធនឹងការកសាងផែនការអភិវឌ្ឍន៍ ដែលមានដូចជា ៖
  - ប្រតិទិនការងារសម្រាប់ការកសាងផែនការអភិវឌ្ឍន៍ខណ្ឌ
  - គោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សាខណ្ឌ ដោយផ្អែកលើការវិភាគស្ថានភាពខណ្ឌ និង
  - ឯកសារពាក់ព័ន្ធផ្សេងៗ ដូចជា ឯកសារព័ត៌មានស្ថានភាពខណ្ឌ ពិន្ទុវិស័យ ទិន្នន័យតាមវិស័យ ផែនទី...។ល។
- អ្នកពាក់ព័ន្ធនានាបានយល់ដឹងកាន់តែប្រសើរឡើងអំពីគោលការណ៍ណែនាំផ្នែកគោលនយោបាយ ប្រតិទិនការងារ និងដំណើរការនៃការរៀបចំកសាងផែនការអភិវឌ្ឍន៍ខណ្ឌ និងរបៀបដែលអ្នកពាក់ព័ន្ធនីមួយៗអាចចូលរួមក្នុងកិច្ចដំណើរការនេះ។

**ដំណើរការ**

ការរៀបចំ និងប្រជុំផ្សព្វផ្សាយអំពីការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ខណ្ឌមានបីដំណាក់កាលដូចខាងក្រោម ៖

១.១. ដំណាក់កាលមុនពេលកិច្ចប្រជុំផ្សព្វផ្សាយ

១.២. ដំណាក់កាលក្នុងអំឡុងពេលកិច្ចប្រជុំផ្សព្វផ្សាយ

១.៣. ដំណាក់កាលក្រោយពេលកិច្ចប្រជុំផ្សព្វផ្សាយ

## ១.១. ដំណាក់កាលមុនកិច្ចប្រជុំផ្សព្វផ្សាយ

មុនពេលរៀបចំកិច្ចប្រជុំផ្សព្វផ្សាយ ក្រុមការងារកសាងផែនការខណ្ឌ ត្រូវ ៖

- ការរៀបចំសេចក្តីព្រាងប្រតិទិនការងារ
- ការរៀបចំសេចក្តីព្រាងគោលការណ៍ណែនាំផ្នែកគោលនយោបាយ
- ការពិនិត្យ និងផ្តល់យោបល់សេចក្តីព្រាងប្រតិទិនការងារ និងសេចក្តីព្រាងគោលការណ៍ណែនាំផ្នែកគោលនយោបាយ
- ការពិនិត្យ និងអនុម័តសេចក្តីព្រាងប្រតិទិនការងារ និងសេចក្តីព្រាងគោលការណ៍ណែនាំផ្នែកគោលនយោបាយ
- ការរៀបចំឯកសារពាក់ព័ន្ធនានា។

### ក). ការរៀបចំសេចក្តីព្រាងប្រតិទិនការងារសម្រាប់ការកសាងផែនការអភិវឌ្ឍន៍ខណ្ឌ

ដើម្បីមានផែនការសកម្មភាពច្បាស់លាស់សម្រាប់ការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ខណ្ឌ ក្រុមការងារកសាងផែនការខណ្ឌ ត្រូវរៀបចំសេចក្តីព្រាងប្រតិទិនការងារឲ្យបានគ្រប់ជ្រុងជ្រោយ ដោយត្រូវឆ្លុះបញ្ចាំងអំពីសកម្មភាព ពេលវេលា ទីកន្លែង អ្នកទទួលខុសត្រូវ និងធនធានដែលត្រូវការចាំបាច់ (តារាង១.១.)។

### ខ). ការរៀបចំសេចក្តីព្រាងគោលការណ៍ណែនាំផ្នែកគោលនយោបាយ

ក្រុមការងារកសាងផែនការខណ្ឌ ត្រូវរៀបចំសេចក្តីព្រាងគោលការណ៍ណែនាំផ្នែកគោលនយោបាយ ដើម្បីដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត។ គោលការណ៍ណែនាំផ្នែកគោលនយោបាយ គឺជាលិខិតបទដ្ឋានគតិយុត្តរបស់ក្រុមប្រឹក្សាខណ្ឌសម្រាប់ណែនាំដល់ក្រុមការងារកសាងផែនការខណ្ឌ និងអ្នកពាក់ព័ន្ធនានាក្នុងខណ្ឌឲ្យចូលរួមរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលខណ្ឌ និងធានាឲ្យផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលខណ្ឌមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដែលគ្របដណ្តប់លើគ្រប់វិស័យអាទិភាព ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង មានសង្គតិភាពជាមួយគោលនយោបាយជាតិ និងស្របតាមសក្តានុពលនានាដែលខណ្ឌមាន ដើម្បីអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងធ្វើឱ្យប្រសើរឡើងនូវគុណភាពជីវិត និងសុខុមាលភាពប្រជាពលរដ្ឋ ពិសេសស្ត្រី កុមារ យុវជន ជនពិការ និងជនងាយរងគ្រោះផ្សេងៗទៀតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។

ក្នុងការរៀបចំសេចក្តីព្រាងគោលការណ៍ណែនាំផ្នែកគោលនយោបាយនេះ ក្រុមការងារកសាងផែនការខណ្ឌត្រូវ ៖

- ពិនិត្យមើលក្របខ័ណ្ឌច្បាប់ គោលនយោបាយជាតិ គោលនយោបាយរាជធានី និងលិខិតបទដ្ឋានគតិយុត្តនានា ដូចជា យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់រាជរដ្ឋាភិបាល ។ល។
- ពិនិត្យមើលស្ថានភាពជាក់ស្តែងរបស់ខណ្ឌតាមរយៈឯកសារព័ត៌មានស្ថានភាពខណ្ឌ ពិន្ទុវិស័យ របាយការណ៍នានា និងទិន្នន័យផ្សេងៗទៀតដែលមាន
- កំណត់អំពីបញ្ហាប្រឈមនានាដែលខណ្ឌកំពុងជួបប្រទះ សក្តានុពលនានាដែលខណ្ឌមាន និងវិធីសាស្ត្រ ឬមធ្យោបាយនានា ដែលខណ្ឌអាចចាត់វិធានការដោះស្រាយបាន
- កំណត់អំពីចក្ខុវិស័យ សកម្មភាព ឬវិស័យជាអាទិភាព ដែលខណ្ឌត្រូវយកចិត្តទុកដាក់អនុវត្តសម្រាប់រយៈពេលប្រាំឆ្នាំនៃអាណត្តិរបស់ក្រុមប្រឹក្សា
- ការរៀបចំសេចក្តីព្រាងគោលការណ៍ណែនាំផ្នែកគោលនយោបាយ (ឧបសម្ព័ន្ធទី១)។

### គ). ការពិនិត្យ និងផ្តល់យោបល់

បន្ទាប់ពីរៀបចំសេចក្តីព្រាងប្រតិទិនការងារ និងគោលការណ៍ណែនាំផ្នែកគោលនយោបាយរួច ក្រុមការងារកសាងផែនការខណ្ឌត្រូវ ៖

- ដាក់ជូនសេចក្តីព្រាងទាំងពីរខាងលើទៅគណៈអភិបាល និងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសដើម្បីពិនិត្យ និងផ្តល់យោបល់
- កែសម្រួលសេចក្តីព្រាងទាំងនេះ ផ្អែកតាមមតិយោបល់របស់គណៈអភិបាល និងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
- បញ្ជូនសេចក្តីព្រាងដែលបានកែសម្រួលទៅក្រុមប្រឹក្សាដើម្បីពិនិត្យ អនុម័ត។

**ឃ). ការពិនិត្យ និងអនុម័ត**

- បន្ទាប់ពីទទួលបានសេចក្តីព្រាងប្រតិទិនការងារ និងគោលការណ៍ណែនាំផ្នែកគោលនយោបាយ ប្រធានក្រុមប្រឹក្សាខណ្ឌរៀបចំកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួន ដើម្បីពិនិត្យ និងអនុម័តសេចក្តីព្រាងទាំងពីរនេះ។
- កិច្ចប្រជុំពិនិត្យ និងអនុម័តសេចក្តីព្រាងប្រតិទិន និងគោលការណ៍ណែនាំផ្នែកគោលនយោបាយត្រូវអនុវត្តតាមបទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាខណ្ឌ។

**ង). ការរៀបចំឯកសារពាក់ព័ន្ធនានា**

ជាមួយគ្នានេះ ក្រុមការងារកសាងផែនការខណ្ឌ ត្រូវរៀបចំឯកសារផ្សេងៗទៀត ដែលពាក់ព័ន្ធនឹងការកសាងផែនការអភិវឌ្ឍន៍ខណ្ឌ ដែលមានដូចជា ឯកសារព័ត៌មានស្ថានភាពខណ្ឌ ទិន្នន័យតាមវិស័យ ផែនទី...។ល។

## ១.២. ដំណាក់កាលក្នុងអំឡុងពេលកិច្ចប្រជុំផ្សព្វផ្សាយ

**ក). សមាសភាពចូលរួម**

សមាសភាពអ្នកពាក់ព័ន្ធសំខាន់ៗ ដែលចូលរួមក្នុងកិច្ចប្រជុំផ្សព្វផ្សាយអំពីការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ខណ្ឌ រួមមាន ៖

- តំណាងក្រុមប្រឹក្សាខណ្ឌ
- តំណាងគណៈកម្មាធិការពាក់ព័ន្ធនានា
- អភិបាល អភិបាលរងខណ្ឌ
- ក្រុមការងារកសាងផែនការខណ្ឌ
- គ្រប់ការិយាល័យចំណុះរដ្ឋបាលខណ្ឌ
- ចៅសង្កាត់ក្នុងខណ្ឌ
- ប្រធាន ឬតំណាងការិយាល័យ អង្គភាពជំនាញនានាក្នុងខណ្ឌ
- តំណាងអង្គការសង្គមស៊ីវិលនានាក្នុងខណ្ឌ
- តំណាងវិស័យឯកជនសំខាន់ៗក្នុងខណ្ឌ
- អ្នកពាក់ព័ន្ធផ្សេងទៀតតាមការចាំបាច់។

**ខ). របៀបវារៈនៃកិច្ចប្រជុំផ្សព្វផ្សាយ**

របៀបវារៈសំខាន់ៗនៃកិច្ចប្រជុំផ្សព្វផ្សាយនេះ រួមមាន ៖

- ការបង្ហាញអំពី ៖

- ខ្លឹមសារសំខាន់នៃលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការកសាងផែនការអភិវឌ្ឍន៍របស់ក្រុមប្រឹក្សាខណ្ឌ
- គោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សា
- ប្រតិទិនការងារ និងដំណើរការនៃការរៀបចំផែនការអភិវឌ្ឍន៍ខណ្ឌ
- របៀបវិភាគព័ត៌មាន និងបំពេញទម្រង់តារាងនានា

• ការពិភាក្សា និងការផ្ដល់យោបល់នានា

• បញ្ហាផ្សេងៗ។

**គ). ដំណើរការប្រជុំ**

ដោយផ្អែកតាមរបៀបវារៈដែលបានកំណត់ អភិបាលខណ្ឌដឹកនាំកិច្ចប្រជុំផ្សព្វផ្សាយនេះ។ បន្ទាប់ពីពិធីបើកកិច្ចប្រជុំ និងដោយមានការអនុញ្ញាតពីប្រធានអង្គប្រជុំ តំណាងក្រុមការងារកសាងផែនការខណ្ឌត្រូវធ្វើបទបង្ហាញអំពី ៖

• ខ្លឹមសារសំខាន់នៃលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការកសាងផែនការអភិវឌ្ឍន៍របស់ក្រុមប្រឹក្សាខណ្ឌ
• ខ្លឹមសារសំខាន់នៃគោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សា
• ដំណើរការនៃការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ខណ្ឌ
• ប្រតិទិនការងារសម្រាប់ការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ខណ្ឌ
• វិធីសាស្ត្រវិភាគស្ថានភាព (ឧបសម្ព័ន្ធទី២)
• វិធីសាស្ត្រចាត់អាទិភាព (ឧបសម្ព័ន្ធទី៣)
• របៀបបំពេញតារាង ១.២. តារាងវិភាគស្ថានភាពរបស់អ្នកពាក់ព័ន្ធ
• របៀបបំពេញទម្រង់ជាតុចូលអំពីកម្មវិធីអភិវឌ្ឍន៍មូលដ្ឋាន (ទម្រង់ទី១) ដោយបញ្ជាក់ជូនតំណាងរដ្ឋបាលខណ្ឌ រដ្ឋបាលសង្កាត់ ការិយាល័យ អង្គភាពនានាថា ទម្រង់ទី១នេះ នឹងត្រូវបំពេញតាមក្រោយ បន្ទាប់ពីទទួលបានការជូនដំណឹងពីក្រុមការងារកសាងផែនការខណ្ឌ
• កាលបរិច្ឆេទបញ្ជូនតារាង១.២. មកឲ្យក្រុមការងារកសាងផែនការខណ្ឌវិញ។

បន្ទាប់ពីបង្ហាញខ្លឹមសារខាងលើហើយ ប្រធានកិច្ចប្រជុំផ្សព្វផ្សាយត្រូវផ្ដល់ឱកាសឲ្យអ្នកចូលរួមសួរសំណួរនានា និងត្រូវឆ្លើយបំភ្លឺឲ្យបានសមស្រប។

## ១.៣. ដំណាក់កាលក្រោយពេលកិច្ចប្រជុំផ្សព្វផ្សាយ

សកម្មភាពចម្បងៗនានា ដែលត្រូវអនុវត្តបន្ទាប់បានពីចូលរួមកិច្ចប្រជុំផ្សព្វផ្សាយនៅថ្នាក់ខណ្ឌរួមមាន ៖

• នាយករដ្ឋបាលខណ្ឌ ត្រូវរៀបចំកិច្ចប្រជុំជាមួយការិយាល័យទាំងអស់ ដើម្បីកំណត់បញ្ហា តម្រូវការ និងដំណោះស្រាយនានា ដើម្បីរៀបចំបំពេញតារាង១.២. តាមការណែនាំរបស់ក្រុមការងារកសាងផែនការខណ្ឌ។

- ប្រធានការិយាល័យ អង្គភាពជំនាញ អង្គការសង្គមស៊ីវិល វិស័យឯកជន និងអ្នកពាក់ព័ន្ធផ្សេងទៀតធ្វើការវិភាគស្ថានភាពពាក់ព័ន្ធនឹងវិស័យជំនាញ និងឬពាក់ព័ន្ធនឹងដែនសមត្ថកិច្ចរបស់ខ្លួន ដោយប្រើប្រាស់វិធីសាស្ត្រដូចមានក្នុងឧបសម្ព័ន្ធទី២ និងវិធីសាស្ត្រផ្សេងៗទៀតតាមស្ថានភាព និងលទ្ធភាពជាក់ស្តែង ដោយត្រូវកំណត់ឲ្យបាននូវបញ្ហា មូលហេតុ និងដំណោះស្រាយសមស្របនានា។ ក្នុងករណីបញ្ហា ឬមូលហេតុ ឬដំណោះស្រាយដែលបានកំណត់មានចំនួនច្រើនពេក អ្នកវិភាគត្រូវចាត់អាទិភាពឲ្យបានសមស្រប (ឧបសម្ព័ន្ធទី៣)។
- ចំពោះរដ្ឋបាលសង្កាត់ ចៅសង្កាត់ត្រូវដឹកនាំ គ.ផ.ថ របស់ខ្លួន ដើម្បីធ្វើសុពលភាពឡើងវិញនូវបញ្ហា តម្រូវការ និងដំណោះស្រាយនានា ដែលសង្កាត់បានរកឃើញកន្លងមក ដើម្បីបំពេញតារាង១.២.របស់ខណ្ឌ តាមការណែនាំរបស់ក្រុមការងាររកសាងផែនការខណ្ឌ។
- ដោយផ្អែកលើលទ្ធផលនៃការវិភាគស្ថានភាព តំណាងការិយាល័យ អង្គភាពជំនាញ រដ្ឋបាលសង្កាត់ អង្គការសង្គមស៊ីវិល វិស័យឯកជន និងអ្នកពាក់ព័ន្ធនីមួយៗត្រូវបំពេញព័ត៌មានចូលក្នុងតារាង១.២. រួចបញ្ជូនមកក្រុមការងាររកសាងផែនការខណ្ឌ តាមកាលបរិច្ឆេទដែលបានកំណត់។
- បន្ទាប់ពីទទួលបានតារាងវិភាគស្ថានភាពពីអ្នកពាក់ព័ន្ធ ក្រុមការងាររកសាងផែនការត្រូវពិនិត្យ និងបូកសរុបចូលទៅក្នុងតារាងបូកសរុបការវិភាគស្ថានភាពខណ្ឌ (តារាង១.៣.)។ ជាមួយគ្នានេះ ក្រុមការងាររកសាងផែនការខណ្ឌពិនិត្យ ពិភាក្សាក្នុងក្រុមការងាររបស់ខ្លួន ដើម្បីបំពេញបន្ថែមនូវបញ្ហា មូលហេតុ និងដំណោះស្រាយនានាផ្សេងៗទៀត តាមការចាំបាច់។

**កំណត់សម្គាល់** ៖ ដោយផ្អែកតាមតារាង១.៣.របស់ខណ្ឌ ក្រុមការងាររកសាងផែនការខណ្ឌ ត្រូវរៀបចំបំពេញតារាង១.២.របស់រាជធានី (តាមការណែនាំរបស់រាជធានី) ហើយត្រូវបញ្ជូនតារាង១.២.របស់រាជធានីនេះទៅឲ្យក្រុមការងាររកសាងផែនការរាជធានីឲ្យបានតាមកាលបរិច្ឆេទដែលបានកំណត់។

**តារាង ១.១ ៖ ប្រតិទិនការងារសម្រាប់ដំណើរការរកសាងផែនការអភិវឌ្ឍន៍ខណ្ឌ**

| ល.រ | សកម្មភាព | ពេលវេលា | ទីកន្លែង | អ្នកទទួលខុសត្រូវ | ថវិកា | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

ប្រតិទិនការងារសម្រាប់កសាងផែនការអភិវឌ្ឍន៍ខណ្ឌខាងលើនេះ បានទទួលការអនុម័តពីក្រុមប្រឹក្សាខណ្ឌនៅក្នុងកិច្ចប្រជុំ.......................លើកទី..................នាថ្ងៃទី............ខែ............ឆ្នាំ.....................។

**ប្រធានក្រុមប្រឹក្សាខណ្ឌ**

## តារាង ១.២ ៖ ការវិភាគស្ថានភាពរបស់អ្នកពាក់ព័ន្ធ

អង្គភាពស្នើ៖_______________ កាលបរិច្ឆេទ៖____________

| ល.រ | បញ្ហា | មូលហេតុ | ដំណោះស្រាយ | ផ្សេងៗ |
|---|---|---|---|---|
| ផ្នែកសេដ្ឋកិច្ច | | | | |
| | | | | |
| | | | | |
| ផ្នែកសង្គមកិច្ច | | | | |
| | | | | |
| | | | | |
| ផ្នែកគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ | | | | |
| | | | | |
| | | | | |
| ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ | | | | |
| | | | | |
| | | | | |

ថ្ងៃទី................. ខែ............. ឆ្នាំ២០..........

**អ្នករៀបចំតារាង**

បានឃើញ និងឯកភាព

ថ្ងៃទី................. ខែ............. ឆ្នាំ២០..........

**ប្រធានអង្គភាព....**

## តារាង ១.៣ ៖ ការបូកសរុបការវិភាគស្ថានភាពខណ្ឌ

| ល.រ | បញ្ហា | មូលហេតុ | ដំណោះស្រាយ | អង្គភាពស្នើ |
|---|---|---|---|---|
| ផ្នែកសេដ្ឋកិច្ច | | | | |
| | | | | |
| | | | | |
| ផ្នែកសង្គមកិច្ច | | | | |
| | | | | |
| | | | | |
| ផ្នែកគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ | | | | |
| | | | | |
| | | | | |
| ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ | | | | |
| | | | | |
| | | | | |

# ទម្រង់ទី១ ÷ ធាតុចូលអំពីកម្មវិធីអភិវឌ្ឍន៍មូលដ្ឋាន

អង្គភាព៖_______________ កាលបរិច្ឆេទ៖_____________

## តារាងក្របខ័ណ្ឌវិនិយោគរយៈពេលប្រាំឆ្នាំ

| ល.រ | កម្មវិធីអភិវឌ្ឍន៍ | ឆ្លើយតបគោលដៅ | បរិយាយ | ឯកតា | លទ្ធផលប៉ាន់ស្មាន | | | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ២០.. | ២០.. | ២០.. | ២០.. | ២០.. | សរុប | |
| ក. ផ្នែកសេដ្ឋកិច្ច | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| ខ. ផ្នែកសង្គមកិច្ច | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| គ. ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| ឃ. ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |

## តារាងក្របខ័ណ្ឌផ្តល់សេវាសម្រាប់រយៈពេលប្រាំឆ្នាំ

| ល.រ | ប្រភេទសេវារដ្ឋបាល | ឯកតា | លទ្ធផលប៉ាន់ស្មាន | | | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| | | | ២០.. | ២០.. | ២០.. | ២០.. | ២០.. | សរុប | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |

## តារាងលិខិតបទដ្ឋានគតិយុត្ត
## ដែលត្រូវរៀបចំ និងដាក់ឲ្យអនុវត្តសម្រាប់រយៈពេលប្រាំឆ្នាំ (សម្រាប់តែរដ្ឋបាលខណ្ឌ សង្កាត់)

| ល.រ | ប្រភេទលិខិត | ឯកតា | លទ្ធផលប៉ាន់ស្មាន | | | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| | | | ២០.. | ២០.. | ២០.. | ២០.. | ២០.. | សរុប | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |

ថ្ងៃទី................. ខែ............. ឆ្នាំ២០..........

**អ្នករៀបចំតារាង**

បានឃើញ និងឯកភាព

ថ្ងៃទី................. ខែ............. ឆ្នាំ២០..........

**ប្រធានអង្គភាព....**

# ជំហានទី២

# ការរៀបចំ និងចងក្រងសេចក្តីព្រាងផែនការអភិវឌ្ឍន៍ខណ្ឌ

## គោលបំណង

គោលបំណងនៃជំហានទី២នេះ គឺដើម្បីរៀបចំ និងចងក្រងសេចក្តីព្រាងផែនការអភិវឌ្ឍន៍ខណ្ឌ ដែលឆ្លុះបញ្ចាំងពីតម្រូវការអភិវឌ្ឍន៍របស់មូលដ្ឋាន និងស្របតាមគោលនយោបាយជាតិ។

## លទ្ធផលរំពឹងទុក

លទ្ធផលរំពឹងទុកដែលនឹងសម្រេចបានគឺ សេចក្តីព្រាងផែនការអភិវឌ្ឍន៍ខណ្ឌ ដែលបានរៀបចំរួចរាល់បានដាក់ជូនក្រុមប្រឹក្សាខណ្ឌពិនិត្យ និងអនុម័ត។

## ដំណើរការ

ការអនុវត្តជំហានទី២នេះ មានពីរដំណាក់កាល ដែលមានសកម្មភាពសំខាន់ៗដូចខាងក្រោម ៖

**ដំណាក់កាលទី១**

២.១. ការវិភាគស្ថានភាពខណ្ឌ

២.២. ការរៀបចំសេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍ខណ្ឌ

២.៣. ការរៀបចំកម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរយៈពេលប្រាំឆ្នាំ

២.៤. ការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម

២.៥. ការពិនិត្យ និងផ្តល់យោបល់របស់គណៈអភិបាលខណ្ឌ

២.៦. ការពិនិត្យ និងសម្រេចលើសេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍ កម្មវិធីអភិវឌ្ឍន៍មូលដ្ឋាន

២.៧. ការរៀបចំក្របខ័ណ្ឌតាមដាន និងវាយតម្លៃ

២.៨. ការរៀបចំខ្លឹមសារស្ថានភាពសេដ្ឋកិច្ច សង្គមរបស់ខណ្ឌ

**ដំណាក់កាលទី២**

២.៩. ការចងក្រងសេចក្តីព្រាងសៀវភៅផែនការអភិវឌ្ឍន៍ខណ្ឌ

២.១០. កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ខណ្ឌ

២.១១. ការពិនិត្យ និងផ្តល់យោបល់

## ដំណាក់កាលទី១

## ២.១. ការវិភាគស្ថានភាពខណ្ឌ

បន្ទាប់ពីបូកសរុបជាតុចូលពីអ្នកពាក់ព័ន្ធ (តារាង១.៣.) រួច ក្រុមការងារកសាងផែនការខណ្ឌត្រូវរៀបចំប្រជុំវិភាគស្ថានភាពខណ្ឌ ដោយមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់ (សមាសភាពដូចជំហានទី១ខាងលើ)។ នៅក្នុងការប្រជុំវិភាគនេះ ក្រុមការងារកសាងផែនការខណ្ឌ ត្រូវ ៖

- ចែកតារាង១.៣. ឲ្យអ្នកចូលរួម ដើម្បីជាឯកសារយោងសម្រាប់ពិភាក្សា
- បែងចែកអ្នកចូលរួមជាក្រុមតូចៗ ដូចជា ៖

- ក្រុមទី១ ៖ ពិនិត្យ និងវិភាគស្ថានភាពសេដ្ឋកិច្ច ដោយផ្តោតលើអាជីវកម្ម កសិកម្ម ឧស្សាហកម្ម គមនាគមន៍ សេវាកម្ម ការវិនិយោគ ជាដើម
- ក្រុមទី២ ៖ ពិនិត្យ និងវិភាគស្ថានភាពសង្គមកិច្ច ដោយផ្តោតលើការងារអប់រំ សុខាភិបាល យេនឌ័រ ភាពក្រីក្រ សាសនា អន្តោប្រវេសន៍ និងចំណាកស្រុក ជាដើម
- ក្រុមទី៣ ៖ ពិនិត្យ និងវិភាគស្ថានភាពគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និង ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ដោយផ្តោតលើការប្រើប្រាស់ដីធ្លី ធនធានធម្មជាតិ បរិស្ថាន គ្រោះមហន្តរាយចម្បងៗ ការប្រែប្រួលអាកាសធាតុ ជាដើម
- ក្រុមទី៤ ៖ ពិនិត្យ និងវិភាគស្ថានភាពការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ដោយផ្តោតលើអភិបាលកិច្ច ការគ្រប់គ្រងដែនដី ការគ្រប់គ្រងស្ថិតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ការងារព្រំដែន។ល។

- ណែនាំឲ្យក្រុមពិភាក្សានីមួយៗធ្វើការពិភាក្សា វិភាគស្ថានភាព (ឧបសម្ព័ន្ធទី២ ៖ វិធីសាស្ត្រវិភាគស្ថានភាព) និងឯកភាពលើការចាត់អាទិភាពអំពីបណ្តាបញ្ហាប្រឈមដែលកំពុងកើតមាន និង ឬអាចនឹងកើតមាន មូលហេតុ និងដំណោះស្រាយនានាដែលអាចអនុវត្តបាននៅក្នុងអាណត្តិរបស់ក្រុមប្រឹក្សា។ ក្នុងការវិភាគនេះ ក្រុមនីមួយៗត្រូវយកចិត្តទុកដាក់ចំពោះតម្រូវការរបស់ស្ត្រី កុមារ យុវជន ជនពិការ និងជនងាយរងគ្រោះផ្សេងៗទៀត ព្រមទាំងបញ្ហាយេនឌ័រ និងការប្រែប្រួលអាកាសធាតុផងដែរ។
- បន្ទាប់មក ក្រុមពិភាក្សានីមួយៗត្រូវពិនិត្យចាត់អាទិភាព និងត្រូវស្រង់លទ្ធផលនៃការពិភាក្សានេះទៅក្នុងតារាងលទ្ធផលក្រុមវិភាគស្ថានភាពខណ្ឌតាមលំដាប់អាទិភាព (តារាង ២.១ )។
- ក្រុមការងារកសាងផែនការស្នើឲ្យតំណាងក្រុមនីមួយៗ បង្ហាញអំពីលទ្ធផលនៃការពិភាក្សា និងស្នើឲ្យអ្នកចូលរួមផ្សេងទៀតផ្តល់យោបល់ ដើម្បីបំពេញបន្ថែម។
- ក្រុមការងារកសាងផែនការប្រមូល និងកត់ត្រារាល់មតិយោបល់ និងលទ្ធផលពិភាក្សា សម្រាប់ប្រើប្រាស់ជាធាតុចូលក្នុងការរៀបចំក្របខ័ណ្ឌអភិវឌ្ឍន៍ខណ្ឌ។

## ២.២. ការរៀបចំសេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍ខណ្ឌ

ដោយផ្អែកតាមគោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សា និងធាតុចូលដែលទទួលបានពីកិច្ចប្រជុំវិភាគស្ថានភាពខណ្ឌ ក្រុមការងារកសាងផែនការខណ្ឌត្រូវ ៖

- រៀបចំ និងសរសេរចក្ខុវិស័យអភិវឌ្ឍន៍ខណ្ឌសម្រាប់អាណត្តិរបស់ក្រុមប្រឹក្សា។ ចក្ខុវិស័យនេះគួរសរសេរឲ្យមានលក្ខណៈទូលំទូលាយ អាចអនុវត្តបានក្នុងអាណត្តិរបស់ក្រុមប្រឹក្សា និងជាទស្សនៈរួមសម្រាប់ចង្អុលទិសដល់កិច្ចអភិវឌ្ឍន៍ក្នុងខណ្ឌ។
- បំប្លែងបញ្ហា មូលហេតុ និងដំណោះស្រាយដែលបានកំណត់ ទៅជាគោលបំណង គោលដៅ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍។

- ស្រង់ ចក្ខុវិស័យ គោលបំណង គោលដៅ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍បញ្ចូលក្នុងតារាងក្របខ័ណ្ឌអភិវឌ្ឍន៍ខណ្ឌ (តារាង២.២)។
- ពិនិត្យ កែសម្រួល និងរៀបចំបញ្ចប់សេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍ខណ្ឌ ដើម្បីដាក់ជូនគណៈអភិបាលពិនិត្យ និងផ្តល់យោបល់។

## ២.៣. ការរៀបចំកម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរយៈពេលប្រាំឆ្នាំ

ក). **ការជូនដំណឹង ៖** ដើម្បីរៀបចំកម្មវិធីអភិវឌ្ឍន៍មូលដ្ឋាន ក្រុមការងារកសាងផែនការខណ្ឌត្រូវជូនដំណឹងទៅរដ្ឋបាលខណ្ឌ រដ្ឋបាលសង្កាត់ក្នុងខណ្ឌ និងការិយាល័យ អង្គភាពជំនាញនានាឲ្យរៀបចំ និងបំពេញជាតុចូល (ទម្រង់ទី១) ដោយភ្ជាប់ជាមួយសេចក្តីព្រាងតារាងក្របខ័ណ្ឌអភិវឌ្ឍន៍ខណ្ឌដែលបានរៀបចំខាងលើ និងកាលបរិច្ឆេទ ដែលត្រូវបញ្ជូនមកឲ្យក្រុមការងារកសាងផែនការខណ្ឌវិញ។

ខ). **ការរៀបចំកម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរយៈពេលប្រាំឆ្នាំរបស់រដ្ឋបាលខណ្ឌ ៖** អភិបាលខណ្ឌ ដោយមាននាយករដ្ឋបាលខណ្ឌ និងការិយាល័យនានាជាជំនួយការ ត្រូវរៀបចំកម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរយៈពេលប្រាំឆ្នាំរបស់រដ្ឋបាលខណ្ឌ ដើម្បី ៖

- **កំណត់ក្របខ័ណ្ឌវិនិយោគ** ដោយត្រូវ ៖
  - ផ្អែកលើតារាងក្របខ័ណ្ឌអភិវឌ្ឍន៍ខណ្ឌ ដែលបានរៀបចំ
  - ព្យាករណ៍អំពីលទ្ធភាពធនធានថវិកា ធនធានមនុស្ស និងធនធានផ្សេងៗទៀតដែលខ្លួនមាន ឬអាចនឹងមានសម្រាប់រយៈពេលប្រាំឆ្នាំ
  - កំណត់របៀបវារៈ ឬកម្មវិធីនៃការអភិវឌ្ឍន៍មូលដ្ឋាន និងចាត់អាទិភាព ដោយត្រូវជ្រើសរើសយករបៀបវារៈនៃកិច្ចអភិវឌ្ឍន៍មូលដ្ឋាននានា ស្របតាមការព្យាករណ៍អំពីលទ្ធភាពធនធានដែលខណ្ឌអាចមានសម្រាប់រយៈពេលប្រាំឆ្នាំ ព្រមទាំងកំណត់សូចនាករ និងក្របខ័ណ្ឌពេលវេលានៃការអនុវត្ត ដោយត្រូវបំពេញចូលក្នុងតារាងក្របខ័ណ្ឌវិនិយោគ (តារាង "ក្របខ័ណ្ឌវិនិយោគ" នៃទម្រង់ទី១)។
- **ការកំណត់ក្របខ័ណ្ឌផ្តល់សេវារដ្ឋបាល** ដោយត្រូវ ៖
  - ផ្អែកលើប្រភេទសេវារដ្ឋបាល និងចំនួនសេវារដ្ឋបាលដែលបាននិងកំពុងផ្តល់ជូនប្រជាពលរដ្ឋ
  - ផ្អែកលើមុខងារ និងធនធានដែលបាននិងកំពុងផ្ទេរឲ្យរដ្ឋបាលខណ្ឌ និងមុខងារដែលគ្រោងនឹងផ្ទេរឲ្យរដ្ឋបាលខណ្ឌ
  - ធ្វើការប៉ាន់ប្រមាណអំពីប្រភេទ និងបរិមាណនៃសេវារដ្ឋបាលនានាទាំងនោះសម្រាប់រយៈពេលប្រាំឆ្នាំនៃអាណត្តិរបស់ក្រុមប្រឹក្សា ដោយបែងចែកតាមឆ្នាំនីមួយៗ។
  - បំពេញតារាងក្របខ័ណ្ឌផ្តល់សេវារដ្ឋបាល (តារាង "ក្របខ័ណ្ឌផ្តល់សេវា" នៃទម្រង់ទី១)

- **ការកំណត់ការដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្តនានា** ដោយត្រូវ ៖
  - ផ្អែកលើប្រភេទលិខិតបទដ្ឋានគតិយុត្ត (ដីកា សេចក្ដីសម្រេច សេចក្ដីណែនាំ....) ដែលបានរៀបចំ និងដាក់ឲ្យអនុវត្តនាពេលបច្ចុប្បន្ន
  - ពិនិត្យមើលលើបញ្ហាប្រឈម និងតម្រូវការនៃការដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្តសម្រាប់បម្រើដល់សេចក្ដីត្រូវការរបស់ប្រជាពលរដ្ឋ និងការធានាបាននូវការផ្ដល់សេវា និងការអភិវឌ្ឍន៍មូលដ្ឋានប្រកបដោយនិរន្តរភាព
  - ធ្វើការប៉ាន់ប្រមាណអំពីប្រភេទលិខិតបទដ្ឋានគតិយុត្ត និងបរិមាណនៃលិខិតបទដ្ឋានគតិយុត្តនានាទាំងនោះសម្រាប់រយៈពេលប្រាំឆ្នាំនៃអាណត្តិរបស់ក្រុមប្រឹក្សា ដោយបែងចែកតាមឆ្នាំនីមួយៗ។
  - បំពេញតារាងការដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្តិ (តារាង"ការដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្ត"នៃនៃទម្រង់ទី១)។

គ). **ការរៀបចំកម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរយៈពេលប្រាំឆ្នាំរបស់រដ្ឋបាលសង្កាត់ ៖** បន្ទាប់ពីទទួលបានការជូនដំណឹងពីក្រុមការងារកសាងផែនការខណ្ឌ ចៅសង្កាត់ត្រូវដឹកនាំ គ.ផ.ថ របស់ខ្លួនដើម្បីរៀបចំកម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរយៈពេលប្រាំឆ្នាំរបស់រដ្ឋបាលសង្កាត់ (បំពេញទម្រង់ទី១) ដោយ ៖

- ស្រង់ក្របខ័ណ្ឌវិនិយោគរបស់សង្កាត់ ដែលបានរៀបចំនៅក្នុងសៀវភៅផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំរបស់សង្កាត់ដាក់បញ្ចូលក្នុងតារាងក្របខ័ណ្ឌវិនិយោគ(តារាង"ក្របខ័ណ្ឌវិនិយោគ" នៃទម្រង់ទី១)។
- ស្រង់ក្របខ័ណ្ឌផ្ដល់សេវារដ្ឋបាលរបស់សង្កាត់ ដែលបានរៀបចំនៅក្នុងសៀវភៅផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំរបស់សង្កាត់ ដាក់បញ្ចូលក្នុងតារាងក្របខ័ណ្ឌផ្ដល់សេវា (តារាង "ក្របខ័ណ្ឌផ្ដល់សេវា" នៃទម្រង់ទី១)។
- ស្រង់លិខិតបទដ្ឋាគតិយុត្តនានារបស់សង្កាត់ ដែលបានរៀបចំនៅក្នុងសៀវភៅផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំរបស់សង្កាត់ ដាក់បញ្ចូលក្នុងតារាងការដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្តិ (តារាង"ការដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្ត" នៃទម្រង់ទី១)។

<u>បញ្ជាក់</u> ៖ ដោយសារក្របខ័ណ្ឌពេលវេលានៃការកសាងផែនការអភិវឌ្ឍន៍របស់សង្កាត់ និងរបស់ខណ្ឌមិនស្របគ្នា ដូច្នេះ ចៅសង្កាត់នីមួយៗ ត្រូវចម្លងទាំងស្រុងចេញពីកម្មវិធីអភិវឌ្ឍន៍មូលដ្ឋាន ដែលបានរៀបចំនៅក្នុងផែនការអភិវឌ្ឍន៍របស់ខ្លួន ឬអាចធ្វើការកែសម្រួលតាមការចាំបាច់មុននឹងបញ្ជូនមកក្រុមការងារកសាងផែនការខណ្ឌ។

ឃ). **ការរៀបចំកម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរបស់ការិយាល័យ អង្គភាពជំនាញ ៖** ដើម្បីរៀបចំកម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរបស់ការិយាល័យ អង្គភាពជំនាញ ប្រធានការិយាល័យ អង្គភាពត្រូវរៀបចំកិច្ចប្រជុំការិយាល័យ អង្គភាពរបស់ខ្លួនដើម្បី ៖

- **កំណត់ក្របខ័ណ្ឌវិនិយោគ** ដោយត្រូវ ៖
  - ផ្អែកលើតារាងក្របខ័ណ្ឌអភិវឌ្ឍន៍ខណ្ឌ
  - គោលនយោបាយ យុទ្ធសាស្ត្រ និងឫកម្មវិធីអភិវឌ្ឍន៍របស់ក្រសួង ស្ថាប័ន
  - ព្យាករណ៍អំពីលទ្ធភាពធនធានថវិកា ធនធានមនុស្ស និងធនធានផ្សេងៗទៀតដែលការិយាល័យ អង្គភាពជំនាញមាន ឬអាចនឹងមានសម្រាប់រយៈពេលប្រាំឆ្នាំ
  - កំណត់របៀបវារៈនៃការអភិវឌ្ឍន៍មូលដ្ឋាន និងចាត់អាទិភាព ស្របតាមការព្យាករណ៍អំពីលទ្ធភាពធនធានដែលការិយាល័យ អង្គភាពជំនាញអាចមានក្នុងរយៈពេលប្រាំឆ្នាំ ព្រមទាំងកំណត់សូចនាករ និងក្របខ័ណ្ឌពេលវេលានៃការអនុវត្ត និងលទ្ធផលរំពឹងទុកក្នុងរបៀបវារៈនីមួយៗដើម្បីបំពេញក្នុងតារាងក្របខ័ណ្ឌវិនិយោគ(តារាង"ក្របខ័ណ្ឌវិនិយោគ" នៃទម្រង់ទី១)។
- **កំណត់ក្របខ័ណ្ឌផ្តល់សេវារដ្ឋបាល** ដោយត្រូវ ៖
  - ផ្អែកលើប្រភេទសេវារដ្ឋបាល និងចំនួនសេវាដែលបាននិងកំពុងផ្តល់ជូនប្រជាពលរដ្ឋ
  - ផ្អែកលើមុខងារ និងធនធានការិយាល័យ អង្គភាពជំនាញនីមួយៗមាន ឬអាចមាន
  - ធ្វើការប៉ាន់ប្រមាណអំពីប្រភេទ និងបរិមាណនៃសេវានានាទាំងនោះសម្រាប់រយៈពេលប្រាំឆ្នាំនៃអាណត្តិរបស់ក្រុមប្រឹក្សា ដោយបែងចែកតាមឆ្នាំនីមួយៗ។
  - បំពេញតារាងក្របខ័ណ្ឌផ្តល់សេវា (តារាង "ក្របខ័ណ្ឌផ្តល់សេវា" នៃទម្រង់ទី១)

  **បញ្ជាក់ ៖** ការិយាល័យ អង្គភាពជំនាញនានាមិនបំពេញតារាង "ការដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្ត" នៃទម្រង់ទី១ឡើយ។

ង). បន្ទាប់ពីរៀបចំតារាងកម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរយៈពេលប្រាំឆ្នាំហើយ នាយករដ្ឋបាលខណ្ឌ ប្រធានការិយាល័យ អង្គភាពជំនាញ និងចៅសង្កាត់នីមួយៗ ត្រូវបញ្ជូនមកឲ្យក្រុមការងារកសាងផែនការខណ្ឌឲ្យបានទាន់ពេលវេលាកំណត់។

ច). ក្រុមការងារកសាងផែនការខណ្ឌពិនិត្យនិងរៀបចំបញ្ចប់តារាងកម្មវិធីអភិវឌ្ឍន៍មូលដ្ឋានដែលមាន ៖
- តារាង២.៣. ក្របខ័ណ្ឌវិនិយោគសម្រាប់រយៈពេលប្រាំឆ្នាំរបស់រដ្ឋបាលខណ្ឌ
- តារាង២.៤. ក្របខ័ណ្ឌផ្តល់សេវារដ្ឋបាលរយៈពេលប្រាំឆ្នាំរបស់រដ្ឋបាលខណ្ឌ
- តារាង២.៥. ការដាក់ចេញលិខិតបទដ្ឋានគតិយុត្តនានារយៈពេលប្រាំឆ្នាំរបស់រដ្ឋបាលខណ្ឌ
- តារាង២.៦. ក្របខ័ណ្ឌវិនិយោគរយៈពេលប្រាំឆ្នាំរបស់ការិយាល័យ អង្គភាពជំនាញ
- តារាង២.៧. ក្របខ័ណ្ឌផ្តល់សេវារដ្ឋបាលរយៈពេលប្រាំឆ្នាំរបស់ការិយាល័យ អង្គភាពជំនាញ

**<u>កំណត់សម្គាល់</u> ៖** ដោយផ្អែកតាមតារាង២.៣. តារាង២.៤ តារាង២.៥. និងទម្រង់ទី១ ជាតុចូលដែលទទួលបានពីគ្រប់សង្កាត់ ក្រុមការងារកសាងផែនការខណ្ឌ ត្រូវរៀបចំបំពេញទម្រង់ទី២របស់រាជធានី តាមការណែនាំរបស់ក្រុមការងារកសាងផែនការរាជធានី និងបញ្ជូនទៅឲ្យក្រុមការងារកសាងផែនការរាជធានីតាមកាលបរិច្ឆេទដែលបានកំណត់។

## ២.៤. ការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម

ផ្អែកតាមទំហំនៃសូចនាករអភិវឌ្ឍន៍ដែលបានសរសេរខាងលើ ក្រុមការងារកសាងផែនការត្រូវធ្វើការគណនាប៉ាន់ស្មានអំពីតម្រូវការថវិកាចំណាយ។ ថវិកាចំណាយមានពីរផ្នែក គឺផ្នែកចំណាយចរន្ត និងផ្នែកចំណាយមូលធន។ ទោះបីជាថវិកាចំណាយនេះមិនទាន់មានលក្ខណៈត្រឹមត្រូវឥតខ្ចោះក៏ដោយ ក៏ថវិកាចំណាយនេះបង្ហាញឱ្យឃើញពីភាពម្ចាស់ការក្នុងកម្រិតណាមួយរបស់ខណ្ឌ។ សេចក្តីណែនាំលម្អិតសម្រាប់រៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យមនឹងធ្វើការណែនាំជាក្រោយ ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ២.៥. ការពិនិត្យ និងផ្តល់យោបល់របស់គណៈអភិបាល

- បន្ទាប់ពីរៀបចំសេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍ និងកម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរយៈពេលប្រាំឆ្នាំរបស់រដ្ឋបាលខណ្ឌ និងរបស់ការិយាល័យ អង្គភាពជំនាញនានាហើយ ក្រុមការងារកសាងផែនការខណ្ឌត្រូវដាក់សេចក្តីព្រាងទាំងនេះជូនគណៈអភិបាលខណ្ឌពិនិត្យ និងផ្តល់យោបល់
- ក្រុមការងារកសាងផែនការខណ្ឌត្រូវកែសម្រួលតាមការណែនាំ ឬអនុសាសន៍របស់គណៈអភិបាលខណ្ឌ
- ក្រុមការងារកសាងផែនការខណ្ឌដាក់សេចក្តីព្រាងចុងក្រោយជូនអភិបាល ដើម្បីដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងសម្រេច។

## ២.៦. ការពិនិត្យ និងសម្រេចលើសេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍ និងកម្មវិធីអភិវឌ្ឍន៍មូលដ្ឋាន

បន្ទាប់ពីបានទទួលសេចក្តីព្រាងទាំងពីរខាងលើពីអភិបាល ប្រធានក្រុមប្រឹក្សាខណ្ឌរៀបចំកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួន តាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា ដើម្បីពិនិត្យ និងសម្រេចលើឯកសារទាំងនោះ។ ក្រុមប្រឹក្សាត្រូវពិនិត្យ និងសម្រេចលើសេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍ និងកម្មវិធីអភិវឌ្ឍន៍មូលដ្ឋាននៅក្នុងកិច្ចប្រជុំរបស់ខ្លួន ហើយស្មារតីការសម្រេចនេះ ត្រូវសរសេរក្នុងកំណត់ហេតុប្រជុំក្រុមប្រឹក្សា។ ក្របខ័ណ្ឌអភិវឌ្ឍន៍ខណ្ឌ និងកម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរយៈពេលប្រាំឆ្នាំដែលបានសម្រេច គឺជាមូលដ្ឋានសម្រាប់រៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល ពិសេសសម្រាប់ឆ្នាំទី១នៃអាណត្តិរបស់ក្រុមប្រឹក្សា ដែលក្រុមការងារកសាងផែនការខណ្ឌ អាចចាប់ផ្តើមរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ក្រុមប្រឹក្សាខណ្ឌ។

## ២.៧. ការរៀបចំក្របខ័ណ្ឌតាមដាន និងវាយតម្លៃ

ក្នុងការរៀបចំក្របខ័ណ្ឌតាមដាន និងវាយតម្លៃ ក្រុមការងារកសាងផែនការខណ្ឌត្រូវកំណត់អំពី ៖

- **យុទ្ធសាស្ត្រ** ការតាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ ដោយត្រូវផ្តោតលើចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម ៖
  - ក្របខ័ណ្ឌពេលវេលាសម្រាប់ការតាមដាន និងវាយតម្លៃលើការអនុវត្តផែនការអភិវឌ្ឍន៍
  - ការកំណត់សូចនាករសម្រាប់តាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ខណ្ឌ
  - ការកំណត់អ្នកទទួលខុសត្រូវតាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ខណ្ឌ
  - ការកំណត់វិធីសាស្ត្រតាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ខណ្ឌ
  - ការកំណត់អ្នកចូលរួមក្នុងការតាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ខណ្ឌ។

- **វិសាលភាព** ការតាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍មានវិសាលភាពលើ ៖
  - ក្របខ័ណ្ឌអភិវឌ្ឍន៍ខណ្ឌ
  - កម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរបស់រដ្ឋបាលខណ្ឌ
  - ក្របខ័ណ្ឌវិនិយោគរបស់ការិយាល័យ អង្គភាពជំនាញ
  - ក្របខ័ណ្ឌផ្តល់សេវារដ្ឋបាលរបស់ការិយាល័យ អង្គភាពជំនាញ
- រៀបចំតារាងក្របខ័ណ្ឌតាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ខណ្ឌ ដែលរួមមាន ៖
  - តារាង២.៨.ក្របខ័ណ្ឌតាមដាន និងវាយតម្លៃការអនុវត្តក្របខ័ណ្ឌអភិវឌ្ឍន៍ខណ្ឌ
  - តារាង២.៩.ក្របខ័ណ្ឌតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរបស់រដ្ឋបាលខណ្ឌ
  - តារាង២.១០. ក្របខ័ណ្ឌតាមដាន និងវាយតម្លៃការអនុវត្តក្របខ័ណ្ឌវិនិយោគរបស់ការិយាល័យ អង្គភាព
  - តារាង២.១១. ក្របខ័ណ្ឌតាមដាន និងវាយតម្លៃការអនុវត្តក្របខ័ណ្ឌផ្តល់សេវារដ្ឋបាលរបស់ការិយាល័យ អង្គភាពជំនាញ
- ការវាយតម្លៃនៅពាក់កណ្តាលអាណត្តិរបស់ក្រុមប្រឹក្សា ដោយមានក្រុមការងារកសាងផែនការខណ្ឌជាសេនាធិការ គណៈអភិបាលខណ្ឌត្រូវប្រមូលទិន្នន័យដើម្បីបញ្ចូលក្នុងតារាង២.៨. ដល់ ២.១១.ខាងលើ ហើយត្រូវរៀបចំសេចក្តីព្រាងរបាយការណ៍ពាក់កណ្តាលអាណត្តិស្តីពីការអនុវត្តផែនការអភិវឌ្ឍន៍ ដោយសហការជាមួយរដ្ឋបាលសង្កាត់ តំណាងការិយាល័យ អង្គភាពជំនាញនានា។ ខ្លឹមសាររបាយការណ៍នេះ រួមមាន វឌ្ឍនភាពការងារអនុវត្តកន្លងមក ទិសដៅការងារសម្រាប់អនុវត្តបន្ត និងសេចក្តីសន្និដ្ឋានរួម។
- គណៈអភិបាលខណ្ឌត្រូវពិនិត្យ និងកែសម្រួលសេចក្តីព្រាងរបាយការណ៍ពាក់កណ្តាលអាណត្តិ បន្ទាប់មកត្រូវដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត។
- ក្រុមប្រឹក្សាខណ្ឌពិនិត្យវឌ្ឍនភាពនៃការសម្រេចបាននូវសូចនាករ និងឧបសគ្គ ហើយផ្តល់ការណែនាំសំខាន់ៗ ព្រមទាំងអនុម័តសេចក្តីព្រាងរបាយការណ៍ពាក់កណ្តាលអាណត្តិ។
- ក្រុមប្រឹក្សាខណ្ឌ ត្រូវធ្វើការណែនាំដល់គណៈអភិបាលខណ្ឌ ដើម្បីផ្សព្វផ្សាយរបាយការណ៍ពាក់កណ្តាលអាណត្តិដែលបានអនុម័តនេះ ជូនដល់អ្នកពាក់ព័ន្ធ។
- គណៈអភិបាលខណ្ឌត្រូវធ្វើការវាយតម្លៃអំពីលទ្ធផល សមិទ្ធផល និងផលប៉ះពាល់នៃការអនុវត្តផែនការអភិវឌ្ឍន៍ ក្នុងរយៈពេលប្រាំមួយខែចុងក្រោយនៃអាណត្តិរបស់ក្រុមប្រឹក្សាប្រកបដោយប្រសិទ្ធភាព និងមានការចូលរួមពីអ្នកពាក់ព័ន្ធនានា។

## ២.៨. ការរៀបចំខ្លឹមសារស្ថានភាពសេដ្ឋកិច្ច សង្គមរបស់ខណ្ឌ

ផ្អែកលើលទ្ធផលនៃការវិភាគស្ថានភាព ក្រុមការងារកសាងផែនការខណ្ឌត្រូវសរសេរបរិយាយអំពីស្ថានភាពសេដ្ឋកិច្ច សង្គមរបស់ខណ្ឌ ដោយឆ្លុះបញ្ចាំងអំពីស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈមតាមគំរូដូចមាននៅក្នុងឧបសម្ព័ន្ធទី៥។

**ដំណាក់កាលទី២**

## ២.៩. ការចងក្រងសេចក្តីព្រាងសៀវភៅផែនការអភិវឌ្ឍន៍ខណ្ឌ

បន្ទាប់ពីរៀបចំព័ត៌មាន និងតារាងនានាខាងលើហើយ ក្រុមការងារកសាងផែនការខណ្ឌត្រូវរៀបចំចងក្រងសេចក្តីព្រាងសៀវភៅផែនការអភិវឌ្ឍន៍ខណ្ឌ ដោយផ្អែកតាមមាតិកានៃសៀវភៅផែនការអភិវឌ្ឍន៍ខណ្ឌ ដោយត្រូវសរសេរបរិយាយស្របតាមសេចក្តីពន្យល់ ដែលមានក្នុងផ្នែកទី២នៃសេចក្តីណែនាំនេះ។

## ២.១០. កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ខណ្ឌ

ក). **សមាសភាពចូលរួម**

- ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខណ្ឌ
- តំណាងក្រុមប្រឹក្សាខណ្ឌ
- គណៈអភិបាលខណ្ឌ
- ក្រុមការងារកសាងផែនការខណ្ឌ
- តំណាងក្រុមប្រឹក្សាគ្រប់សង្កាត់
- តំណាងសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់
- សមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសខណ្ឌ
- តំណាងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខណ្ឌ និងគណៈកម្មាធិការផ្សេងៗទៀត
- តំណាងអង្គការ សង្គមស៊ីវិល និងវិស័យឯកជនពាក់ព័ន្ធក្នុងខណ្ឌ
- អ្នកពាក់ព័ន្ធដទៃទៀតតាមការចាំបាច់។

គ). **កិច្ចការដែលត្រូវធ្វើ**

- ក្រុមការងារកសាងផែនការខណ្ឌ រៀបចំឯកសារដូចខាងក្រោម ៖
  - របៀបវារៈនៃកិច្ចប្រជុំ
  - លិខិតអញ្ជើញដោយភ្ជាប់ជាមួយនូវសេចក្តីព្រាងផែនការអភិវឌ្ឍន៍ខណ្ឌ
  - បទបង្ហាញស្តីពីខ្លឹមសារសំខាន់ៗនៃសេចក្តីព្រាងផែនការអភិវឌ្ឍន៍ខណ្ឌ
  - ឯកសារចាំបាច់ផ្សេងៗទៀតដែលស្នើឡើងដោយគណៈអភិបាល។
- កិច្ចប្រជុំពិគ្រោះយោបល់គួរប្រព្រឹត្តទៅតាមរបៀបវារៈដូចខាងក្រោម ៖
  - បទបង្ហាញពីខ្លឹមសារនៃសេចក្តីព្រាងផែនការអភិវឌ្ឍន៍ខណ្ឌ
  - ក្នុងករណីចាំបាច់ អង្គប្រជុំអាចធ្វើការបែងចែកអ្នកចូលរួមជាក្រុមដើម្បីពិភាក្សាលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ ក្នុងនោះអាចមានប្រធានបទសំខាន់ៗដូចជា ៖

    ក). ក្របខ័ណ្ឌអភិវឌ្ឍន៍ ៖

    + ចក្ខុវិស័យអភិវឌ្ឍន៍
    + គោលបំណងអភិវឌ្ឍន៍
    + គោលដៅអភិវឌ្ឍន៍
    + យុទ្ធសាស្ត្រអភិវឌ្ឍន៍ និង
    + ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម ។ល។

ខ). កម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរយៈពេលប្រាំឆ្នាំ ៖

+ ក្របខ័ណ្ឌវិនិយោគ

+ ក្របខ័ណ្ឌផ្តល់សេវាកម្ម និង

+ ការដាក់ចេញលិខិតបទដ្ឋានគតិយុត្តនានា។

- ក្រុមការងារកសាងផែនការខណ្ឌ ត្រូវកត់ត្រានូវរាល់មតិយោបល់ និងធាតុចូលនានាដែលទទួលបានពីកិច្ចប្រជុំពិគ្រោះយោបល់នេះ សម្រាប់ពិនិត្យ និងកែសម្រួលសេចក្តីព្រាងផែនការអភិវឌ្ឍន៍ខណ្ឌ រួចដាក់ជូនគណៈអភិបាលពិនិត្យ និងផ្តល់យោបល់។

## ២.១១. ការពិនិត្យ និងផ្តល់យោបល់

- **ការពិនិត្យ និងផ្តល់យោបល់របស់គណៈអភិបាលខណ្ឌ**
  - បន្ទាប់ពីទទួលបានសេចក្តីព្រាងសៀវភៅផែនការអភិវឌ្ឍន៍ពីក្រុមការងារកសាងផែនការខណ្ឌ អភិបាលខណ្ឌរៀបចំកិច្ចប្រជុំគណៈអភិបាលរបស់ខ្លួនដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ខណ្ឌ
  - ក្រុមការងារកសាងផែនការ កែសម្រួលសេចក្តីព្រាងផែនការអភិវឌ្ឍន៍ខណ្ឌ ផ្អែកតាមមតិយោបល់របស់គណៈអភិបាល រួចដាក់ជូនគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសដើម្បីពិនិត្យ និងផ្តល់យោបល់។
- **ការពិនិត្យ និងផ្តល់យោបល់របស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស**
  - បន្ទាប់ពីទទួលបានសេចក្តីព្រាងសៀវភៅផែនការអភិវឌ្ឍន៍ពីក្រុមការងារកសាងផែនការខណ្ឌ ប្រធានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរៀបចំកិច្ចប្រជុំគណៈម្មាធិការរបស់ខ្លួនដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ខណ្ឌ
  - ក្រុមការងារកសាងផែនការ កែសម្រួលសេចក្តីព្រាងផែនការអភិវឌ្ឍន៍ខណ្ឌ ផ្អែកតាមមតិយោបល់របស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស រួចដាក់ជូនអភិបាល ដើម្បីជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត។

**តារាង ២.១. ៖ លទ្ធផលក្រុមវិភាគស្ថានភាពខណ្ឌ**

ក្រុម.............................. ផ្នែក...........................

| ល.រ | បញ្ហា | មូលហេតុ | ដំណោះស្រាយ | ផ្សេងៗ |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |

## តារាង២.២. ក្របខ័ណ្ឌអភិវឌ្ឍន៍ខណ្ឌ

| **ចក្ខុវិស័យ ÷** | | | | | |
|---|---|---|---|---|---|
| គោលបំណង និងគោលដៅ | សូចនាករ | | | | យុទ្ធសាស្ត្រអភិវឌ្ឍន៍ |
| | ការបរិយាយ | ឯកតា | ដើមគ្រា | ២០... | |
| **១. ផ្នែកសេដ្ឋកិច្ច** | | | | | |
| **១.១. គោលបំណង ៖** | | | | | |
| ១.១.១. គោលដៅ៖ | | | | | |
| ១.១.២. គោលដៅ៖ | | | | | |
| **១.២. គោលបំណង ៖** | | | | | |
| ១.២.១. គោលដៅ៖ | | | | | |
| ១.២.២. គោលដៅ៖ | | | | | |
| **២. ផ្នែកសង្គមកិច្ច** | | | | | |
| **២.១. គោលបំណង ៖** | | | | | |
| ២.១.១. គោលដៅ៖ | | | | | |
| ២.១.២. គោលដៅ៖ | | | | | |
| **៣. ផ្នែកគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ** | | | | | |
| **៣.១. គោលបំណង៖** | | | | | |
| ៣.១.១. គោលដៅ៖ | | | | | |
| ៣.១.២. គោលដៅ៖ | | | | | |
| **៤. ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ** | | | | | |
| **៤.១. គោលបំណង ៖** | | | | | |
| ៤.១.១. គោលដៅ៖ | | | | | |
| ៤.១.២. គោលដៅ៖ | | | | | |

### តារាង២.៣. ក្របខ័ណ្ឌវិនិយោគសម្រាប់រយៈពេលប្រាំឆ្នាំរបស់រដ្ឋបាលខណ្ឌ

| ល.រ | កម្មវិធីអភិវឌ្ឍន៍ | ឆ្លើយតបគោលដៅ | បរិយាយ | ឯកតា | លទ្ធផលប៉ាន់ស្មាន | | | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ២០.. | ២០.. | ២០.. | ២០.. | ២០.. | សរុប | |
| ក. ផ្នែកសេដ្ឋកិច្ច | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| ខ. ផ្នែកសង្គមកិច្ច | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| គ. ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| ឃ. ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |

### តារាង២.៤. ក្របខ័ណ្ឌវិនិយោគរយៈពេលប្រាំឆ្នាំរបស់ការិយាល័យ អង្គភាពជំនាញ

| ល.រ | កម្មវិធីអភិវឌ្ឍន៍ | ឆ្លើយតបគោលដៅ | បរិយាយ | ឯកតា | លទ្ធផលប៉ាន់ស្មាន | | | | | | ផ្នែក |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ២០.. | ២០.. | ២០.. | ២០.. | ២០.. | សរុប | |
| ១. ការិយាល័យ....... | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| ២. ការិយាល័យ.......... | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| ៣. ការិយាល័យ............ | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |

### តារាង២.៥. ក្របខ័ណ្ឌផ្តល់សេវារដ្ឋបាលរយៈពេលប្រាំឆ្នាំរបស់រដ្ឋបាលខណ្ឌ

| ល.រ | ប្រភេទសេវារដ្ឋបាល | ឯកតា | លទ្ធផលប៉ាន់ស្មាន | | | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| | | | ២០.. | ២០.. | ២០.. | ២០.. | ២០.. | សរុប | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |

### តារាង២.៦. ក្របខ័ណ្ឌផ្តល់សេវារដ្ឋបាលរយៈពេលប្រាំឆ្នាំរបស់ការិយាល័យ អង្គភាពជំនាញ

| ល.រ | ប្រភេទសេវារដ្ឋបាល | ឯកតា | លទ្ធផលប៉ាន់ស្មាន | | | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| | | | ២០.. | ២០.. | ២០.. | ២០.. | ២០.. | សរុប | |
| ១. ការិយាល័យ............ | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| ២. ការិយាល័យ............... | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |

### តារាង២.៧. លិខិតបទដ្ឋានគតិយុត្ត ដែលត្រូវរៀបចំ និងដាក់ឲ្យអនុវត្តរយៈពេលប្រាំឆ្នាំរបស់រដ្ឋបាលខណ្ឌ

| ល.រ | ប្រភេទលិខិត | ឯកតា | លទ្ធផលប៉ាន់ស្មាន | | | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| | | | ២០.. | ២០.. | ២០.. | ២០.. | ២០.. | សរុប | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |

### តារាង២.៨.ក្របខ័ណ្ឌតាមដាន និងវាយតម្លៃការអនុវត្តក្របខ័ណ្ឌផែនការអភិវឌ្ឍន៍

| គោលបំណង និងគោលដៅ | សូចនាករ | | | | អ្នកទទួលបន្ទុក | ប្រភពព័ត៌មាន | វិធីសាស្រ្ត |
|---|---|---|---|---|---|---|---|
| | ការបរិយាយ | ឯកតា | គ្រោង | ជាក់ស្តែង | | | |
| **១. ផ្នែកសេដ្ឋកិច្ច** | | | | | | | |
| **១.១. គោលបំណង ៖** | | | | | | | |
| ១.១.១. គោលដៅ ៖ | | | | | | | |
| ១.១.២. គោលដៅ ៖ | | | | | | | |
| **១.២. គោលបំណង ៖** | | | | | | | |
| ១.២.១. គោលដៅ ៖ | | | | | | | |
| ១.២.២. គោលដៅ ៖ | | | | | | | |
| **២. ផ្នែកសង្គមកិច្ច** | | | | | | | |
| **២.១. គោលបំណង ៖** | | | | | | | |
| ២.១.១. គោលដៅ ៖ | | | | | | | |
| ២.១.២. គោលដៅ ៖ | | | | | | | |
| **៣. ផ្នែកគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងការបន្សុំាំនឹងការប្រែប្រួលអាកាសធាតុ** | | | | | | | |
| **៣.១. គោលបំណង ៖** | | | | | | | |
| ៣.១.១. គោលដៅ ៖ | | | | | | | |
| ៣.១.២. គោលដៅ ៖ | | | | | | | |
| **៤. ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ** | | | | | | | |
| **៤.១. គោលបំណង ៖** | | | | | | | |
| ៤.១.១. គោលដៅ ៖ | | | | | | | |
| ៤.១.២. គោលដៅ ៖ | | | | | | | |

### តារាង២.៩.ក្របខ័ណ្ឌតាមដាន និងវាយតម្លៃការអនុវត្តក្របខ័ណ្ឌវិនិយោគរយៈពេលប្រាំឆ្នាំ

| ល.រ | កម្មវិធីអភិវឌ្ឍន៍ | ឆ្លើយតបគោលដៅ | បរិយាយ | ឯកតា | គ្រោង | ជាក់ស្តែង | ប្រែប្រួល | អ្នកទទួលបន្ទុក | ប្រភពព័ត៌មាន | វិធីសាស្ត្រ |
|---|---|---|---|---|---|---|---|---|---|---|
| **១. សម្រាប់រដ្ឋបាលខណ្ឌ** | | | | | | | | | | |
| ក. ផ្នែកសេដ្ឋកិច្ច | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ខ. ផ្នែកសង្គមកិច្ច | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| គ. ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ឃ. ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| **២. សម្រាប់ការិយាល័យ អង្គភាពជំនាញ** | | | | | | | | | | |
| ក. ការិយាល័យ.......... | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ខ. ការិយាល័យ.............. | | | | | | | | | | |
| | | | | | | | | | | |

### តារាង២.១០.ក្របខ័ណ្ឌតាមដាន និងវាយតម្លៃការអនុវត្តក្របខ័ណ្ឌផ្តល់សេវារដ្ឋបាល

| ល.រ | ប្រភេទសេវារដ្ឋបាល | ឯកតា | គ្រោង | ជាក់ស្តែង | ប្រែប្រួល | អ្នកទទួលបន្ទុក | ប្រភពព័ត៌មាន | វិធីសាស្ត្រ |
|---|---|---|---|---|---|---|---|---|
| **១. សម្រាប់រដ្ឋបាលខណ្ឌ** | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| **២. សម្រាប់ការិយាល័យ អង្គភាពជំនាញ** | | | | | | | | |
| ក. ការិយាល័យ................. | | | | | | | | |
| | | | | | | | | |
| | | | | | | | | |

### តារាង២.១១.ក្របខ័ណ្ឌតាមដាន និងវាយតម្លៃ
### ការអនុវត្តដាក់ចេញលិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋបាលខណ្ឌ

| ល.រ | ប្រភេទលិខិត | ឯកតា | គ្រោង | ជាក់ស្តែង | ប្រែប្រួល | អ្នកទទួលបន្ទុក | ប្រភពព័ត៌មាន | វិធីសាស្ត្រ |
|---|---|---|---|---|---|---|---|---|
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |

# ជំហានទី៣

# ការអនុម័ត និងការផ្សព្វផ្សាយផែនការអភិវឌ្ឍន៍ខណ្ឌ

**គោលបំណង**

គោលបំណងនៃជំហាននេះ គឺដើម្បីពិនិត្យ អនុម័ត និងផ្សព្វផ្សាយផែនការអភិវឌ្ឍន៍ខណ្ឌសម្រាប់អាណត្តិរបស់ក្រុមប្រឹក្សា និងដើម្បីប្រើប្រាស់ជាមូលដ្ឋានក្នុងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខណ្ឌ។

**លទ្ធផលរំពឹងទុក**

លទ្ធផល ដែលរំពឹងថានឹងទទួលបានពីជំហាននេះ គឺ ៖

- ផែនការអភិវឌ្ឍន៍ខណ្ឌ ដែលបានអនុម័ត
- ខ្លឹមសារផែនការអភិវឌ្ឍន៍បានផ្សព្វផ្សាយយ៉ាងទូលំទូលាយដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ។

**ដំណើរការ**

ជំហានទី៣ រួមមាន ២សកម្មភាព ដូចខាងក្រោម ៖

៣.១. ការអនុម័តផែនការអភិវឌ្ឍន៍ខណ្ឌ

៣.២. ការបោះពុម្ព និងការផ្សព្វផ្សាយសៀវភៅផែនការអភិវឌ្ឍន៍ខណ្ឌ

## ៣.១. ការអនុម័តផែនការអភិវឌ្ឍន៍ខណ្ឌ

### ៣.១.១ ការងារមុនកិច្ចប្រជុំក្រុមប្រឹក្សាខណ្ឌ

- ក្រុមការងារកសាងផែនការដោយមានជំនួយពីនាយករដ្ឋបាលខណ្ឌ និងការិយាល័យ ផែនការ និងអភិវឌ្ឍន៍ ត្រូវរៀបចំកិច្ចការសំខាន់ៗដូចខាងក្រោម ៖
  - រៀបចំរបៀបវារៈនៃកិច្ចប្រជុំ
  - រៀបចំសេចក្តីថ្លែងហេតុ
  - រៀបចំឯកសារបង្ហាញអំពីសេចក្តីព្រាងផែនការអភិវឌ្ឍន៍ខណ្ឌ
  - រៀបចំ និងបញ្ជូនលិខិតអញ្ជើញ ដោយភ្ជាប់ជាមួយនូវសេចក្តីព្រាងផែនការអភិវឌ្ឍន៍ខណ្ឌ និងឯកសារពាក់ព័ន្ធផ្សេងៗទៀត (ឯកសារទាំងនេះត្រូវផ្ញើជូនអ្នកពាក់ព័ន្ធនានាឱ្យបានយ៉ាងតិច០៣ថ្ងៃមុនកិច្ចប្រជុំ)
  - រៀបចំកិច្ចការចាំបាច់ផ្សេងៗទៀតតាមការណែនាំរបស់អភិបាលខណ្ឌ។

### ៣.១.២. អំឡុងពេលប្រជុំក្រុមប្រឹក្សាខណ្ឌ

**ក). សមាសភាពចូលរួម**

- ក្រុមប្រឹក្សាខណ្ឌ
- គណៈអភិបាលខណ្ឌ
- ក្រុមការងារកសាងផែនការខណ្ឌ
- ប្រធានការិយាល័យផែនការ និងអភិវឌ្ឍ
- នាយករដ្ឋបាលនៃសាលាខណ្ឌ
- អ្នកពាក់ព័ន្ធ និងអ្នកសង្កេតការណ៍នានាចូលរួមតាមការអនុញ្ញាតពីប្រធានក្រុមប្រឹក្សាខណ្ឌ។

ខ). **កិច្ចការដែលត្រូវធ្វើ**

- អភិបាលខណ្ឌអានសេចក្តីថ្លែងហេតុ និងធ្វើបទបង្ហាញអំពីសេចក្តីព្រាងផែនការអភិវឌ្ឍន៍
- ក្រុមប្រឹក្សាខណ្ឌពិនិត្យ ពិភាក្សា និងអនុម័តសេចក្តីព្រាងផែនការអភិវឌ្ឍន៍ខណ្ឌ (ឧបសម្ព័ន្ធទី៤ ៖ ចំណុចគន្លឹះសម្រាប់ជាមូលដ្ឋានក្នុងការពិនិត្យ និងអនុម័តផែនការអភិវឌ្ឍន៍)។ កិច្ចប្រជុំពិនិត្យ និងអនុម័តលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ខណ្ឌ ត្រូវដំណើរការតាមនីតិវិធី និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាខណ្ឌ។

### ៣.១.៣. ការងារក្រោយកិច្ចប្រជុំក្រុមប្រឹក្សាខណ្ឌ

ក). **ការកែសម្រួលសេចក្តីព្រាងផែនការអភិវឌ្ឍន៍ខណ្ឌ**

- ក្រុមការងារកសាងផែនការខណ្ឌ ត្រូវធ្វើការកែសម្រួលសេចក្តីព្រាងផែនការអភិវឌ្ឍន៍ ដោយផ្អែកតាមការសម្រេចរបស់ក្រុមប្រឹក្សាខណ្ឌ
- អភិបាលខណ្ឌចាត់ចែងបញ្ជូនសៀវភៅផែនការអភិវឌ្ឍន៍ខណ្ឌជូនរដ្ឋបាលរាជធានី ដើម្បីពិនិត្យ និងផ្តល់អនុលោមភាព។

ខ). **ការផ្តល់អនុលោមភាពលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ខណ្ឌ**

- បន្ទាប់ពីទទួលបានសេចក្តីព្រាងផែនការអភិវឌ្ឍន៍ពីអភិបាលខណ្ឌ អភិបាលរាជធានីត្រូវរៀបចំកិច្ចប្រជុំរបស់ខ្លួន ដើម្បីពិនិត្យ និងផ្តល់អនុលោមភាពលើសេចក្តីព្រាងផែនការនេះ។
- ការពិនិត្យ និងផ្តល់យោបល់របស់អភិបាលរាជធានី លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ខណ្ឌត្រូវផ្តោតលើភាពស្របច្បាប់ និងសង្គតិភាពរបស់ផែនការអភិវឌ្ឍន៍ខណ្ឌ ជាមួយនឹងគោលនយោបាយជាតិ ច្បាប់ និងលិខិតបទដ្ឋាននានា។
- អភិបាលរាជធានី ត្រូវពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ខណ្ឌ ក្នុងរយៈពេល៣០ថ្ងៃគិតពីថ្ងៃដែលទទួលបានការស្នើសុំពិនិត្យ និងផ្តល់យោបល់ពីអភិបាលខណ្ឌ។ រយៈពេល៣០ថ្ងៃនេះ រួមមានពេលវេលាចំណាយសម្រាប់ការធ្វើទំនាក់ទំនងរវាងអភិបាលខណ្ឌជាមួយនឹងអភិបាលរាជធានី ដើម្បីស្រាយបំភ្លឺ និងឯកភាពលើយោបល់ដែលផ្តល់ដោយអភិបាលរាជធានី លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ខណ្ឌ។
- ក្នុងករណីមិនមានការឯកភាពគ្នារវាងអភិបាលខណ្ឌ និងអភិបាលរាជធានីអំពីខ្លឹមសារនៃសេចក្តីព្រាងផែនការអភិវឌ្ឍន៍ខណ្ឌ អភិបាលរាជធានីត្រូវរាយការណ៍ និងស្នើសុំមកក្រសួងមហាផ្ទៃ ដើម្បីធ្វើការសម្របសម្រួលដោះស្រាយ។
- ក្នុងរយៈពេល៣០ថ្ងៃ បើគ្មានការឆ្លើយតបជាលាយលក្ខណ៍អក្សរពីអភិបាលរាជធានីទៅអភិបាលខណ្ឌទេ នោះសេចក្តីព្រាងផែនការអភិវឌ្ឍន៍ ត្រូវបានចាត់ទុកថាទទួលបានអនុលោមភាពពីអភិបាលរាជធានី។
- ក្នុងករណីមានយោបល់កែសម្រួលលើសេចក្តីផែនការអភិវឌ្ឍន៍ខណ្ឌ ដោយអភិបាលរាជធានី គណៈអភិបាលខណ្ឌ ធ្វើការពិចារណា និងកែសម្រួលសេចក្តីព្រាងផែនការអភិវឌ្ឍន៍ទៅតាម

យោបល់ដែលទទួលបាន ហើយដាក់ជូនក្រុមប្រឹក្សាខណ្ឌពិនិត្យ និងអនុម័តឡើងវិញ ដោយផ្តោតតែទៅលើចំណុចដែលបានកែសម្រួលប៉ុណ្ណោះ។

**គ). សេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់ផែនការអភិវឌ្ឍន៍ខណ្ឌ**

១. បន្ទាប់ពីទទួលបានការផ្តល់អនុលោមភាពពីអភិបាលរាជធានី ក្រុមការងារកសាងផែនការខណ្ឌ រៀបចំសេចក្តីព្រាងសេចក្តីសម្រេចស្តីពីការដាក់ឲ្យប្រើប្រាស់ផែនការអភិវឌ្ឍន៍ខណ្ឌ រួចដាក់ ជូនអភិបាលខណ្ឌពិនិត្យ និងផ្តល់យោបល់

២. ក្រុមការងារកសាងផែនការខណ្ឌកែសម្រួលតាមការណែនាំរបស់គណៈអភិបាល រួចដាក់ជូនអភិបាល ដើម្បីដាក់ជូនប្រធានក្រុមប្រឹក្សាខណ្ឌចុះហត្ថលេខា។

## ៣.២. ការបោះពុម្ព និងការផ្សព្វផ្សាយសៀវភៅផែនការអភិវឌ្ឍន៍ខណ្ឌ

### ៣.២.១. ការបោះពុម្ពសៀវភៅផែនការអភិវឌ្ឍន៍ខណ្ឌ

គណៈអភិបាលខណ្ឌ ត្រូវរៀបចំបោះពុម្ពសៀវភៅផែនការអភិវឌ្ឍន៍ខណ្ឌ និងបែងចែក ផ្សព្វផ្សាយជាសាធារណៈ និងតម្កល់ទុកនៅរដ្ឋបាលខណ្ឌ ការិយាល័យផែនការខណ្ឌ រដ្ឋបាលរាជធានី មន្ទីរផែនការរាជធានី មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី និងអ្នកពាក់ព័ន្ធផ្សេងទៀតតាមការចាំបាច់។

### ៣.២.២ ការផ្សព្វផ្សាយផែនការអភិវឌ្ឍន៍ខណ្ឌ

១. ក្រុមប្រឹក្សាខណ្ឌត្រូវណែនាំដល់គណៈអភិបាលខណ្ឌ ឲ្យធ្វើការផ្សព្វផ្សាយខ្លឹមសារផែនការអភិវឌ្ឍន៍ខណ្ឌ ឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ។

២. ជាមួយនឹងការផ្សព្វផ្សាយតាមការចែកសៀវភៅផែនការអភិវឌ្ឍន៍ខណ្ឌ ក្រុមប្រឹក្សាខណ្ឌគប្បីណែនាំឲ្យមានការផ្សព្វផ្សាយខ្លឹមសារផែនការអភិវឌ្ឍន៍ខណ្ឌឲ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា ដូចជាការផ្សព្វផ្សាយក្នុងកិច្ចប្រជុំនានា ក្នុងវេទិកាសាធារណៈ តាមសារព័ត៌មាន វិទ្យុក្នុងខណ្ឌ និងតាមមធ្យោបាយផ្សេងៗទៀតដែលអាចធ្វើបាន។ល។

# ផ្នែកទី៤
# ឧបសម្ព័ន្ធសម្រាប់ជំនួយស្មារតី
# នៅពេលរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ខណ្ឌ

## ឧបសម្ព័ន្ធទី១ ៖ ទម្រង់គំរូគោលការណ៍ណែនាំផ្នែកគោលនយោបាយ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ**

**រដ្ឋបាល ÷ .....................**

លេខ ៖ សសរ

**សេចក្តីសម្រេច**

**ស្តីពី**

**គោលការណ៍ណែនាំផ្នែកគោលនយោបាយ**

**សម្រាប់ការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល**

**ក្រុមប្រឹក្សា.....................**

– បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
– បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
– បានឃើញអនុក្រឹត្យលេខ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា អណៈអភិបាលរាជធានី ក្រុមប្រឹក្សា គណៈអភិបាលខណ្ឌ
– បានឃើញអនុក្រឹត្យលេខ២១៩ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការកសាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
– បានឃើញអនុក្រឹត្យលេខ១៥២ អនក្រ.បក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការកែសម្រួលមាត្រា១២នៃអនុក្រឹត្យស្តីពីការកសាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
– បានឃើញប្រកាសអន្តរក្រសួងលេខ........... ប្រក ចុះថ្ងៃទី....... ខែ.......... ឆ្នាំ២០......... ស្តីពីការកសាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
– យោងតាមស្មារតីកិច្ចប្រជុំ....................... លើកទី................ របស់ក្រុមប្រឹក្សា............... នាថ្ងៃទី........... ខែ............ ឆ្នាំ.............។

**សម្រេច**

**ប្រការ ១.-**

សេចក្តីសម្រេចនេះ មានគោលបំណងណែនាំផ្នែកគោលនយោបាយសម្រាប់ការកសាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ក្រុមប្រឹក្សា.................................។

**ប្រការ ២.-**

ដំណើរការកសាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ត្រូវអនុវត្តតាមសេចក្តីណែនាំបច្ចេកទេសស្តីពីការកសាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល...។

**ប្រការ ៣.-**

ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ត្រូវរៀបចំឡើងដោយផ្អែកលើគោលការណ៍សំខាន់ៗគឺ ១.ការចែករំលែកព័ត៌មាន ២.តម្លាភាព ៣.សង្គតិភាព និងសុខដុមនីយកម្ម ៤.ការចូលរួមពិគ្រោះយោបល់ជាទូទៅ ៥.ការឆ្លើយតបនឹងតម្រូវការរបស់មូលដ្ឋាន ៦.គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ ៧.ប្រសិទ្ធភាព និងសុក្រឹត្យភាពសេដ្ឋកិច្ចនិងសង្គម ៨.ការធានាចីរភាពធនធានធម្មជាតិ និងបរិស្ថាន និង៩.ការធានាសមធម៌។

**ប្រការ ៤.-**

ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ត្រូវមានលក្ខណៈគ្រប់ជ្រុងជ្រោយដែលគ្របដណ្តប់លើគ្រប់វិស័យអាទិភាព ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង មានសង្គតិភាពជាមួយគោលនយោបាយរបស់ជាតិ និងស្របតាមសក្តានុពលនានាដែលខ្លួនមាន ដើម្បីអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងធ្វើឱ្យប្រសើរឡើងនូវគុណភាពជីវិតនិងសុខុមាលភាពប្រជាពលរដ្ឋ ពិសេសស្ត្រី កុមារ យុវជន ជនពិការ ព្រមទាំងជនងាយរងគ្រោះផ្សេងៗទៀតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។

**ប្រការ ៥.-**

ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់... ត្រូវយកចិត្តទុកដាក់ជាចម្បងលើវិស័យ និងសកម្មភាពអាទិភាពនានា ដូចខាងក្រោម ៖

១. ពង្រឹង និងពង្រីកផលិតភាពកសិកម្មទាំងបរិមាណ និងគុណភាព ដោយយកចិត្តទុកដាក់លើការស្តារ ការកសាង ការជួសជុល ការថែទាំ និងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រខ្នាតតូច និងមធ្យម
២. ការកសាង ការជួសជុល និងការថែទាំហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍គ្រប់ប្រភេទ
៣. ពង្រឹង និងពង្រីកគុណភាពនៃការអប់រំចំណេះទូទៅ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ
៤. យកចិត្តទុកដាក់លើការលើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋ តាមរយៈការផ្គត់ផ្គង់ទឹកស្អាត អនាម័យជនបទ ការទទួលបានសេវាសុខាភិបាល និងការផ្សព្វផ្សាយអប់រំ
៥. លើកកម្ពស់ការគ្រប់គ្រង និងថែទាំធនធានធម្មជាតិ តាមរយៈការជំរុញការអនុវត្តច្បាប់ព្រៃឈើ ច្បាប់ជលផល ការទប់ស្កាត់រាល់សកម្មភាពអនាធិបតេយ្យលើការប្រើប្រាស់ធនធានធម្មជាតិគ្រប់ប្រភេទ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ
៦. លើកកម្ពស់ការអភិវឌ្ឍន៍តំបន់អេកូទេសចរណ៍ និងសោភ័ណ្ឌភាពទីក្រុង
៧. យកចិត្តទុកដាក់លើការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងរក្សាសុវត្ថិភាពជូនប្រជាពលរដ្ឋ
៨. ជំរុញការចុះបញ្ជីដីធ្លីជាប្រព័ន្ធជូនប្រជាពលរដ្ឋ
៩. ពង្រឹងការអនុវត្តគោលការណ៍អភិបាលកិច្ចល្អរបស់រដ្ឋបាលខេត្ត
១០. យកចិត្តទុកដាក់លើការលើកកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងតួនាទីជាអ្នកធ្វើសេចក្តីសម្រេចចិត្ត
១១. ការលើកកម្ពស់ និងការលើកទឹកចិត្តដល់ការវិនិយោគរបស់វិស័យឯកជន
១២. ការលើកកម្ពស់ និងការលើកទឹកចិត្តរបស់អង្គការសង្គមស៊ីវិល ក្នុងការចូលរួមចំណែកអភិវឌ្ឍន៍មូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្រ
១៣. ។ល។

**ប្រការ ៦.-**

ដំណើរការកសាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ត្រូវផ្តល់ឱកាសឱ្យមានការចូលរួមបានពេញលេញដល់គ្រប់អ្នកពាក់ព័ន្ធទាំងអស់។ អ្នកពាក់ព័ន្ធទាំងនោះ រួមមាន គណៈអភិបាល ការិយាល័យ អង្គភាពជំនាញនានា ការិយាល័យនានាចំណុះសាលាខណ្ឌ តំណាងរដ្ឋបាលពាក់ព័ន្ធ អង្គការសង្គមស៊ីវិល វិស័យឯកជន ប្រជាពលរដ្ឋ ក្រុមតំណាងផលប្រយោជន៍ជាក់លាក់ និងក្រុមជនងាយរងគ្រោះនានា។ល។

**ប្រការ ៧.-**

គណៈអភិបាល ប្រធានការិយាល័យ អង្គភាពជំនាញ និងអ្នកពាក់ព័ន្ធទាំងអស់ ដូចប្រការ៦ខាងលើ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

............., ថ្ងៃទី........ ខែ........... ឆ្នាំ ២០.......

**ប្រធានក្រុមប្រឹក្សា**........

<u>កន្លែងទទួល ៖</u>

- .............

  *"ដើម្បីគោរពជូនជ្រាប"*
- ដូចប្រការ ៦ និងប្រការ ៧

  *"ដើម្បីអនុវត្ត"*
- ឯកសារ កាលប្បវត្តិ។

**ឧបសម្ព័ន្ធទី២ ៖ វិធីសាស្ត្រវិភាគស្ថានភាព**

## ឧបករណ៍ "វិភាគតាមដើមឈើបញ្ហា"

ក្នុងការវិភាគស្ថានភាពរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ក៏ដូចជាការវិភាគស្ថានភាពរបស់មន្ទីរ អង្គភាព ការិយាល័យ និងអ្នកពាក់ព័ន្ធនានា ប្រសិនបើមិនទាន់អាចកំណត់បានច្បាស់លាស់អំពីបញ្ហា និងមូលហេតុនៃបញ្ហា ក្រុមការងារកសាងផែនការ គ.ផ.ថ និងអ្នកពាក់ព័ន្ធនីមួយៗនោះ អាចធ្វើការវិភាគស្ថានភាព ដោយប្រើប្រាស់ឧបករណ៍ "ដើមឈើបញ្ហា" និងឬឧបករណ៍ផ្សេងៗទៀតតាមការចាំបាច់។

ដើមឈើបញ្ហា គឺជាឧបករណ៍សម្រាប់វិភាគស្ថានភាព ដោយត្រូវកំណត់អំពីបញ្ហាចម្បង មូលហេតុដែលនាំឲ្យមានបញ្ហា និងផលប៉ះពាល់ដែលកើតចេញពីបញ្ហាចម្បងនោះ។ ដូច្នេះ ដើម្បីកំណត់បាននូវបញ្ហា មូលហេតុនៃបញ្ហា និងដំណោះស្រាយតាមវិស័យ ឬផ្នែកនីមួយៗ អ្នកពាក់ព័ន្ធនីមួយៗត្រូវពិចារណា និងអនុវត្តតាមនីតិវិធីមួយចំនួនដូចខាងក្រោម ៖

- វិភាគបញ្ហា និងមូលហេតុនៃបញ្ហា
- វិភាគអំពីគោលបំណង គោលដៅ និងដំណោះស្រាយ
- ធ្វើការចាត់អាទិភាពដំណោះស្រាយ រួចស្រង់ចូលតារាងតាមការណែនាំរបស់ក្រុមការងារ។

**ក). ការវិភាគបញ្ហា និងមូលហេតុនៃបញ្ហា**

ការវិភាគបញ្ហា និងមូលហេតនៃបញ្ហាត្រូវអនុវត្តដូចខាងក្រោម ៖

- អ្នកវិភាគ ត្រូវឯកភាពលើបញ្ហាចម្បងក្នុងផ្នែក ឬវិស័យរបស់ខ្លួន។ ដើមឈើមួយប្រើសម្រាប់បញ្ហាចម្បងមួយ។ ប្រសិនបើមានបញ្ហាចម្បងច្រើន ត្រូវប្រើដើមឈើបញ្ហាច្រើនតាមចំនួនបញ្ហាចម្បង នោះ។ បញ្ហាចម្បងនីមួយៗ ដែលត្រូវយកមកវិភាគ គឺជាបញ្ហាដែលអាចរកដំណោះស្រាយបាន។

**ឧទាហរណ៍** : បញ្ហាចម្បង គឺ ប្រជាពលរដ្ឋមានចំណូលទាប




- បន្ទាប់ពីកំណត់បញ្ហាចម្បងហើយ ត្រូវបន្តកំណត់អំពីមូលហេតុដែលនាំឲ្យកើតមានបញ្ហាចម្បង នោះ ដោយសួរសំណួរថា "**ហេតុអ្វី ?**"។

**ឧទាហរណ៍** : មូលហេតុនៃបញ្ហា




- បន្ទាប់ពីកំណត់បញ្ហា និងមូលហេតុនៃបញ្ហា ត្រូវបន្តវិភាគ និងកំណត់អំពីផលប៉ះពាល់ដែលកើតចេញពីបញ្ហាចម្បងនោះ ដោយសួរសំណួរថា "**មានអ្វីកើតឡើង ?**"។




- បន្ទាប់ពីកំណត់បញ្ហាចម្បង មូលហេតុនៃបញ្ហា និងផលប៉ះពាល់ហើយ ត្រូវរៀបចំលទ្ធផលនៃការវិភាគនេះ ទៅជាទម្រង់ដើមឈើបញ្ហា ដូចខាងក្រោម ៖




- បន្ទាប់ពីកំណត់បញ្ហាចម្បង មូលហេតុនៃបញ្ហា និងផលប៉ះពាល់ហើយ ត្រូវវិភាគអំពីតម្រូវការយេនឌ័រ។ ក្នុងការកំណត់អំពីតម្រូវការយេនឌ័រ អ្នកវិភាគត្រូវវិភាគតាមបញ្ហា មូលហេតុ និងផលប៉ះពាល់នីមួយៗ ដោយពិចារណាថា តើបញ្ហាបានបង្កប់នូវបញ្ហាយេនឌ័រយ៉ាងដូចម្តេចខ្លះ? តើមូលហេតុនីមួយៗ បានបង្កប់នូវបញ្ហាយេនឌ័រយ៉ាងដូចម្តេចខ្លះ? តើផលប៉ះពាល់នីមួយៗបានបង្កប់នូវបញ្ហាយេនឌ័រយ៉ាងដូចម្តេចខ្លះ?

**ឧទាហរណ៍ :**



## ខ). ការវិភាគអំពីដំណោះស្រាយ

បន្ទាប់ពីរៀបចំដើមឈើបញ្ហា ត្រូវបន្តរៀបចំដើមឈើដំណោះស្រាយ។ ឧបករណ៍ដើមឈើដំណោះស្រាយនេះមានលក្ខណៈប្រហាក់ប្រហែលគ្នាដើមឈើបញ្ហាដែរ។ ប៉ុន្តែដើមឈើដំណោះស្រាយផ្តោតលើការបំប្លែងពីដើមឈើបញ្ហាទៅជាដំណោះស្រាយ។ ក្នុងការរៀបចំ និងវិភាគអំពីដើមឈើដំណោះស្រាយ អ្នកវិភាគគប្បីពិនិត្យ ពិចារណាលើជំហាននានា ដូចខាងក្រោម ៖

- កែសម្រួលបញ្ហាស្នូល ឬបញ្ហាចម្បងឱ្យទៅជាគោលបំណង ដោយការប្តូរប្រយោគអវិជ្ជមានពីមុនឱ្យទៅជាប្រយោគវិជ្ជមាន ដែលពិពណ៌នាអំពីស្ថានភាពមួយបន្ទាប់ដោះស្រាយបញ្ហាចម្បងនោះ។

**ឧទាហរណ៍** : ប្រជាពលរដ្ឋមានចំណូលទាប ទៅជា ចំណូលរបស់ប្រជាពលរដ្ឋកើនឡើង។

- កែសម្រួលមូលហេតុផ្ទាល់ឱ្យទៅជាគោលដៅ តាមនីតិវិធីដូចខាងលើ

**ឧទាហរណ៍** : ទិន្នផលស្រូវទាប ***ទៅជា*** ទិន្នផលស្រូវកើនឡើង

- កែសម្រួលមូលហេតុរងឱ្យទៅជាដំណោះស្រាយតាមនីតិវិធីដូចខាងលើ

**ឧទាហរណ៍** : កសិករខ្វះបច្ចេកទេស ***ទៅជា*** បណ្តុះបណ្តាលបច្ចេកទេសកសិកម្ម ជាដើម។




## គ). ធ្វើការចាត់អាទិភាពដំណោះស្រាយ និងស្រង់ចូលតារាង

បន្ទាប់ពីកំណត់បាននូវបញ្ហា មូលហេតុ និងដំណោះស្រាយហើយ អ្នកវិភាគនីមួយៗត្រូវស្រង់ព័ត៌មានទាំងនោះចូលក្នុងតារាង (តាមការណែនាំរបស់ក្រុមការងារកសាងផែនការ)។

<u>**បញ្ជាក់**</u>: ក្នុងការវិភាគស្ថានភាពរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ក្រុមការងារកសាងផែនការរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មន្ទីរ អង្គភាព និងគណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ សង្កាត់ (គ.ផ.ថ) អាចពិចារណាប្រើប្រាស់វិធីសាស្ត្រផ្សេងៗទៀត ដូចជា ការវិភាគផែនទី ដ្យាក្រាមសកម្មភាពស្ត្រី បុរស ការវិភាគនិន្នាការ ការវាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះ(VRA) តាមការចាំបាច់ និងតាមលទ្ធភាពដែលក្រុមការងារអាចធ្វើបាន។

## ឧបករណ៍
## វិភាគផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ

នៅក្នុងការបញ្ជ្រាបការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ ក្រុមការងារកសាងផែនការ គ.ផ.ថ និង ឬ អ្នកពាក់ព័ន្ធផ្សេងៗទៀត អាចប្រើប្រាស់ឧបករណ៍នានាដូចខាងក្រោម ៖

**១). ការគូសផែនទីហានិភ័យនៃគ្រោះមហន្តរាយ**

ការរៀបចំផែនទីនេះនឹងជួយកំណត់ពីមុខសញ្ញាហានិភ័យនៃគ្រោះមហន្តរាយ ដែលបានកើតឡើងក្នុងមូលដ្ឋាន។ ការគូរផែនទីនឹងជួយដល់អ្នករៀបចំផែនការក្នុងការកំណត់នូវទីតាំង និងស្ថានភាពនៃភាពងាយរងគ្រោះ ដើម្បីឈានទៅធ្វើការវិភាគផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។ ការគូសផែនទីនេះនឹងធ្វើឡើងនៅក្នុងកម្រិតឃុំ សង្កាត់ ដោយមានការចូលរួមពីសមាជិកក្រុមប្រឹក្សា គ.ក.ន.ក ប្រធានភូមិ និងអ្នកពាក់ព័ន្ធនានា ដោយប្រើប្រាស់ផែនទីរដ្ឋបាលឃុំ សង្កាត់ជាគោល។

ការគូសផែនទីត្រូវធ្វើឡើងជា៤ជំហាន ដូចខាងក្រោម ៖

- **ជំហានទី១ ៖** គូសគំនូសទ្រង់ទ្រាយរបស់រដ្ឋបាលឃុំ សង្កាត់ កំណត់ព្រំប្រទល់រដ្ឋបាលភូមិ រួចហើយអ្នកចូលរួមគូរបន្ថែមនូវទីតាំងលក្ខណៈធម្មជាតិដូចជា ទន្លេ បឹង ព្រៃ តំបន់អភិរក្សជាដើម។
- **ជំហានទី២ ៖** គូសបន្ថែមនូវហេដ្ឋារចនាសម្ព័ន្ធថ្មីៗដែលមានក្នុងមូលដ្ឋានទៅក្នុងផែនទី ដូចជា ៖
  - ផ្លូវ
  - អគារសាធារណៈ (វត្ត អគាររដ្ឋបាល សាលារៀន មន្ទីរពេទ្យ...)
  - ទំនប់ទឹក អាងស្តុកទឹក ប្រព័ន្ធធារាសាស្ត្រ អណ្តូងទឹក និងស្រះ
  - ហេដ្ឋារចនាសម្ព័ន្ធអគ្គីសនី (ម៉ាស៊ីនភ្លើង, ថាមពលកកើតឡើងវិញ...)
  - ទីតាំងចាក់សំរាម ប្រព័ន្ធលូ
  - បូជនីយដ្ឋាន ជាដើម
- **ជំហានទី៣ ៖** ក្នុងជំហាននេះ អ្នកចូលរួមគូសផែនទីបញ្ជាក់ពីទីតាំងដែលទទួលរងផលប៉ះពាល់ពីគ្រោះធម្មជាតិ ដោយប្រើប្រាស់គំនូសតាងផ្សេងៗគ្នា ឬប្រើប្រាស់ពណ៌ជាសញ្ញាតាមការឯកភាពគ្នាក្នុងក្រុម។ ផលប៉ះពាល់អាចមានដូចជា តំបន់ដែលរងផលប៉ះពាល់ពីទឹកជំនន់ គ្រោះរាំងស្ងួត ព្យុះ សត្វល្អិតបំផ្លាញ ជម្ងឺរាតត្បាត ការឡើងកំដៅ និងតំបន់ឆ្នេរដែលមានរលកធំៗ ជាដើម។
- **ជំហានទី៤ ៖** អ្នកចូលរួមកំណត់ និងគូសលើផែនទីពីស្ថានភាពប្រែប្រួលនៃទិដ្ឋភាពពីមុន និងពេលបច្ចុប្បន្ន (ឧទាហរណ៍ ៖ ទំនប់តាមតំបន់ឆ្នេរ ការបាត់បង់ព្រៃ និងដីអភិរក្ស)។ ការប្រែប្រួលទាំងនេះអាចមានប្រភពខុសគ្នាៗដូចជា បណ្តាលមកពីការសម្រេចចិត្តផ្នែកនយោបាយ សង្គម សេដ្ឋកិច្ច ផលប៉ះពាល់ពីអាកាសធាតុ និងពីគ្រោះធម្មជាតិជាដើម។ ទោះជាមានហេតុផលខុសគ្នាក៏ដោយ ការប្រែប្រួលនៃបរិស្ថានធម្មជាតិ ក៏អាចជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់ការប្រែប្រួលអាកាសធាតុ ឬគ្រោះធម្មជាតិផងដែរ។

**តាមរយៈឧបករណ៍ទី១នេះ** អ្នកវិភាគអាចកំណត់បាននូវទីតាំងភូមិសាស្ត្រ ប្រភេទគ្រោះមហន្តរាយធម្មជាតិ ស្ថានភាពនៃការប្រែប្រួល និងមូលហេតុនានាដែលនាំឲ្យមានការប្រែប្រួលស្ថានភាពគ្រោះធម្មជាតិតាមប្រភេទនីមួយៗ។ ឧបករណ៍ទី១នេះ នឹងត្រូវប្រើប្រាស់ជាមូលដ្ឋានក្នុងការអនុវត្តឧបករណ៍ផ្សេងៗទៀត។

## ២). ការវិភាគនិន្នាការ

ការវិភាគនិន្នាការ គឺជាឧបករណ៍សម្រាប់កំណត់នូវការប្រែប្រួលអាកាសធាតុសំខាន់ៗ និងព្រឹត្តការណ៍គ្រោះមហន្តរាយទាក់ទងនឹងអាកាសធាតុដែលកើតមានឡើង។ លទ្ធផលនៃការវិភាគនេះនឹងផ្តល់នូវព័ត៌មានអំពីគ្រោះមហន្តរាយអាកាសធាតុជាក់លាក់ និន្នាការនៃប្រភេទគ្រោះមហន្តរាយធម្មជាតិនីមួយៗ ភាពញឹកញាប់ ភាពធ្ងន់ធ្ងរ និងរបបនៃផលប៉ះពាល់។

ការអនុវត្តនូវឧបករណ៍វិភាគនិន្នាការនេះ ត្រូវធ្វើឡើងជាមួយប្រជាពលរដ្ឋ ដែលស្ថិតក្នុងតំបន់រងគ្រោះពីគ្រោះមហន្តរាយ (ផ្អែកលើផែនទីហានិភ័យគ្រោះមហន្តរាយ) ជនងាយរងគ្រោះ ស្ត្រី ចាស់ជរា និងជនក្រីក្រ ដោយបែងចែកជាក្រុមពិភាក្សាតូចៗ ដូចជា ក្រុមស្ត្រី ក្រុមបុរស និងក្រុមអាជ្ញាធរ ឬច្រើនជាងនេះទៅតាមការចាំបាច់។ ការវិភាគធ្វើឡើងជា៣ជំហាន ដូចខាងក្រោម ៖

- **ជំហានទី១ ៖** អ្នកសម្របសម្រួលត្រូវសួរអំពីព្រឹត្តការណ៍គ្រោះមហន្តរាយទាក់ទងនឹងអាកាសធាតុ និងផលប៉ះពាល់ដែលពួកគេបានជួបប្រទះកន្លងមក ហើយយកទិន្នន័យនោះទៅបំពេញនៅក្នុងតារាងខាងក្រោមត្រង់ខ្ទង់លក្ខខណ្ឌគ្រោះថ្នាក់នៃអាកាសធាតុ និងធាតុអាកាស (ដូចមានក្នុងតារាងខាងក្រោម)។
- **ជំហានទី២ ៖** អ្នកសម្របសម្រួលបន្តសាកសួរដល់អ្នកចូលរួមធ្វើការចាត់ថ្នាក់ភាពងាយរងគ្រោះដែលបានជួបប្រទះតាមឆ្នាំ ដែលបានកំណត់ទៅតាមមុខសញ្ញានៃគ្រោះមហន្តរាយនីមួយៗ។ ក្នុងការធ្វើចំណាត់ថ្នាក់នេះត្រូវដាក់ពិន្ទុ កម្រិតរងគ្រោះពី១ ដល់៥ (១.កម្រិតរងគ្រោះទាបបំផុត និង៥.ជាកម្រិតរងគ្រោះធ្ងន់ធ្ងរបំផុត)។
- **ជំហានទី៣ ៖** បន្ទាប់ពីការដាក់ពិន្ទុកម្រិតភាពរងគ្រោះហើយ ត្រូវបន្តពិនិត្យមើលលើនិន្នាការនៃផលប៉ះពាល់ទៅតាមមុខសញ្ញានីមួយៗ ហើយស្វែងរកនូវមុខសញ្ញាគ្រោះថ្នាក់ណាមួយដែលកើតឡើងញឹកញាប់ និងកាន់តែធ្ងន់ធរ ដើម្បីធ្វើការវិភាគបន្តនៅក្នុងទម្រង់អក្សរ H។

**តារាងវិភាគនិន្នាការ**

| ប្រភេទគ្រោះធម្មជាតិ | និន្នាការ | | | | កំណត់សម្គាល់ |
|---|---|---|---|---|---|
| | ១៩៨០-៨៩ | ១៩៩០-៩៩ | ២០០០-០៩ | ២០១០-បច្ចុប្បន្ន | |
| រាំងស្ងួត | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | |
| រដូវប្រាំងអូស បន្លាយ (លើសពី៣សប្តាហ៍) | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | |
| ការខូតដំណាំ ដោយភាពរាំងស្ងួត | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | |
| ការខូតដំណាំ ដោយទឹកជំនន់ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | |
| ការធ្លាក់ភ្លៀងខ្លាំង | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | |
| ការកើនឡើងកម្រិតទឹកជំនន់ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | |
| ការអូសបន្លាយ រយៈពេលទឹក ជំនន់ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | |
| ការប្រែប្រួល អំឡុងពេលរដូវ ប្រាំង - វស្សា | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | |
| ។ល។ | | | | | |

**កំណត់សម្គាល់**

ក្នុងការអនុវត្តជាក់ស្តែង អ្នកវិភាគត្រូវពិចារណាលើកំណត់សម្គាល់ដូចខាងក្រោម ៖

- ប្រភេទគ្រោះធម្មជាតិ ៖ អាស្រ័យលើប្រភេទគ្រោះធម្មជាតិដែលបានកើតមានឡើងជាក់ស្ដែងនៅក្នុងមូលដ្ឋាននីមួយៗ។
- ឆ្នាំ ៖ អាចកំណត់ ឬបែងចែកតាមជំនាន់ ឬរបប ឬឆ្នាំ ឬតាមការកំណត់ផ្សេងៗទៀត ដែលអាចឲ្យអ្នកចូលរួមងាយស្រួលក្នុងការរំលឹកឡើងវិញនូវនិន្នាការពាក់ព័ន្ធនឹងគ្រោះធម្មជាតិនីមួយៗ

## ៣). ការវិភាគតាមទម្រង់ H

ឧបករណ៍ទម្រង់អក្សរ "H" គឺជាឧបករណ៍វាយតម្លៃដោយមានការចូលរួម ដែលពង្រឹងបន្ថែមលើលទ្ធផលនៃការវិភាគនិន្នាការ ហើយឧបករណ៍នេះមានគោលបំណងកំណត់ភាពប្រែប្រួលសំខាន់នៃអាកាសធាតុ និងព្រឹត្តការណ៍គ្រោះមហន្តរាយអាកាសធាតុ ព្រមទាំងផលប៉ះពាល់ក្នុងមូលដ្ឋាននៅតំបន់ជាក់លាក់ណាមួយ។ លើសពីនេះឧបករណ៍នេះក៏ជួយសម្រួលផងដែរក្នុងការកំណត់វិធានការបន្សាំដែលសមស្របសម្រាប់សហគមន៍។

ក្នុងការអនុវត្តជំហាននេះ អ្នកវិភាគត្រូវអនុវត្តតាមជំហាននានា ដូចខាងក្រោម ៖

- **ជំហានទី១ "ការកំណត់ផលប៉ះពាល់នៃមុខសញ្ញាគ្រោះមហន្តរាយ"៖** សកម្មភាពក្នុងជំហាននេះ រួមមាន ៖
  - កំណត់ និងឯកភាពលើមុខសញ្ញា ឬប្រភេទគ្រោះមហន្តរាយធម្មជាតិ
  - វិភាគនិន្នាការនៃមុខសញ្ញា ឬប្រភេទគ្រោះមហន្តរាយធម្មជាតិ ដោយសួរសំណួរគន្លឹះមួយចំនួនដូចខាងក្រោម ៖
    - + តើមានផលប៉ះពាល់អវិជ្ជមានអ្វីខ្លះ កើតចេញពីមុខសញ្ញានៃគ្រោះមហន្តរាយ?
    - + តើមានដំណោះស្រាយអ្វីខ្លះ?
    - + តើផលប៉ះពាល់ មានកម្រិតណា?
    - + តើនៅក្នុងសហគមន៍មានធនធានអ្វីខ្លះ សម្រាប់ដោះស្រាយបញ្ហាប្រឈមផលប៉ះពាល់ទាំងនោះ?។ល។
  - បន្ទាប់ពីសួរសំណួរគន្លឹះនានាហើយ អ្នកសម្របសម្រួលត្រូវ ៖
    - + ស្រង់នូវផលប៉ះពាល់អវិជ្ជមានដែលបានលើកឡើងដោយអ្នកចូលរួមទៅក្នុងផ្នែកខាងឆ្វេងនៃតារាងទម្រង់ H
    - + ស្រង់ពីធនធានដែលមានក្នុងសហគមដាក់នៅផ្នែកខាងស្ដាំនៃតារាងទម្រង់ H
    - + ស្រង់អំពីដំណោះស្រាយដែលបានលើកឡើងនៅផ្នែកកណ្ដាលនៃតារាងទម្រង់ H
  - បន្ទាប់មកទៀត អ្នកសម្របសម្រួលស្នើសុំឲ្យអ្នកចូលរួមវាយតម្លៃពីកម្រិតផលប៉ះពាល់នៃមុខសញ្ញារងគ្រោះនោះចំពោះរូបគេ និងក្រុមគ្រួសារម្នាក់ម្ដងៗ តាមរយៈការដាក់ពិន្ទុពី១ជាកម្រិតទាប ដល់៥ដែលជាកម្រិតធ្ងន់ធ្ងរ។ រួចធ្វើការគណនាមធ្យមភាគពិន្ទុដែល អ្នកចូលរួមបានដាក់។

**ការវិភាគតាមទម្រង់ H ទី១**

បញ្ហា ៖ ......................................................

| ផលប៉ះពាល់ ៖ | ដំណោះស្រាយ<br><br>១ ២ ៣ ៤ ៥ | ធនធានដែលមាន ៖ |
|---|---|---|
| + | + | + |
| + | + | + |
| + | + | + |

- បន្ទាប់ពីអ្នកចូលរួមនីមួយៗបានដាក់ពិន្ទុលើកម្រិតនៃផលប៉ះពាល់ហើយ អ្នកសម្របសម្រួលត្រូវបូកសរុប និងគិតមធ្យមភាគលើពិន្ទុដែលបានកំណត់។ ពិន្ទុមធ្យមភាគដែលបានកំណត់ត្រូវប្រើប្រាស់ជាសូចនាករសម្រាប់តាមដានអំពីវឌ្ឍនភាពនៃការឆ្លើយតបនឹងការបន្សាំការប្រែប្រួលអាកាសធាតុ និងជាលក្ខណៈវិនិច្ឆ័យសម្រាប់ចាត់អាទិភាពបញ្ហាដែលត្រូវដោះស្រាយ។

- **ជំហានទី២ "ការកំណត់ផលប៉ះពាល់ពីការកើនឡើងទ្វេរដងនៃមុខសញ្ញាគ្រោះមហន្តរាយ" ៖** នៅក្នុងជំហានទី២នេះ អ្នកសម្របសម្រួលលើកឡើងថា ប្រសិនបើមុខសញ្ញានៃគ្រោះមហន្តរាយ (មុខសញ្ញាដែលបានវិភាគក្នុងជំហានទី១) កើនឡើងកាន់តែញឹកញាប់ ឬកើនឡើងទ្វេដង តើប្រជាពលរដ្ឋម្នាក់ៗ ឬគ្រួសារនីមួយៗនឹងទទួលផលប៉ះពាល់យ៉ាងដូចម្ដេចខ្លះ? ហើយគួរត្រូវមានដំណោះស្រាយយ៉ាងដូចម្ដេច? អ្នកសម្របសម្រួលកត់ត្រាចម្លើយរបស់អ្នកចូលរួមនៅក្នុងទម្រង់ H ដូចខាងក្រោម ៖

**ការវិភាគតាមទម្រង់ H ទី២**

បញ្ហា ៖ ..........................................................

| ផលប៉ះពាល់ ៖ | ដំណោះស្រាយ ៖<br>១ ២ ៣ ៤ ៥ | |
|---|---|---|
| +<br>+<br>+ | +<br>+<br>+ | |

បន្ទាប់មក អ្នកសម្របសម្រួលស្នើឲ្យអ្នកចូលរួមដាក់ពិន្ទុលើកម្រិតផលប៉ះពាល់ ដូចជំហានទី១។ ទម្រង់អក្សរHទី២នេះ នឹងជួយឲ្យអ្នកចូលរួមគិតប្រមាណទុកជាមុននូវភាពធ្ងន់ធ្ងរនៃអាកាសធាតុ ដែលអាចគំរាមកំហែងដល់សហគមន៍ និងលើកយកដំណោះស្រាយកាន់តែមានប្រសិទ្ធភាពមួយកម្រិតថែមទៀតក្នុងការបង្ការផលប៉ះពាល់ពីគ្រោះមហន្តរាយ កសាងភាពធន់ និងការបន្សាំខ្លួនរបស់សហ គមន៍។

- **ជំហានទី៣ "ការកំណត់កត្តារាំង" ៖** បន្ទាប់មកអ្នកសម្របសម្រួលបន្តពិភាក្សាអំពីឧបសគ្គនានា ដែលអាចកើតមានឡើង ដោយប្រើឧបករណ៍ទម្រង់អក្សរ H ទី៣។ ក្នុងការប្រើប្រាស់ឧបករណ៍ H ទី៣នេះ អ្នកសម្រសបម្រួល ផ្ដោតលើកត្តារាំងនានា ដែលប្រជាពលរដ្ឋ ឬសហគមន៍មិនអាចបន្សាំទៅនឹងមុខសញ្ញានៃគ្រោះមហន្តរាយដែលត្រូវបានលើកឡើងមកនោះ។ ចម្លើយរបស់អ្នកចូលរួមត្រូវកត់ត្រាទុកនៅផ្នែកកណ្ដាលនៃតារាង ហើយអ្នកចូលរួមត្រូវដាក់ពិន្ទុនៃកម្រិតកត្តារាំងនោះម្នាក់ម្ដងៗពីលេខ១ជាកម្រិតតិចតួច ដល់លេខ៥ជាកម្រិតធ្ងន់ធ្ងរ។ ចុងបញ្ចប់ត្រូវគណនានូវពិន្ទុមធ្យមភាគនៃការដាក់ពន្ទុរបស់អ្នកចូលរួម។

**ការវិភាគតាមទម្រង់ H ទី៣**

បញ្ហា ៖ ..........................................................

| | កត្តារាំង ៖<br>១ ២ ៣ ៤ ៥ | |
|---|---|---|
| | +<br>+<br>+ | |

- **ជំហានទី៤ "ការកំណត់វិធានការ" ៖** បន្ទាប់មកអ្នកសម្របសម្រួលបន្តពិភាក្សាអំពីសកម្មភាព ឬ

វិធានការនានា ដែលអាចជួយឲ្យប្រជាពលរដ្ឋ និងគ្រួសារនីមួយៗអាចបន្សាំទៅនឹងមុខសញ្ញានៃមហន្តរាយធម្មជាតិ ដូចដែលបានវិភាគក្នុងជំហានទី៣ ដោយសួរសំណួរគន្លឹះ ថា ៖

- តើមានវិធានការបន្សាំអ្វីខ្លះដែលអាចជួយបង្កើនភាពធនរបស់សហគមន៍បាន?
- តើត្រូវធ្វើយ៉ាងដូចម្តេចខ្លះ ដើម្បីឲ្យទទួលបានពិន្ទុកាន់តែល្អជាងនេះ?

ជាមួយគ្នានេះ អ្នកសម្របសម្រួលត្រូវស្រង់ចម្លើយនៃសំណួរទាំងនេះដាក់ក្នុងផ្នែកកណ្តាលនៃទម្រង់ H និងត្រូវស្រង់ដំណោះស្រាយនានាដែលបានកំណត់ក្នុងជំហានទី២ មកដាក់បញ្ចូល និងបន្សីជាមួយគ្នា។ ព្រមទាំងធ្វើការដាក់ពិន្ទុដោយឯកភាពគ្នាជាក្រុមលើការទុកចិត្តនៃគម្រោង ឬដំណោះស្រាយដែលបានលើកឡើង ពីពិន្ទុ១ ដែលពិន្ទុទុកចិត្តខ្លាំងដល់ពិន្ទុ៥ ជាពិន្ទុមិនទុកចិត្តសោះ។

**ការគណនាពិន្ទុ៖**

ការគណនាពិន្ទុមធ្យមភាគនៃទម្រង់Hនីមួយៗ ត្រូវយកពិន្ទុសរុប ចែកនឹងចំនួនអ្នកដាក់ពិន្ទុ ឬ គណនាតាមមធ្យោបាយផ្សេងៗទៀតតាមការចាំបាច់។

- **ជំហានទី៥ "ការរៀបចំគម្រោង"** ៖ ក្រោយពីបានពិភាក្សាតាមក្រុមរួចរាល់ហើយ អ្នកសម្របសម្រួលយកលទ្ធផលនៃការពិភាក្សាក្រុមទាំងអស់ដាក់បញ្ចូលគ្នា ដោយស្រង់យកនូវដំណោះស្រាយនានា ដែលបានលើកឡើង មករៀបចំជាគម្រោងបន្សាំការប្រែប្រួលអាកាសធាតុ។ ចំណែកឯពិន្ទុនៃការពិភាក្សា ក្នុងក្រុមនីមួយៗ ត្រូវយកមកបូកបញ្ចូលគ្នាចែកនឹងចំនួនក្រុមពិភាក្សានឹងបានជាពិន្ទុមធ្យមភាគផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុក្នុងឃុំ សង្កាត់ ដែលត្រូវបានកំណត់ជា សូចនាករសម្រាប់តាមដានក្នុងឆ្នាំបន្ទាប់។ ក្រោយពីបានរៀបចំជាគម្រោងបន្សាំការ ប្រែប្រួលអាកាសធាតុរួចរាល់ហើយ អ្នកវិភាគត្រូវជួបប្រជុំគ្នាជាថ្មីដើម្បីធ្វើការចាត់ថ្នាក់ភាពងាយរងគ្រោះនៃគម្រោងដោយប្រើប្រាស់ឧបករណ៍ទី៤។

## ឧបសម្ព័ន្ធទី៣

# វិធីសាស្ត្រចាត់អាទិភាព

ការចាត់អាទិភាពបញ្ហា តម្រូវការ ដំណោះស្រាយ អាចមានវិធីសាស្ត្រជាច្រើន ដូចជា ១).វិធីសាស្ត្រផ្តល់ពិន្ទុផ្អែកលើលក្ខណៈវិនិច្ឆ័យ ២).វិធីសាស្ត្រផ្ទូរផ្ទង និង៣).វិធីសាស្ត្រជ្រើសរើសដោយដាក់ពិន្ទុតាមជម្រើសជាដើម។ ក្នុងចំណោមវិធីសាស្ត្រទាំងនេះ វិធីសាស្ត្រផ្តល់ពិន្ទុ ផ្អែកតាមលក្ខណៈវិនិច្ឆ័យ គឺជាវិធីសាស្ត្រសាមញ្ញ។

ក្នុងការអនុវត្តវិធីសាស្ត្រនេះ ក្រុមការងារកសាងផែនការ ឬអ្នកពាក់ព័ន្ធនានាអាចពិចារណា និងអនុវត្តតាមចំណុចនីមួយៗដូចខាងក្រោម ៖

- ស្រង់ជម្រើសនានា ដែលត្រូវចាត់អាទិភាពចូលក្នុងតារាង
- ពិភាក្សា និងកំណត់លក្ខណៈវិនិច្ឆ័យនានា។ ជាទូទៅលក្ខណៈវិនិច្ឆ័យមានការប្រែប្រួលទៅតាមលក្ខណៈនៃជម្រើស ឬបញ្ហា ឬដំណោះស្រាយ។ ជាទូទៅលក្ខណៈវិនិច្ឆ័យដែលចាំបាច់គួរតែមាននៅគ្រប់ជម្រើស ឬដំណោះស្រាយ គឺការឆ្លើយតបទៅនឹងតម្រូវការពិតប្រាកដរបស់ក្រុមងាយរងគ្រោះជាក់លាក់ណាមួយ និងភាពសមធម៌។
- ពិនិត្យជម្រើសនីមួយៗម្តងមួយៗ ដោយធៀបជាមួយលក្ខណៈវិនិច្ឆ័យដែលបានកំណត់។ ពិន្ទុដែលទទួលបានពីការប្រៀបធៀបត្រូវកំណត់ជាលេខ។ ពិន្ទុទាបជាងគេ០១ ហើយពិន្ទុខ្ពស់ជាងគេ គឺជាស្មើនឹងចំនួនជម្រើសសរុប។

**ឧទាហរណ៍ ៖** អំពីតារាងនៃវិធីផ្តល់ពិន្ទុផ្អែកលើលក្ខណៈវិនិច្ឆ័យ

| ជម្រើស | លក្ខណៈវិនិច្ឆ័យ | | | | | សរុបពិន្ទុ |
|---|---|---|---|---|---|---|
| | ការឆ្លើយតបតម្រូវការ | ងាយស្រួលអនុវត្ត | ការចូលរួម | សមធម៌ | ប្រសិទ្ធភាពតម្លៃ | |
| ដំណោះស្រាយ "ក" | 2 | 3 | 5 | 1 | 5 | 16 |
| ដំណោះស្រាយ "ខ" | 4 | 5 | 4 | 3 | 4 | 20 |
| ដំណោះស្រាយ "គ" | 3 | 3 | 3 | 2 | 3 | 14 |
| ដំណោះស្រាយ "ឃ" | 5 | 1 | 2 | 4 | 1 | 13 |
| ដំណោះស្រាយ "ង" | 1 | 1 | 2 | 1 | 1 | 6 |

តាមរយៈឧបករណ៍នេះ ក្រុមការងារបានកំណត់យកដំណោះស្រាយចំនួន០៥ និងលក្ខណៈវិនិច្ឆ័យចំនួន ០៥ មកធ្វើជាមូលដ្ឋានសម្រាប់រៀបលំដាប់ថ្នាក់អាទិភាពនៃដំណោះស្រាយ។ តាមការផ្តល់ពិន្ទុក្នុងតារាងខាងលើ យើងឃើញថា ៖

| ជំរើស | អាទិភាព |
|---|---|
| ដំណោះស្រាយ "ខ" | ១ |
| ដំណោះស្រាយ "ក" | ២ |
| ដំណោះស្រាយ "គ" | ៣ |
| ដំណោះស្រាយ "ឃ" | ៤ |
| ដំណោះស្រាយ "ង" | ៥ |

**ឧបសម្ព័ន្ធទី៤**

## ចំណុចគន្លឹះសម្រាប់ក្រុមប្រឹក្សា
## ពិនិត្យ និងអនុម័តផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ

ជាជំនួយស្មារតី ក្នុងការពិនិត្យ និងអនុម័តផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ ក្រុមប្រឹក្សាគប្បីយកចិត្តទុកដាក់លើចំណុចគន្លឹះនានា ដូចខាងក្រោម ៖

- តើការរៀបចំសៀវភៅផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំស្របតាមមាតិកា ដែលបានកំណត់ក្នុងសេចក្តីណែនាំបច្ចេកទេសដែរឬទេ ?
- តើដំណើរការរៀបចំផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ អនុវត្តតាមជំហាននានាដូចបានកំណត់ក្នុងសេចក្តីណែនាំបច្ចេកទេសឬទេ ?
- តើមានការវិភាគស្ថានភាពជាក់ស្តែងដែរឬទេ ?
- តើទិន្នន័យ និងព័ត៌មានដែលបានយកមកប្រើ គឺជាទិន្នន័យ និងព័ត៌មានដែលបានធ្វើបច្ចុប្បន្នភាពឬទេ ?
- តើការវិភាគស្ថានភាព បានផ្តោតលើបញ្ហារបស់ស្ត្រី បុរស កុមារ ជនពិការ យុវជន ឬក្រុមជនងាយរងគ្រោះជាក់លាក់ឬទេ ?
- តើការវិភាគស្ថានភាពបានផ្តោតលើបញ្ហាពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុឬទេ ?
- តើបានកំណត់អំពីបញ្ហាប្រឈម និងដំណោះស្រាយសមស្រប សម្រាប់ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ពិសេស ស្ត្រី បុរស កុមារ និងក្រុមជនងាយរងគ្រោះជាក់លាក់ឬទេ ?
- តើចក្ខុវិស័យអភិវឌ្ឍន៍ គោលបំណងអភិវឌ្ឍន៍ គោលដៅអភិវឌ្ឍន៍ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ដែលបានកំណត់ឆ្លុះបញ្ចាំង ឬស្របតាមគោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សាឬទេ ?
- តើចក្ខុវិស័យអភិវឌ្ឍន៍ គោលបំណងអភិវឌ្ឍន៍ គោលដៅអភិវឌ្ឍន៍ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ដែលបានកំណត់មានលក្ខណៈសមស្រប និងអាចសម្រេចបាននៅក្នុងអាណត្តិរបស់ក្រុមប្រឹក្សាឬទេ ?
- តើការកំណត់ចក្ខុវិស័យអភិវឌ្ឍន៍ គោលបំណងអភិវឌ្ឍន៍ គោលដៅអភិវឌ្ឍន៍ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍មានភាពប្រទាក់ក្រឡាគ្នាដែរឬទេ ?
- តើគោលដៅអភិវឌ្ឍន៍នីមួយៗបានកំណត់សូចនាករច្បាស់លាស់ដែរឬទេ ? បើមាន តើក្នុងអាណត្តិក្រុមប្រឹក្សាសម្រេចបានដែរឬទេ ?
- តើការកំណត់កម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរយៈពេលប្រាំឆ្នាំបានបញ្ចូលនូវ ១).ក្របខ័ណ្ឌវិនិយោគ ២).ក្របខ័ណ្ឌផ្តល់សេវា និង៣).ការដាក់ចេញនូវលិខិតបទដ្ឋានគតិតយុត្តដែរឬទេ ? បើមាន តើព័ត៌មាន និងសូចនាករដែលបានកំណត់លក្ខណៈជាក់លាក់ និងអាចសម្រេចបានដែរឬទេ ?
- តើមានការកំណត់ក្របខ័ណ្ឌតាមដាន និងវាយតម្លៃឬទេ ? បើមាន តើមានលក្ខណៈសមស្រប និងឆ្លើយតបទៅនឹងក្របខ័ណ្ឌអភិវឌ្ឍន៍ និងកម្មវិធីអភិវឌ្ឍន៍មូលដ្ឋានឬទេ ?
- តើសេចក្តីព្រាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ ត្រូវបានយកទៅពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនានាឬទេ ?

**ឧបសម្ព័ន្ធទី៥**

## ជំនួយស្មារតី

## សម្រាប់សរសេរអំពីស្ថានភាពទូទៅ

នៅពេលសរសេរពីស្ថានភាពទូទៅ សក្តានុពល និងបញ្ហាប្រឈមរបស់មូលដ្ឋាន (រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់) ក្រុមការងារកសាងផែនការ ឬគ.ផ.ថ ត្រូវអនុវត្តតាមលំដាប់លំដោយដូចខាងក្រោម ៖

**ការរៀបចំតារាងទិន្នន័យ**

តួលេខដែលយកមកបំពេញក្នុងតារាងសង្ខេបទិន្នន័យ ត្រូវស្រង់ចេញពីសៀវភៅទិន្នន័យភូមិ សង្កាត់ និងឯកសារព័ត៌មានស្ថានភាពមូលដ្ឋាន ដែលបានធ្វើបច្ចុប្បន្នភាពចុងក្រោយគេ។ តួលេខមួយចំនួនដូចជា ផ្ទៃដី ចំនួនសង្កាត់ ចំនួនភូមិ គឺក្រុមការងារកសាងផែនការត្រូវបំពេញដោយខ្លួនឯង។ ក្រុមការងារអាចបន្ថែមព័ត៌មានផ្សេងទៀត ដែលខ្លួនយល់ថាមានសារៈសំខាន់ដល់ការរំលេចគុណភាពផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំរបស់ខ្លួន ដូចជាសូចនាករនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព គោលដៅ និងចំណុចដៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ តែមិនគួរបន្ថែមច្រើនពេកនាំឱ្យព័ត៌មានទាំងនោះប្រែទៅជាមិនសំខាន់ទៅវិញ។

**ការសរសេរពីស្ថានភាពសេដ្ឋកិច្ច**

ក្នុងចំណុចនេះក្រុមការងារ ត្រូវធ្វើការកំណត់ និងសរសេរតាមបែបវិភាគអំពីសកម្មភាពសេដ្ឋកិច្ចចម្បងៗ និងបន្ទាប់បន្សំមួយចំនួន ដែលមានក្នុងមូលដ្ឋានដោយផ្អែកលើលទ្ធផលវិភាគផ្នែកសេដ្ឋកិច្ច។

សកម្មភាពសេដ្ឋកិច្ចចម្បង គឺសំដៅលើសកម្មភាពដែលប្រជាពលរដ្ឋភាគច្រើនអនុវត្ត ដើម្បីយកផលមកធ្វើជាកម្លាំងស្នូលក្នុងការទ្រទ្រង់ជីវភាពប្រចាំថ្ងៃ។ ចំណែកឯសកម្មភាពសេដ្ឋកិច្ចបន្ទាប់បន្សំ គឺសំដៅលើសកម្មភាពដែលប្រជាពលរដ្ឋមួយចំនួនអនុវត្ត ដើម្បីរកកម្រៃបន្ថែមសម្រាប់ការទ្រទ្រង់ជីវភាព (ទោះបីជាបរិមាណចំណូលពីសកម្មភាពសេដ្ឋកិច្ចបន្ទាប់បន្សំអាចច្រើនជាងចំណូលពីសកម្មភាពសេដ្ឋកិច្ចចម្បងក៏ដោយ ក៏នៅតែចាត់ទុកថាជាសកម្មភាពសេដ្ឋកិច្ចបន្ទាប់បន្សំ)។

**ឧទាហរណ៍ ៖** ក្នុងខណ្ឌដែលមានប្រជាពលរដ្ឋភាគច្រើនប្រកបរបរជាអាជីវករលក់ដូរ ដូច្នេះសកម្មភាពសេដ្ឋកិច្ចចម្បងគឺអាជីវកម្ម ទោះបីជាចំណូលពីការលក់ដូររបស់ប្រជាពលរដ្ឋម្នាក់ៗអាចមានកម្រិតទាបជាងចំណូលពីសកម្មភាពផ្សេងក៏ដោយ។ ក្រុមការងារត្រូវវិភាគស្ថានភាពអាជីវកម្មជាក់ស្តែងក្នុងដែនដីរបស់ខ្លួនដោយពិនិត្យពីកត្តា អ្វីខ្លះដែលបានជំរុញ និងអ្វីខ្លះជាឧបសគ្គដល់ការឈានឡើងទាំងចំពោះមុខ និងយូរអង្វែងរបស់វិស័យនេះក្នុងខណ្ឌហើយ ដែលកំពុងជះឥទ្ធិពលលើកម្រិតជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។ ទន្ទឹមនេះ ត្រូវបរិយាយពីអ្វីខ្លះដែលនាំឱ្យមានការផ្លាស់ប្តូរក្នុងមុខរបរជំនួញ (ឧទាហរណ៍ : កត្តាសេដ្ឋកិច្ចប្រែប្រួល) ហើយអ្វីខ្លះដែលត្រូវធ្វើការព្យាយាមទប់ស្កាត់ ឬគ្រប់គ្រងការផ្លាស់ប្តូរទាំងនេះ ដើម្បីធានានិរន្តរភាព និងភាពរីកចម្រើនក្នុងវិស័យនេះ។ ចំពោះរដ្ឋបាលដែលមានប្រជាពលរដ្ឋភាគច្រើនប្រកបអាជីវកម្ម សកម្មភាពសេដ្ឋកិច្ចចម្បងនោះ គឺអាជីវកម្ម ទោះបីជាចំណូលបានមកពីការធ្វើអាជីវកម្មរបស់ប្រជាជនម្នាក់ៗអាចតិចជាងចំណូលពីសកម្មភាពផ្សេងក៏ដោយ។

ក្នុងផ្នែកសេដ្ឋកិច្ច រួមមាន ៖

- **អាជីវកម្ម ៖** មុខរបរសំខាន់ៗក្នុងវិស័យអាជីវកម្មរួមមាន មុខរបរជំនួញ ប្រភេទសិប្បកម្មនានា ជាងជួសជុល។ល។ ក្នុងស្ថានភាពអាជីវកម្ម ត្រូវសរសេររៀបរាប់ពីសក្តានុពលសំខាន់ៗរបស់មូលដ្ឋាន និងបញ្ហាប្រឈមនានាដែលមូលដ្ឋានកំពុងជួបប្រទះ។
- **កសិកម្ម ៖** សកម្មភាពសំខាន់ៗក្នុងវិស័យកសិកម្ម រួមមាន ការដាំដុះស្រូវ ដំណាំកសិឧស្សាហកម្ម

និងដំណាំរួមផ្សំ ការចិញ្ចឹមសត្វនិងត្រី ការប្រើប្រាស់ជីធ្លី និងប្រព័ន្ធធារាសាស្ត្រដែលជួយគាំទ្រដល់ការងារកសិកម្ម។ ក្នុងស្ថានភាពកសិកម្ម ត្រូវសរសេររៀបរាប់អំពីសក្តានុពលសំខាន់ៗរបស់មូលដ្ឋាន និងបញ្ហាប្រឈមនានាកំពុងជួបប្រទះនៅក្នុងមូលដ្ឋាន។

- **ឧស្សាហកម្ម ៖** សកម្មភាពសំខាន់ៗក្នុងវិស័យឧស្សហកម្មរួមមាន សកម្មភាពសិប្បកម្ម រោងចក្រ និងការងារសំណង់ជាដើម។ ដូច្នេះ ត្រូវសរសេររៀបរាប់អំពីសក្តានុពល និងបញ្ហាប្រឈមសំខាន់ៗដែលពាក់ព័ន្ធនឹងវិស័យនេះ។
- **គមនាគមន៍ ៖** សរសេររៀបរាប់អំពីសក្តានុពលនៃប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធផ្លូវគោក និងផ្លូវទឹកដែលខេត្តមាន និងបញ្ហាប្រឈមសំខាន់ៗដែលមូលដ្ឋានកំពុងជួបប្រទះ។
- **សេវាកម្ម ៖** សរសេររៀបរាប់អំពីសក្តានុពល និងបញ្ហាប្រឈមនៃសេវាកម្មនានាពាក់ព័ន្ធនឹងសាធារណការ ទឹកស្អាត អគ្គិសនី ទីផ្សារ ទេសចរណ៍ ។ល។
- **ការវិនិយោគ ៖** ចំណុចនេះត្រូវសរសេររៀបរាប់អំពីទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការជាមួយវិស័យឯកជន ដើម្បីរៀបចំគម្រោងអភិវឌ្ឍន៍នានា ដូចជាការអភិវឌ្ឍន៍ផ្សារ ចំណតរថយន្ត ផ្លូវ ស្ពាន និងគម្រោងអភិវឌ្ឍន៍ផ្សេងទៀត។ ដូច្នេះត្រូវសរសេររៀបរាប់ពីសក្តានុពល និងបញ្ហាប្រឈមចម្បងៗដែលពាក់ព័ន្ធនឹងការវិនិយោគនេះ។
- **ការទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ៖** ត្រូវសរសេររៀបរាប់អំពីទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការជាមួយពាណិជ្ជករ ឬក្រុមហ៊ុនក្នុង ក្រៅខណ្ឌ ឬកិច្ចសហប្រតិបត្តិការ ឬការចងសម្ព័ន្ធមេត្រីជាមួយអាជ្ញាធររដ្ឋបាលនានាដើម្បីអភិវឌ្ឍន៍មូលដ្ឋាន ដូចជា ការបង្កើតតំបន់អភិវឌ្ឍន៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការការពារទឹកជំនន់ និងការអភិវឌ្ឍទីផ្សារជាដើម។ ដូច្នេះត្រូវសរសេររៀបរាប់អំពីសក្តានុពល និងបញ្ហាប្រឈមសំខាន់ៗ ដែលពាក់ព័ន្ធនឹងការងារទាំងនេះ។

ក្រៅពីចំណុចសំខាន់ដែលបានរៀបរាប់ខាងលើ ក្រុមការងារអាចបន្ថែមនូវចំណុចផ្សេងទៀត ដែលយល់ថាចាំបាច់ និងគួរបញ្ចូលក្នុងផែនការអភិវឌ្ឍន៍។ ការសរសេររៀបរាប់ចំណុចបន្ថែមនេះ គឺដូចគ្នានឹងចំណុចនានាខាងលើដោយផ្តោតលើសក្តានុពល និងបញ្ហាប្រឈមនានា ។

**ការសរសេរពីស្ថានភាពសង្គមកិច្ច**

ស្ថានភាពសង្គមកិច្ច គឺជាផ្នែកមួយដែលត្រូវធ្វើការសិក្សាពីលក្ខណៈប្រជាសាស្ត្រ សេវាសាធារណៈផ្នែកសង្គម និងសុវត្ថិភាពរបស់ប្រជាពលរដ្ឋ ដូចជា ស្ថានភាពអប់រំ សុខុមាលភាព យេនឌ័រ ភាពក្រីក្រ អំពើហិង្សា ការជួញដូរស្ត្រីនិងកុមារ ការលើកកម្ពស់សិទ្ធិមនុស្ស និងស្ថានភាពសាសនាជាដើម។ ពេលសរសេរអំពីស្ថានភាពសង្គមកិច្ចត្រូវសរសេរតាមបែបវិភាគដោយផ្អែកលើលទ្ធផលនៃការវិភាគសង្គមកិច្ច និងត្រូវផ្តោតលើចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម ៖

- **អប់រំ ៖** សរសេរពីការសម្រេចបានរបស់វិស័យអប់រំ ដូចជា ការសិក្សារបស់កុមារ ស្តង់ដារអប់រំ (ការចូលរៀនរបស់កុមារនៅថ្នាក់មត្តេយ្យ បឋមសិក្សា អនុវិទ្យាល័យ ការបោះបង់ចោលការសិក្សា ការរៀនត្រួតថ្នាក់ ពិសេសក្មេងស្រី ការងារអក្ខរកម្ម...)។
- **សុខាភិបាល ៖** សរសេរពីស្ថានភាពសុខភាពរបស់ប្រជាជន ពិសេសស្ត្រីនិងកុមារ កម្រិតនៃការទទួលបានសេវាសុខភាព អត្រាមរណភាពមាតានិងទារក គ្រោះថ្នាក់កើតពីជំងឺផ្សេងៗ និងបញ្ហាដែលពាក់ព័ន្ធនឹងសុខភាពមាតានិងកុមារ ទឹកស្អាត អនាម័យ បញ្ហាយុវវ័យ សុខភាពបន្តពូជ ។ល។

- **យេនឌ័រ ៖** គួរសរសេរពីការទទួលយកសេវា ការចូលរួមចំណែករបស់ស្ត្រីក្នុងការសម្រេចចិត្តនានា និងសកម្មភាពសង្គម និងការលំបាកដែលស្ត្រីកំពុងជួបប្រទះ (បុរសពុំបានជួប) ឬកត្តាទាំងឡាយក្នុងសង្គម ដែលនាំឱ្យស្ត្រីជួបការលំបាកញឹកញាប់ជាងបុរស។
- **ភាពក្រីក្រ ៖** សរសេរពីកម្រិតក្រីក្ររបស់ប្រជាជនដោយបង្ហាញពីមូលហេតុចម្បងៗដែលនាំឱ្យមានគ្រួសារមួយចំនួនធ្លាក់ខ្លួនក្រ មូលហេតុដែលគ្រួសារក្រីក្រមិនអាចកែលម្អជីវភាពរបស់ពួកគេបាន និងមូលហេតុដែលនាំឲ្យគ្រួសារក្រីក្របានកែលម្អជីវភាពខ្លួន។
- **សាសនា ៖** រៀបរាប់ពីប្រភេទសាសនា និងចំនួនភាគរយប្រជាពលរដ្ឋ ដែលកាន់សាសនានីមួយៗ។
- **អន្តោប្រវេសន៍ និងការផ្លាស់លំនៅ ៖** ត្រូវសរសេររៀបរាប់ពីស្ថានភាពនៃការផ្លាស់លំនៅរបស់ប្រជាពលរដ្ឋពីតំបន់ផ្សេងៗចូលមកមូលដ្ឋានខ្លួនដើម្បីប្រកបមុខរបរនានា ដូចជា ប្រកបមុខរបរជាកម្មករ រត់ម៉ូតូឌុប កម្មកររោងចក្រ និងជនបរទេសដែលចូលមកជាអ្នកទេសចរ ឬមកប្រកបមុខរបរ។ ចំណុចនេះ ត្រូវសរសេររៀបរាប់ពីសក្តានុពល និងបញ្ហាប្រឈមសំខាន់ៗ ដែលពាក់ព័ន្ធនឹងស្ថានភាពទាំងនេះ។

ក្រៅពីស្ថានភាពសំខាន់ៗខាងលើ ក្រុមការងារអាចធ្វើការរៀបរាប់បន្ថែមពីស្ថានភាពផ្សេងទៀតដែលពាក់ព័ន្ធនឹងស្ថានភាពសង្គមកិច្ច តាមស្ថានភាពជាក់ស្តែងរបស់មូលដ្ឋាន ដូចជាការលើកកម្ពស់សិទ្ធិកុមារ និងប្រជាពលរដ្ឋទូទៅ ការទប់ស្កាត់សកម្មភាពជួញដូរស្ត្រីនិងកុមារ ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការជួយជនចាស់ជរាគ្មានទីពឹង និវត្តជន កុមារកំព្រា ជនអនាថា។ល។

**ការសរសេរពីស្ថានភាពធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ**

ផ្នែកនេះត្រូវសរសេររៀបរាប់ពីអ្វីខ្លះដែលជាភាពខ្លាំង (សក្តានុពល) និងផលប្រយោជន៍ ដែលមានដូចជាដីធ្លី និងធនធានធម្មជាតិ និងអ្វីខ្លះដែលជាបញ្ហាប្រឈម ឬឧបសគ្គដែលកំពុងគំរាមកំហែងដល់ដីធ្លី ធនធានធម្មជាតិ និងបរិស្ថាន។ ទន្ទឹមនេះ ត្រូវសរសេររៀបរាប់ពីគ្រោះថ្នាក់ ការបាត់បង់ខូចខាត ការបំផ្លិចបំផ្លាញ ការប្រែប្រួល និងផលប៉ះពាល់ជាអវិជ្ជមានពីបាតុភូតទាំងឡាយកើតមានឡើង ដែលបង្កដោយមនុស្ស ឬដោយធម្មជាតិ។

ការសរសេរផ្នែកនេះត្រូវផ្អែកលើលទ្ធផលនៃការវិភាគការប្រើប្រាស់ដីធ្លី ការវិភាគធនធានធម្មជាតិ ការវិភាគបរិស្ថាន និងការវិភាគគ្រោះមហន្តរាយ ដោយផ្តោតលើ ៖

- **ការប្រើប្រាស់ដីធ្លី ៖** ត្រូវរៀបរាប់ពីបញ្ហាប្រឈមសំខាន់ៗ ដែលពាក់ព័ន្ធនឹងការប្រើប្រាស់ដីលំនៅដ្ឋាន ដីធ្វើស្រែ ដីចម្ការ ដីសម្រាប់ការវិនិយោគ ដីសម្បទាន តំបន់អភិរក្ស។ល។ ចំពោះការប្រើប្រាស់ដីសម្រាប់លំនៅដ្ឋាន ត្រូវរៀបរាប់ពីសក្តានុពលនិងបញ្ហាប្រឈមដែលពាក់ព័ន្ធនឹងការកំណត់ប្រភេទលំនៅដ្ឋាន ការផ្លាស់ប្តូរទីតាំង ការរៀបចំនិងគ្រប់គ្រងសំណង់អនាធិបតេយ្យ និងការរៀបចំប្លង់លំនៅដ្ឋានជាដើម។ល។
- **ធនធានធម្មជាតិ ៖** បរិយាយពីធនធានធម្មជាតិសំខាន់ៗ ដែលមាន ដូចជា ដីធ្លី ព្រៃឈើ សត្វព្រៃ ធនធានជលផល បឹង អូរ ស្ទឹង រ៉ែ...។ល។ ដែលប្រជាជនពឹងផ្អែកលើធនធានទាំងនេះ សម្រាប់ទ្រទ្រង់ជីវភាពរស់នៅរបស់ពួកគាត់។ ដូច្នេះ ត្រូវសរសេរពីកម្រិតនៃការប្រើប្រាស់ធនធានទាំងនេះ និងបញ្ហាប្រឈមចម្បងៗដែលកំពុងជួបប្រទះពាក់ព័ន្ធនឹងការប្រើប្រាស់នេះ។
- **បរិស្ថាន ៖** ត្រូវរៀបរាប់ពីសក្តានុពលពាក់ព័ន្ធនឹងបរិស្ថាន ដូចជាកន្លែងហាត់ប្រាណ និងសួន ឧទ្យានសាធារណៈ ទីលានចាក់សំរាម និងបញ្ហានានា ដែលគំរាមកំហែងលើបរិស្ថាន ដូចជាការបំពុលបរិយាកាស សំណល់រឹង និងរាវ។ល។

- **គ្រោះមហន្តរាយចម្បងៗ ៖** រៀបរាប់ពីស្ថានភាពនៃការបំផ្លិចបំផ្លាញដោយសារខ្យល់ព្យុះ ខ្យល់កន្ត្រាក់ ភ្លើងឆេះផ្ទះ គ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌមិនទាន់ផ្ទុះ គ្រោះទឹកជំនន់។ល។
- **ការប្រែប្រួលអាកាសធាតុ ៖** រៀបរាប់ពីទឹកជំនន់ ភាពរាំងស្ងួត សីតុណ្ហភាពឡើងខ្ពស់ កម្រិតទឹកភ្លៀងមិនទៀងទាត់។

**ការសរសេរពីស្ថានភាពរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ**

ផ្នែកនេះត្រូវសរសេររៀបរាប់ដោយសង្ខេបពីចំណុចសំខាន់ៗដូចជា អភិបាលកិច្ច ការគ្រប់គ្រងដែនដី ស្ថិតិប្រជាជន កិច្ចការសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ដោយផ្អែកលើលទ្ធផលនៃការវិភាគស្ថានភាពរដ្ឋបាលសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ។ ទិន្នន័យនិងព័ត៌មានមួយចំនួនដែលត្រូវរៀបរាប់ក្នុងផ្នែកនេះ មានបង្ហាញក្នុងតារាងផ្ទៃដីភូមិសាស្ត្រមូលដ្ឋាន (ចំនួនសង្កាត់ ភូមិ) និងស្ថិតិប្រជាជន។

- **អភិបាលកិច្ច ៖** រៀបរាប់ពីភាពខ្លាំង និងបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងអភិបាលកិច្ច។
- **គ្រប់គ្រងដែនដី ៖** រៀបរាប់ពីភាពខ្លាំង និងបញ្ហាប្រឈមពាក់ព័ន្ធនឹងការរៀបចំ និងគ្រប់គ្រងដែនដីរដ្ឋបាល ដូចជា ការកំណត់ព្រំប្រទល់ដែនដីភូមិសាស្ត្ររដ្ឋបាល និងតំបន់សំខាន់ៗក្នុងមូលដ្ឋាន ការបង្កើតក្រុង ស្រុក ឃុំ សង្កាត់ និងភូមិថ្មី ការរៀបចំប្លង់គោលជាដើម។
- **ការគ្រប់គ្រងស្ថិតិ៖** រៀបរាប់ពីបញ្ហាសំខាន់ៗពាក់ព័ន្ធនឹងការចុះបញ្ជី និងការងារអត្រានុកូលដ្ឋាន។
- **ការងារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ៖** រៀបរាប់ពីភាពខ្លាំង និងបញ្ហាសំខាន់ៗពាក់ព័ន្ធនឹងការគ្រប់គ្រង ការរក្សាសន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ នៅតំបន់ទីប្រជុំជនសំខាន់ៗ។

ចំពោះរដ្ឋបាលដែលនៅជាប់ព្រំដែន គួរបញ្ចូលការងារព្រំដែន ដូចជា ភាពងាយស្រួល និងការលំបាកក្នុងការរៀបចំ និងគ្រប់គ្រងច្រកព្រំដែន និងកិច្ចសហការជាមួយប្រទេសជិតខាង។